ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

# ព្រឹត្តិបត្រ

# គណៈកម្មាធិការជាតិភាសាខ្មែរ

## BULLETIN DU COMITÉ NATIONAL DE LA LANGUE KHMÈRE

## BULLETIN OF THE NATIONAL COMMISSION OF KHMER LANGUAGE

លេខ ៣ ឆ្នាំ២០១០

Vol. 3, 2010

លេខាធិការដ្ឋានអចិន្ត្រៃយ៍ : វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា (ជាន់ទី២)

Secrétariat permanent: Institut de la Langue Nationale de l'Académie Royale du Cambodge

Permanent Secretariat: National Language Institute of the Royal Academy of Cambodia

Tel: 012 911 357 / 012 580 310 / FAX: 024 998 019 / E-mail: nckl_secretariat@yahoo.com

## សេចក្តីជូនដំណឹង

**គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.)**

មានកិត្តិយសជម្រាបសាធារណជនថា គ.ជ.ខ.ភ.បានបង្កើតអង់តែនមួយ សម្រាប់ជួយអ្នកដែលគ្មានវចនានុក្រមប្រើប្រាស់ ហើយ ដែលមានបញ្ហាក្នុងការសរសេរពាក្យ ។ បើសាធារណជនរូបណា មានបញ្ហាដូចបានជម្រាបខាងលើនេះ សូមទាក់ទងមកលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ គ.ជ.ភ.ខ. ដែលមានទីតាំងនៅជាន់ទី២នៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា តាមរយៈទូរស័ព្ទលេខ :

០១២ ២៥២ ៤៧៣ , ០១២ ៥៨០ ៣១០ , ០១២ ២៧៤ ៤៣៩

# មាតិកា

**ចំណងជើង** **ទំព័រ**


- គណៈគ្រប់គ្រងនិងក្រុមការងារ........................................................................................................ i
- បុព្វកថា.........................................................................................................................................ii
- អនុក្រឹត្យលេខ ៧៥១ អនក្រ. គត ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៩ បន្ថែមសមាជិក គ.ជ.ភ.ខ. ២រូប ....................១
- លិខិតរបស់ក្រសួងសុខាភិបាល ចុះថ្ងៃ៣១-០៣-០៩ ចាត់តំណាងម្នាក់ឱ្យចូលរួមប្រជុំជាមួយ គ.ជ.ភ.ខ. ..................៣
- លិខិតរបស់ក្រសួងសុខាភិបាល ចុះថ្ងៃ២៧-១១-០៩ ចាត់តំណាងថ្មីជំនួសតំណាងចាស់..........................................៤
- លិខិតរបស់ក្រសួងកិច្ចការី ចុះថ្ងៃ១២-០៦-០៩ ចាត់តំណាងម្នាក់ឱ្យចូលរួមប្រជុំជាមួយ គ.ជ.ភ.ខ............................៥
- លិខិតរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃ៣០-០៦-១០ ចាត់តំណាងម្នាក់ឱ្យចូលរួមប្រជុំជាមួយ គ.ជ.ភ.ខ. ....................៦
- សេចក្តីសម្រេចលេខ ០១/០៩ គជភខ. សសរ ចុះថ្ងៃទី១៤ ខែ១២ ឆ្នាំ២០០៩ ស្តីពីការផ្ទេរភារកិច្ច និង ការប្រគល់ភារកិច្ចទាក់ទងនឹងសមាជិកមួយចំនួន ក្នុងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ គ.ជ.ភ.ខ. ......................................៧
- សេចក្តីសម្រេច លេខ ០២/០៩ គជភខ.សសរ ចុះថ្ងៃទី១៤ ខែ១២ ឆ្នាំ២០០៩ ស្តីពីការផ្ទេរភារកិច្ច ការប្រគល់ភារកិច្ច និង ការបន្ថែមសមាជិកក្នុងគណៈកម្មការបច្ចេកទេសនានារបស់ គ.ជ.ភ.ខ.................................................៩
- សម្រង់ពាក្យទាក់ទងនឹង ណ ន , ឡ ល .........................................................................................១៣
- គោលការណ៍បង្កើតពាក្យ..............................................................................................................១៦
- គោលការណ៍កម្ចីពាក្យ................................................................................................................២៦
- ជម្រើសរវាងការបង្កើតពាក្យនិងកម្ចីពាក្យ....................................................................................២៧
- បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ វិទ្យាសាស្ត្រនយោបាយ និង ការទូត ដែល គ.ជ.ភ.ខ.បានអនុម័ត .............៣១
- បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ មនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម ដែល គ.ជ.ភ.ខ.បានអនុម័ត............៤៣
- បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ វប្បធម៌ និង វិចិត្រសិល្បៈ ដែល គ.ជ.ភ.ខ.បានអនុម័ត..........................៤៧
- បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម ដែល គ.ជ.ភ.ខ.បានអនុម័ត ..............៤៩
- បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ ភាសាវិទ្យា និង អក្សរសិល្ប៍ ដែល គ.ជ.ភ.ខ.បានអនុម័ត ........................៥៦
- បញ្ជីរាយនាមសប្បុរសជន..............................................................................................................៧២
- សេចក្តីសម្រេចមូលដ្ឋានមួយចំនួន និង មតិសាធារណជន ................................................................៧២


**ឧបសម្ព័ន្ធ**


- លិខិតនៃ គ.ជ.ភ.ខ. ស្នើទៅ រ.ប.ស.ក. ឱ្យពិនិត្យលទ្ធភាពប្រើអក្ខរាវិរុទ្ធតាមវចនានុក្រមរបស់ ស. ជួន ណាត .........៧៥
- សេចក្តីជូនដំណឹងរបស់ រ.ប.ស.ក. សុំឱ្យស្ថាប័នក្រោមឱវាទប្រើអក្ខរាវិរុទ្ធតាមវចនានុក្រមរបស់ ស. ជួន ណាត ........៧៦
- បទបង្ហាញរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ អនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ភ.ខ. ក្នុងជំនួបជាមួយតំណាងប្រព័ន្ធផ្សព្វផ្សាយ នៅថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០១០ .......................................................................៧៧

## គណៈគ្រប់គ្រង

- ប្រធាន ................................ : ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ
- អនុប្រធានអចិន្ត្រៃយ៍ .... : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**
- អនុប្រធាន ......................... : ឯកឧត្តម **ឈន អៀម**
- អគ្គលេខាធិការ ................ : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន**
- អគ្គលេខាធិការរង .......... : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ **អ៊ីវ ច័ន**

## ក្រុមការងារ

### ១- ក្រុមអ្នកផ្ទៀងផ្ទាត់

- ប្រធាន : ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ សំណព្វ** សមាជិក គ.ជ.ភ.ខ.
- អនុប្រធាន : លោកសាស្ត្រាចារ្យ **ស៊ុំ ឈុំឡុង** ប្រធានការិយាល័យបោះពុម្ពផ្សាយ
- សមាជិក : លោកសាស្ត្រាចារ្យ **មាឃ បូរ៉ា** អនុប្រធានការិយាល័យរដ្ឋបាល
- សមាជិក : លោកសាស្ត្រាចារ្យ **ណុន សុខា** អនុប្រធានការិយាល័យរដ្ឋបាល

### ២- ក្រុមអ្នកចាត់ការទូទៅ

- លោកសាស្ត្រាចារ្យបណ្ឌិត **សន ពៅ** ប្រធានការិយាល័យហិរញ្ញវត្ថុ
- លោកសាស្ត្រាចារ្យ **ជួរ គារី** ប្រធានការិយាល័យរដ្ឋបាល
- លោកសាស្ត្រាចារ្យ **លាង សុភាព** អនុប្រធានការិយាល័យហិរញ្ញវត្ថុ

### ៣- ក្រុមអ្នករៀបចំ

- លោកសាស្ត្រាចារ្យ **សេ អឿន** អនុប្រធានការិយាល័យបោះពុម្ពផ្សាយ
- លោកសាស្ត្រាចារ្យ **ប៊ី សុខគង់** អនុប្រធានការិយាល័យបោះពុម្ពផ្សាយ
- លោកសាស្ត្រាចារ្យ **ឡុង សុរិន្ទ** សមាជិកការិយាល័យបោះពុម្ពផ្សាយ
- លោកស្រីសាស្ត្រាចារ្យ **តិប ស៊ីណា** សមាជិកការិយាល័យបោះពុម្ពផ្សាយ
- លោកសាស្ត្រាចារ្យ **លី សុធីរ័ត្ន** សមាជិកការិយាល័យបោះពុម្ពផ្សាយ
- លោក **ប៊ុត សុម៉េត** សមាជិកការិយាល័យបោះពុម្ពផ្សាយ

# **បុព្វកថា**

ដូចលេខ១និងលេខ២ដែរ ព្រឹត្តិបត្រលេខ៣លើកនេះ ចុះផ្សាយលទ្ធផលនៃកិច្ចការរបស់គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ដើម្បីឱ្យសាធារណជនជ្រាប និង មានមតិទិតៀនស្ថាបនាតាមដែលអាចធ្វើបាន ។

- គួររំលឹកថា គ.ជ.ភ.ខ.មានភារកិច្ចស្វែងរកការឯកភាពជូនភាសាខ្មែរលើចំណុចមួយចំនួន : ការឯកភាពក្នុងការសរសេរពាក្យ ក្នុងការអានពាក្យ ក្នុងការបង្កើតនិងការប្រើពាក្យ និង ក្នុងការខ្ចីពាក្យពីភាសាបរទេស ។

ក្នុងព្រឹត្តិបត្រលេខ២ គ.ជ.ភ.ខ.បានចុះផ្សាយពាក្យកម្ចីសម្គាល់ប្រទេសក្នុងលោក (ក្នុងចំណោមលទ្ធផលសំខាន់ៗឯទៀត) ដើម្បីទប់ស្កាត់ឱ្យទាន់ពេលកុំឱ្យ អ្នកខ្លះថា *កូឌីវ័រ* អ្នកខ្លះថា *អៃវរីខូស* , អ្នកខ្លះថា *ស៊ីប* អ្នកខ្លះថា *សៃប្រឹស* ជាដើម ។ ពាក្យកម្ចីត្រូវក្លាយទៅជាពាក្យខ្មែរដូចពាក្យឯទៀតដែរ : បើខ្មែរខ្ចីពាក្យមិនដូចគ្នា ភាសាខ្មែរនឹងខ្វះការឯកភាពកាន់តែច្រើនឡើង បន្ថែមលើកង្វះការឯកភាពដែលមានស្រាប់ ហើយ ដែល គ.ជ.ភ.ខ.កំពុងខំដោះស្រាយ ។

ក្នុងព្រឹត្តិបត្រលេខ៣លើកនេះ គ.ជ.ភ.ខ.ចុះផ្សាយលទ្ធផលរបស់ខ្លួនក្នុងគោលដៅដែលដូចមានចែងខាងលើ ។ តាមរយៈអំណានរបស់ខ្លួន សាធារណជនអាចសង្កេតឃើញថា អំណើះតទៅ ក្នុងចំណោមពាក្យជាច្រើនសម្រាប់បញ្ញត្តិតែមួយ ដូច *កម្មវង*, *កម្មបទ*, *បទកម្ម*, និង *កម្ម* ជាដើម គ.ជ.ភ.ខ.អនុម័តយកតែពាក្យ *កម្ម* មួយទេ ។ ក្នុងចំណោមអក្ខរាវិរុទ្ធពីរបីបែប ដូច *សំឡេង*, *សំលេង* និង *សម្លេង* ជាដើម គ.ជ.ភ.ខ.ត្រូវរក្សាទុកតែអក្ខរាវិរុទ្ធ *សំឡេង* ដែលត្រឹមត្រូវតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ។ ល ។ ឧទាហរណ៍ពីរបែបដែលទើបបានបង្ហាញនេះ ជាតំណាងលទ្ធផលច្រើនទៀតដែលឆ្លុះបញ្ចាំងការខំប្រឹងប្រែងរបស់ គ.ជ.ភ.ខ.ក្នុងការស្វែងរកការឯកភាពជូនភាសាខ្មែរ ។

ប៉ុន្តែ ការផ្សព្វផ្សាយតាមរយៈព្រឹត្តិបត្រមិនអាចជ្រួតជ្រាបដល់សាធារណជនគ្រប់ស្រទាប់ទេ ពីព្រោះព្រឹត្តិ-បត្រមានចំនួនត្រឹមពីរបីពាន់ក្បាលប៉ុណ្ណោះ : គ.ជ.ភ.ខ.ត្រូវប្រើមធ្យោបាយផ្សេងៗទៀត ដើម្បីឱ្យការផ្សព្វផ្សាយជ្រួតជ្រាបដល់គ្រប់ស្រទាប់នៃសាធារណជន ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ០៩ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **សុខ អាន**

...កម្មាធិការជាតិ...
ចូល បានទទួលថ្ងៃ ២៥/03/16
ម៉ោង ៣ រសៀល
លេខ ០០៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ៧៥១ អនក្រ.តត**

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងសមាជិកបន្ថែមនៃគណៈកម្មាធិការជាតិភាសាខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ៧៩២ អនក្រ.តត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងជាសមាជិកបន្ថែមនៃគណៈកម្មាធិការជាតិភាសាខ្មែរ ដូចមានរាយនាមខាងក្រោម៖

១-លោកសាស្ត្រាចារ្យ **អុក ចួន** អតីតព្រឹទ្ធបុរសរងមហាវិទ្យាល័យសង្គមសាស្ត្រ មនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

២-លោក **ខូច គីមស្រ៊ាន** សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិតសភាកម្ពុជា
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិភាសាខ្មែរ

ចូល មកដល់ថ្ងៃ 20/5/09 ម៉ោង ១៣:០០ លេខ 003 កំណត់

ក្រសួងសុខាភិបាល

លេខ ០៤៤៦ សា.ឧ៩ឃ

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៩

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សូមគោរពជូន

**ឯកឧត្តមប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

កម្មវត្ថុ : ការចាត់តាំងតំណាងក្រសួងសុខាភិបាលអោយចូលរួមជាសមាជិកអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិភាសាខ្មែរ ។

យោង : លិខិតលេខ : ០១៦.០៩ គជភខ.រ ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិភាសាខ្មែរ ។

សេចក្តីដូចមានចែងជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធានថា : ក្រសួងសុខាភិបាលសូមចាត់តាំង លោកស្រីឱសថការី **ខិន ឈាង** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល អោយទៅចូលរួមជាសមាជិក អចិន្ត្រៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ) ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម ឯកឧត្តមប្រធាន មេត្តាជ្រាបដោយការគួរ ។

សូមឯកឧត្តមប្រធានមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

វេជ្ជ. តែ_គុយស៊ាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ១៣៧ អឧស.អឧម

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៩

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**គោរពជូន**

**ឯកឧត្តមប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

<u>កម្មវត្ថុ</u> :សំណើសុំផ្លាស់ប្តូរសមាសភាពមន្ត្រី ចូលរួមជាសមាជិកអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិភាសាខ្មែរ។

<u>យោង</u> :លិខិតលេខ ០៤៦ ស.នរប ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ របស់ ក្រសួងសុខាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសជំរាបជូនឯកឧត្តមប្រធានជ្រាបថា ក្រសួងសុខាភិបាល ស្នើសុំ ចាត់បញ្ជូនលោកវេជ្ជ. **ជួង តារារិទ្ធ** ព្រឹទ្ធបុរសរងមហាវិទ្យាល័យវេជ្ជសាស្ត្រនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដើម្បីចូលរួមជាសមាជិកអចិន្ត្រៃយ៍នៃ គណៈកម្មាធិការជាតិភាសាខ្មែរ ជំនួសឱ្យលោកស្រីឱសថការី **ជិន ឈាច** អគ្គនាយករងរដ្ឋបាល-ហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះសូមឯកឧត្តមប្រធានជ្រាប និងទទួលស្គាល់មន្ត្រីខាងលើតាមការគួរ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

វេជ្ជ. តែ-គុយស៊ាង

<u>ចំលងជូន</u> :

- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាបជាពត៌មាន"

- អង្គភាពសាម៉ី
- សាម៉ីខ្លួន
- ឯកសារ

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល,លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៨ / ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៣៣

ក្រសួង កិច្ចការនារី

គណៈកម្មាធិការជាតិភាសាខ្មែរ
ចូល មកដល់ថ្ងៃ ១៥ ខែ មិថុនា ២០០៩
ម៉ោង ៩:០០ ព្រឹក
លេខ ០០៥ គជភខ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ២៧៥៥ កកន / ២.៥

## សូមគោរពជូន
## ឯកឧត្តមប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

**កម្មវត្ថុ** : ការចាត់តំណាងក្រសួងចំនួន ០១រូប ឱ្យចូលរួមជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ ( គ.ជ.ភ.ខ ) ។

**យោង** : លិខិតលេខ ០៣០/០៩.គជភខ/រ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៩ របស់គណៈកម្មាធិការជាតិភាសាខ្មែរ ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា : ក្រសួងកិច្ចការនារីបានចាត់លោកជំទាវ **ស៊ី វណ្ណបុត្តុច** រដ្ឋលេខាធិការ ឱ្យចូលរួមជាសមាជិកអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិភាសាខ្មែរ ( គ.ជ.ភ.ខ ) ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានមេត្តាជ្រាប និងមេត្តាទទួលដោយអនុគ្រោះ ។

សូមឯកឧត្តមប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។ ១៥៧

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៩

រដ្ឋមន្ត្រី

ក្រសួងកិច្ចការនារី ព្រះរាជាណាចក្រកម្ពុជា

**អ៊ឹង កន្ថាផាវី**

- ឯកសារ

អាគារលេខ ៣ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ (ភ្នំពេញ) ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៤២៦ ៥៣៩ / ២៣ ៤២៦ ៥៧៥
ទូរស័ព្ទ : (៨៥៥) ២៣ ២១៦ ៧០៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិភាសាខ្មែរ មកដល់ថ្ងៃ 02/7/2010 ម៉ោង 11 លេខ 008/10 ... ចូល

ក្រសួងពាណិជ្ជកម្ម

លេខ ៦៧៣១ ព.ណ.ចក

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០

រាជបណ្ឌិត្យសភាកម្ពុជា ចូល មកដល់ថ្ងៃទី 02/07/201 លេខ 488 របស់ ម៉ោង 10 h.00.

**ជម្រាបជូន**

**ឯកឧត្តម ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

**កម្មវត្ថុ:** ការចាត់មន្ត្រី ០១រូប ជាតំណាងក្រសួងពាណិជ្ជកម្ម ចូលរួមជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ)។

**យោង:** -លិខិតលេខ ០៣២/១០.គជភខ/រ ចុះថ្ងៃទី ១៤ ខែ ខែ មិថុនា ឆ្នាំ២០១០ របស់គណៈកម្មាធិការជាតិភាសាខ្មែរ។

តបតាមកម្មវត្ថុ និងសេចក្តីយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម ប្រធាន** ជ្រាបថា ក្រសួងពាណិជ្ជកម្ម សូមចាត់បញ្ជូនលោក ស៊ូ ម៉េង ប្រធានការិយាល័យតម្កល់ឯកសារបញ្ជីពាណិជ្ជកម្ម នៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ជាតំណាងក្រសួងពាណិជ្ជកម្ម ដើម្បីចូលរួមជាសមាជិកនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ) ដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខនេះ ក្នុងគោលបំណងចូលរួមវិភាគទានលើការផ្តល់យោបល់ដល់ការប្រើប្រាស់ភាសារខ្មែរ ជាពិសេស ចំពោះវាក្យស័ព្ទពាណិជ្ជកម្ម។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាប និងទទួលស្គាល់ តាមការគួរ។

សូម **ឯកឧត្តម ប្រធាន** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះ អំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម្លងជូន:**

- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- ឯកសារ កាលប្បវត្ត

**ចាម ប្រសិទ្ធ**

**ប៉ាន់ សូរស័ក្តិ** ... 

**ក៏ម ស៊ីថន**

សហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ/ទូរសារ: (៨៥៥) -២៣ ៨៦៦ ៤៦៩
Federation Blvd, Toeuk Thla Village, Sangkat Toeuk Thla, Khan Sen Sok, Phnom Penh, CAMBODIA Phone/Facsimile: (855)-23 866 469

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**គណៈកម្មាធិការជាតិភាសាខ្មែរ**
**លេខ:** ០១/០៩.គ.ជ.ភ.ខ_សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការផ្ទេរភារកិច្ច និងប្រគល់ភារកិច្ច
## របស់លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ៧៩២ អនក្រ.តត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ៧៥១ អនក្រ.តត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាជិកបន្ថែមនៃគណៈកម្មាធិការជាតិភាសាខ្មែរ

- បានឃើញសេចក្តីសម្រេចលេខ១២១ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ១២៣ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- តាមការងារចាំបាច់របស់គណៈកម្មាធិការជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១:** ត្រូវបានផ្ទេរភារកិច្ច ដូចខាងក្រោម ៖

១- លោក **លី សុធីរត្ន** ពីអនុប្រធានការិយាល័យហិរញ្ញវត្ថុ ទៅជាសមាជិកនៃការិយាល័យបោះពុម្ពផ្សាយ

២- លោកស្រី **អ៊ីង ម៉ាល័យ** ពីសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទវប្បធម៌និងវិចិត្រសិល្បៈ ទៅជាសមាជិកនៃការិយាល័យរដ្ឋបាល

**ប្រការ២:** ត្រូវបានប្រគល់ភារកិច្ចជូន ដូចខាងក្រោម ៖

១- លោកស្រី **រ័ត្ន ធីតា** មន្ត្រីហិរញ្ញវត្ថុនៃរាជបណ្ឌិតសភាកម្ពុជា ជាអនុប្រធាន ការិយាល័យហិរញ្ញវត្ថុ ជំនួសលោក **លី សុធីរត្ន**

២- លោក **ប៊ុត សុមេត** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃអគ្គលេខាធិការដ្ឋាន គ.ទ.ក. ជាសមាជិកការិយាល័យបោះពុម្ពផ្សាយ

**ប្រការ៣:** ប្រធានការិយាល័យរដ្ឋបាល ប្រធានការិយាល័យហិរញ្ញវត្ថុ ប្រធានការិយាល័យបោះពុម្ពផ្សាយ ប្រធានគណៈកម្មការបច្ចេកស័ព្ទវប្បធម៌និងវិចិត្រសិល្បៈ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 14 ខែ 12 ឆ្នាំ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

**សុខ អាន**

**កន្លែងទទួល :**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិតសភាកម្ពុជា
- អគ្គលេខាធិការដ្ឋាន គ.ទ.ក.
- សមាជិក គណៈកម្មាធិការជាតិភាសារខ្មែរ
- គណៈកម្មការបច្ចេកស័ព្ទនានា
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**គណៈកម្មាធិការជាតិភាសាខ្មែរ**

លេខៈ០២/០៨.គ.ម.ភ.ខ.ជ.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការផ្ទេរភារកិច្ច ប្រគល់ភារកិច្ច និងបន្ថែមសមាជិក នៃគណៈកម្មការបច្ចេកទេសនានារបស់គណៈកម្មាធិការជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គណៈកម្មាធិការជាតិភាសាខ្មែរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ៧៩២ អនក្រ.តត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ

- បានឃើញអនុក្រឹត្យលេខ ៧៥១ អនក្រ.តត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងសមាជិកបន្ថែមនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ១២១ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ១២៣ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- តាមការងារចាំបាច់របស់គណៈកម្មាធិការជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១:**

ត្រូវបានផ្ទេរភារកិច្ច ដូចខាងក្រោម ÷

១- លោកស្រីសាស្ត្រាចារ្យបណ្ឌិត **ឡាំ ទេវី** ពីសមាជិកនៃគណៈកម្មការបច្ចេកសព្ទវប្បធម៌និងវិចិត្រសិល្បៈ ឯកទេសសេដ្ឋកិច្ច ប្តូរទៅជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

២- ឯកឧត្តម **សឺង ផុស** ពីសមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្ពីពាក្យ ប្តូរទៅជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ ភាសាវិទ្យានិងអក្សរសិល្ប៍ ។

**ប្រការ២:**

ត្រូវបានប្រគល់ភារកិច្ច ដូចខាងក្រោម ÷

១- លោក **ពៅ ប៉ូលីណែល** មន្ត្រីផ្នែកច្បាប់អន្តរជាតិនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ ឯកទេសប្រវត្តិវិទ្យា ជាអនុប្រធាននៃគណៈកម្មការបច្ចេកសព្ទ វិទ្យាសាស្ត្រនយោបាយនិងការទូត ជំនួសលោកសាស្ត្រាចារ្យបណ្ឌិត **គា គីរីរេណុល**

២- លោក **ប្លង់ គីរម្យ** មន្ត្រីវិទ្យាស្ថានភាសាជាតិឯកទេសភាសាវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជំនួសលោក **អ៊ុក សៅបុល**

៣- លោកសាស្ត្រាចារ្យ **គុយ រិន** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសភាសាវិទ្យាជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ វប្បធម៌និងវិចិត្រសិល្បៈ ជំនួសលោកស្រី **អ៊ឹង ម៉ាល័យ** ។

**ប្រការ៣:**

ត្រូវបានបន្ថែមសមាជិក គណៈកម្មការបច្ចេកសព្ទនានា ដូចខាងក្រោម ÷

១- លោកសាស្ត្រាចារ្យបណ្ឌិត **ឆេង វណ្ណារិទ្ធ** ប្រធានផ្នែកនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកទេសសេដ្ឋកិច្ច ជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ។

២- លោកស្រី **ជា វណ្ណី** មន្ត្រីផ្នែកនរវិទ្យានិងជាតិពន្ធុវិទ្យា ឯកទេស អក្សរសិល្ប៍ ជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

៣- ឯកឧត្តមសាស្ត្រាចារ្យ **ត្រឹង លីម** ទីប្រឹក្សាអមរាជបណ្ឌិតសភាកម្ពុជា ឯកទេសគ្រប់គ្រង ជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ វិទ្យាសាស្ត្រនយោបាយនិងការទូត

៤- លោកសាស្ត្រាចារ្យ **ឈាង សុភាព** អនុប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ ឯកទេសគ្រប់គ្រង ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយ និងការទូត

៥- លោកស្រី **ហេង ដារី** មន្ត្រីផ្នែករដ្ឋបាល ឯកទេសវិទ្យាសាស្ត្រនយោបាយ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយ និងការទូត

៦- លោកសាស្ត្រាចារ្យ **ប៊ី សុខគង់** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសភាសាវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

៧- លោកស្រីសាស្ត្រាចារ្យ **តាង ណារង** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសអក្សរសិល្ប៍ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

៨- លោកសាស្ត្រាចារ្យ **ណុន សុខា** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសអក្សរសិល្ប៍ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

៩- លោកសាស្ត្រាចារ្យបណ្ឌិត **នៅ ស៊ុន** មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ឯកទេសភាសាវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

១០- លោកស្រីសាស្ត្រាចារ្យបណ្ឌិត **ឈុំ ណារី** ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឯកទេសរូបវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

១១- លោកសាស្ត្រាចារ្យ **តាត់ ចាន់ថា** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ឯកទេសបច្ចេកវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

១២- លោកសាស្ត្រាចារ្យបណ្ឌិត **ហ៊ឹម សុភី** ប្រធានផ្នែកសិល្បៈប្រជាប្រិយនៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ ឯកទេសវិទ្យាសាស្ត្រសិល្បៈ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទវប្បធម៌ និងវិចិត្រសិល្បៈ

១៣- លោកសាស្ត្រាចារ្យ **ឈឹម សុខាន់ដារ៉ា** មន្ត្រីវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ ឯកទេសបុរាណវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វប្បធម៌ និងវិចិត្រសិល្បៈ

១៤- លោកសាស្ត្រាចារ្យបណ្ឌិត **គឹម ពីនន់** ព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឯកទេសវិទ្យាសាស្ត្រសិល្បៈ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វប្បធម៌ និងវិចិត្រសិល្បៈ

១៥- លោក **ចាន់ ប៊ុន្នី** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសគ្រប់គ្រងសាធារណៈ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម

១៦- លោក **តាំង ស៊ិន** មន្ត្រីនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសបសុពេទ្យ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម

១៧- លោក **សួន សុភា** មន្ត្រីនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសក្សេត្រសាស្ត្រ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម

១៨- លោក **អាត ធារ៉ា** មន្ត្រីនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសវេជ្ជសាស្ត្រ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ។

**ប្រការ៤:** ប្រធានការិយាល័យរដ្ឋបាល ប្រធានការិយាល័យហិរញ្ញវត្ថុ ប្រធានការិយាល័យបោះពុម្ពផ្សាយ ប្រធានគណៈកម្មការបច្ចេកស័ព្ទពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 14 ខែ 12 ឆ្នាំ២០០៩*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធាន គណៈកម្មាធិការជាតិភាសាខ្មែរ**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិតសភាកម្ពុជា
- សមាជិក គណៈកម្មាធិការជាតិភាសាខ្មែរ
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

ដើម្បីជួយសាធារណជនក្នុងការសរសេរពាក្យឱ្យបានត្រឹមត្រូវតាមវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ដែល គ.ជ.ភ.ខ. បានអនុម័តយកជាមូលដ្ឋាន កាលពីថ្ងៃពុធ២០-០២-០៨និង ដែលសម្ដេចតេជោបានប្រកាសកាលពីថ្ងៃសុក្រ១៩-០៣-១០ ឱ្យ គ.ជ.ភ.ខ.ផ្សព្វផ្សាយឱ្យបានទូលំទូលាយ គ.ជ.ភ.ខ.ចុះផ្សាយអក្ខរាវិរុទ្ធត្រឹមត្រូវតាមវចនានុក្រមខាងលើ និង អក្ខរាវិរុទ្ធមិនត្រឹមត្រូវ ក្នុងតារាង ដូចមានខាងក្រោម :

<u>សេចក្ដីបញ្ជាក់</u> : បញ្ជីពាក្យក្នុងតារាងខាងក្រោម ត្រូវបានជ្រើសចេញពីសម្រង់របស់លោកស្រី ហង់ ថារី ដែលគាត់បានធ្វើឡើងក្នុងបំណងផ្សេង។ ជម្រើសរបស់យើងបានជម្រុះពាក្យមួយចំនួនដែលវចនានុក្រមរបស់សម្ដេច ជួន ណាត អនុញ្ញាតឱ្យប្រើអក្សរ *ណ* ក៏បាន ឬ *ន* ក៏បាន និង *ឡ* ក៏បាន ឬ *ល* ក៏បាន, ឧ. កំណួចឬកំនួច, ស្រឡាបឬស្រលាប ,...

| ល.រ. | អក្ខរាវិរុទ្ធត្រឹមត្រូវតាមវចនានុក្រម ស.ជួន ណាត | អក្ខរាវិរុទ្ធ<u>មិន</u>ត្រឹមត្រូវ | ល.រ. | អក្ខរាវិរុទ្ធត្រឹមត្រូវតាមវចនានុក្រម ស.ជួន ណាត | អក្ខរាវិរុទ្ធ<u>មិន</u>ត្រឹមត្រូវ | ល.រ. | អក្ខរាវិរុទ្ធត្រឹមត្រូវតាមវចនានុក្រម ស.ជួន ណាត | អក្ខរាវិរុទ្ធ<u>មិន</u>ត្រឹមត្រូវ |
|---|---|---|---|---|---|---|---|---|
| **ប្រើអក្សរ ណ មិនប្រើអក្សរ ន ទេ** | | | ២៦ | កំណោស | ~~កំនោស~~ | ៥២ | ចំណៀស | ~~ចំនៀស~~ |
| **ក** | | | ២៧ | កំណោះ | ~~កំនោះ~~ | ៥៣ | ចំណេញ | ~~ចំនេញ~~ |
| ១ | កំណកំណើត | ~~កំនកំនើត~~ | ២៨ | ក្រណាន់ | ~~ក្រនាន់~~ | ៥៤ | ចំណេរ | ~~ចំនេរ~~ |
| ២ | កំណក | ~~កំនក~~ | **ច** | | | ៥៥ | ចំណេះ | ~~ចំនេះ~~ |
| ៣ | កំណប់ | ~~កំនប់~~ | ២៩ | ចំណ | ~~ចំន~~ | ៥៦ | ចំណែក | ~~ចំនែក~~ |
| ៤ | កំណល់ | ~~កំនល់~~ | ៣០ | ចំណង | ~~ចំនង~~ | ៥៧ | ចំណែង | ~~ចំនែង~~ |
| ៥ | កំណាច | ~~កំនាច~~ | ៣១ | ចំណត | ~~ចំនត~~ | ៥៨ | ចំណែវ | ~~ចំនែវ~~ |
| ៦ | កំណាញ់ | ~~កំនាញ់~~ | ៣២ | ចំណត់ | ~~ចំនត់~~ | ៥៩ | ចំណោត | ~~ចំនោត~~ |
| ៧ | កំណាត់ | ~~កំនាត់~~ | ៣៣ | ចំណរ | ~~ចំនរ~~ | ៦០ | ចំណោទ | ~~ចំនោទ~~ |
| ៨ | កំណាន់ | ~~កំនាន់~~ | ៣៤ | ចំណាក់ | ~~ចំនាក់~~ | ៦១ | ចំណោម | ~~ចំនោម~~ |
| ៩ | កំណាព្យ | ~~កំនាព្យ~~ | ៣៥ | ចំណាន | ~~ចំនាន~~ | ៦២ | ចំណោល | ~~ចំនោល~~ |
| ១០ | កំណារ | ~~កំនារ~~ | ៣៦ | ចំណាប់ | ~~ចំនាប់~~ | ៦៣ | ចំណោះ | ~~ចំនោះ~~ |
| ១១ | កំណិន | ~~កំនិន~~ | ៣៧ | ចំណាយ | ~~ចំនាយ~~ | ៦៤ | ចំណំ | ~~ចំនំ~~ |
| ១២ | កំណើត | ~~កំនើត~~ | ៣៨ | ចំណារ | ~~ចំនារ~~ | ៦៥ | ចំណាំ | ~~ចំនាំ~~ |
| ១៣ | កំណើន | ~~កំនើន~~ | ៣៩ | ចំណាល | ~~ចំនាល~~ | ៦៦ | ចំណាំង | ~~ចំនាំង~~ |
| ១៤ | កំណើល | ~~កំនើល~~ | ៤០ | ចំណាល់ | ~~ចំនាល់~~ | ៦៧ | ច្រណែន | ~~ច្រនែន~~ |
| ១៥ | កំណៀង | ~~កំនៀង~~ | ៤១ | ចំណាស់ | ~~ចំនាស់~~ | **ដ** | | |
| ១៦ | កំណៀច | ~~កំនៀច~~ | ៤២ | ចំណិត | ~~ចំនិត~~ | ៦៨ | ដំណក | ~~ដំនក~~ |
| ១៧ | កំណៀវ | ~~កំនៀវ~~ | ៤៣ | ចំណី | ~~ចំនី~~ | ៦៩ | ដំណក់ | ~~ដំនក់~~ |
| ១៨ | កំណៀស | ~~កំនៀស~~ | ៤៤ | ចំណឹក | ~~ចំនឹក~~ | ៧០ | ដំណង | ~~ដំនង~~ |
| ១៩ | កំណេះ | ~~កំនេះ~~ | ៤៥ | ចំណឹប | ~~ចំនឹប~~ | ៧១ | ដំណល់ | ~~ដំនល់~~ |
| ២០ | កំណែន | ~~កំនែន~~ | ៤៦ | ចំណុក | ~~ចំនុក~~ | ៧២ | ដំណាក់ | ~~ដំនាក់~~ |
| ២១ | កំណែ | ~~កំនែ~~ | ៤៧ | ចំណុច | ~~ចំនុច~~ | ៧៣ | ដំណាច់ | ~~ដំនាច់~~ |
| ២២ | កំណោង | ~~កំនោង~~ | ៤៨ | ចំណុះ | ~~ចំនុះ~~ | ៧៤ | ដំណាប់ | ~~ដំនាប់~~ |
| ២៣ | កំណោត | ~~កំនោត~~ | ៤៩ | ចំណូក | ~~ចំនូក~~ | ៧៥ | ដំណាល | ~~ដំនាល~~ |
| ២៤ | កំណោន | ~~កំនោន~~ | ៥០ | ចំណូរ | ~~ចំនូរ~~ | ៧៦ | ដំណាល់ | ~~ដំនាល់~~ |
| ២៥ | កំណោរ | ~~កំនោរ~~ | ៥១ | ចំណូល | ~~ចំនូល~~ | ៧៧ | ដំណាស់ | ~~ដំនាស់~~ |

| ល.រ. | អក្ខរាវិរុទ្ធ ត្រឹមត្រូវតាម វចនានុក្រម ស.ជួន ណាត | អក្ខរាវិរុទ្ធ មិនត្រឹមត្រូវ |
|---|---|---|
| ៧៨ | ដំណិត | ~~ដំនិត~~ |
| ៧៩ | ដំណឹង | ~~ដំនឹង~~ |
| ៨០ | ដំណុត | ~~ដំនុត~~ |
| ៨១ | ដំណុស | ~~ដំនុស~~ |
| ៨២ | ដំណុះ | ~~ដំនុះ~~ |
| ៨៣ | ដំណួច | ~~ដំនួច~~ |
| ៨៤ | ដំណុរ | ~~ដំនុរ~~ |
| ៨៥ | ដំណួច | ~~ដំនួច~~ |
| ៨៦ | ដំណួល | ~~ដំនួល~~ |
| ៨៧ | ដំណួស | ~~ដំនួស~~ |
| ៨៨ | ដំណើប | ~~ដំនើប~~ |
| ៨៩ | ដំណើរ | ~~ដំនើរ~~ |
| ៩០ | ដំណៀង | ~~ដំនៀង~~ |
| ៩១ | ដំណៀល | ~~ដំនៀល~~ |
| ៩២ | ដំណេក | ~~ដំនេក~~ |
| ៩៣ | ដំណេញ | ~~ដំនេញ~~ |
| ៩៤ | ដំណេរ | ~~ដំនេរ~~ |
| ៩៥ | ដំណែង | ~~ដំនែង~~ |
| ៩៦ | ដំណោត | ~~ដំនោត~~ |
| ៩៧ | ដំណោយ | ~~ដំនោយ~~ |
| ៩៨ | ដំណោល | ~~ដំនោល~~ |
| ៩៩ | ដំណោះ | ~~ដំនោះ~~ |
| ១០០ | ដំណៅ | ~~ដំនៅ~~ |
| ១០១ | ដំណំ | ~~ដំនំ~~ |
| ១០២ | ដំណាំ | ~~ដំនាំ~~ |
| | **ត** | |
| ១០៣ | តំណក | ~~តំនក~~ |
| ១០៤ | តំណក់ | ~~តំនក់~~ |
| ១០៥ | តំណាង | ~~តំនាង~~ |
| ១០៦ | តំណាប់ | ~~តំនាប់~~ |
| ១០៧ | តំណាល | ~~តំនាល~~ |
| ១០៨ | តំណិច | ~~តំនិច~~ |
| ១០៩ | តំណិះ | ~~តំនិះ~~ |
| ១១០ | តំណឹង | ~~តំនឹង~~ |
| ១១១ | តំណុះ | ~~តំនុះ~~ |
| ១១២ | តំណួច | ~~តំនួច~~ |
| ១១៣ | តំណែង | ~~តំនែង~~ |
| ១១៤ | តំណោង | ~~តំនោង~~ |
| ១១៥ | តំណាំង | ~~តំនាំង~~ |
| ១១៦ | ត្រណម | ~~ត្រនម~~ |
| ១១៧ | ត្រណាក់ចិត្ត | ~~ត្រនាក់ចិត្ត~~ |
| ១១៨ | ត្រណោត | ~~ត្រនោត~~ |
| | **ប** | |
| ១១៩ | បំណង | ~~បំនង~~ |
| ១២០ | បំណន់ | ~~បំនន់~~ |
| ១២១ | បំណាក់ | ~~បំនាក់~~ |
| ១២២ | បំណាច់ | ~~បំនាច់~~ |
| ១២៣ | បំណាត់ | ~~បំនាត់~~ |
| ១២៤ | បំណិទ | ~~បំនិទ~~ |
| ១២៥ | បំណុល | ~~បំនុល~~ |
| ១២៦ | បំណើក | ~~បំនើក~~ |
| ១២៧ | បំណែ | ~~បំនែ~~ |
| ១២៨ | បំណែក | ~~បំនែក~~ |
| ១២៩ | បំណោក | ~~បំនោក~~ |
| ១៣០ | បំណាំ | ~~បំនាំ~~ |
| ១៣១ | បំណះ | ~~បំនះ~~ |
| ១៣២ | ប្រណាក | ~~ប្រនាក~~ |
| ១៣៣ | ប្រណិងប្រណុង | ~~ប្រនិងប្រនុង~~ |
| ១៣៤ | ប្រណាំង | ~~ប្រនាំង~~ |
| | **ស** | |
| ១៣៥ | សំណ | ~~សំន~~ |
| ១៣៦ | សំណក | ~~សំនក~~ |
| ១៣៧ | សំណង | ~~សំនង~~ |
| ១៣៨ | សំណង់ | ~~សំនង់~~ |
| ១៣៩ | សំណព្វ | ~~សំនព្វ~~ |
| ១៤០ | សំណល់ | ~~សំនល់~~ |
| ១៤១ | សំណាដៃ | ~~សំនាដៃ~~ |
| ១៤២ | សំណាក | ~~សំនាក~~ |
| ១៤៣ | សំណាក់ | ~~សំនាក់~~ |
| ១៤៤ | សំណាង | ~~សំនាង~~ |
| ១៤៥ | សំណាញ | ~~សំនាញ~~ |
| ១៤៦ | សំណាញ់ | ~~សំនាញ់~~ |
| ១៤៧ | សំណាត់ | ~~សំនាត់~~ |
| ១៤៨ | សំណាប | ~~សំនាប~~ |
| ១៤៩ | សំណាម | ~~សំនាម~~ |
| ១៥០ | សំណិង | ~~សំនិង~~ |
| ១៥១ | សំណុំ | ~~សំនុំ~~ |
| ១៥២ | សំណឹក | ~~សំនឹក~~ |
| ១៥៣ | សំណុស | ~~សំនុស~~ |
| ១៥៤ | សំណុះ | ~~សំនុះ~~ |
| ១៥៥ | សំណួក | ~~សំនួក~~ |
| ១៥៦ | សំណួម | ~~សំនួម~~ |
| ១៥៧ | សំណួរ | ~~សំនួរ~~ |
| ១៥៨ | សំណើ | ~~សំនើ~~ |
| ១៥៩ | សំណើច | ~~សំនើច~~ |
| ១៦០ | សំណើម | ~~សំនើម~~ |
| ១៦១ | សំណេះ | ~~សំនេះ~~ |
| ១៦២ | សំណេះសំណាល | ~~សំនេះសំនាល~~ |
| ១៦៣ | សំណែន | ~~សំនែន~~ |
| ១៦៤ | សំណែព | ~~សំនែព~~ |
| ១៦៥ | សំណែស | ~~សំនែស~~ |
| ១៦៦ | សំណោក | ~~សំនោក~~ |
| ១៦៧ | សំណៅ | ~~សំនៅ~~ |
| ១៦៨ | ស្រណាង | ~~ស្រនាង~~ |
| ១៦៩ | ស្រណាន | ~~ស្រនាន~~ |
| ១៧០ | ស្រណុក | ~~ស្រនុក~~ |
| ១៧១ | ស្រណោក | ~~ស្រនោក~~ |
| ១៧២ | ស្រណោះ | ~~ស្រនោះ~~ |
| | **អ** | |
| ១៧៣ | អាណិត | ~~អានិត~~ |
| ១៧៤ | អាណោច | ~~អានោច~~ |
| ១៧៥ | អំណត់ | ~~អំនត់~~ |

| ល.រ. | អក្ខរាវិរុទ្ធត្រឹមត្រូវតាមវចនានុក្រម ស.ជួន ណាត | អក្ខរាវិរុទ្ធ<u>មិន</u>ត្រឹមត្រូវ |
|---|---|---|
| ១៧៦ | អំណរ | ~~អំនរ~~ |
| ១៧៧ | អំណស់ | ~~អំនស់~~ |
| ១៧៨ | អំណាច | ~~អំនាច~~ |
| ១៧៩ | អំណឹះ | ~~អំនឹះ~~ |
| ១៨០ | អំណើះ | ~~អំនើះ~~ |
| ១៨១ | អំណោយ | ~~អំនោយ~~ |
| **ប្រើព្យាង្គតម្រួតឬអក្សរ ឡ មិនប្រើអក្សរ ល ទេ** | | |
| **ក** | | |
| ១ | កម្លា | ~~កំលា~~ |
| ២ | កម្លាច | ~~កំលាច~~ |
| ៣ | កម្លោច | ~~កំលោច~~ |
| ៤ | កម្លៅ | ~~កំលៅ~~ |
| ៥ | កម្លាំង | ~~កំលាំង~~ |
| ៦ | ក្រឡ | ~~ក្រល~~ |
| ៧ | ក្រឡក | ~~ក្រលក~~ |
| ៨ | ក្រឡង់ | ~~ក្រលង់~~ |
| ៩ | ក្រឡា | ~~ក្រលា~~ |
| ១០ | ក្រឡាញ់ | ~~ក្រលាញ់~~ |
| ១១ | ក្រឡាន | ~~ក្រលាន~~ |
| ១២ | ក្រឡាប់ | ~~ក្រលាប់~~ |
| ១៣ | ក្រឡាស់ | ~~ក្រលាស់~~ |
| ១៤ | ក្រឡឹង | ~~ក្រលឹង~~ |
| ១៥ | ក្រឡឹប | ~~ក្រលឹប~~ |
| ១៦ | ក្រឡឹម | ~~ក្រលឹម~~ |
| ១៧ | ក្រឡុញ | ~~ក្រលុញ~~ |
| ១៨ | ក្រឡុប | ~~ក្រលុប~~ |
| ១៩ | ក្រឡូម | ~~ក្រលូម~~ |
| ២០ | ក្រឡេក | ~~ក្រលេក~~ |
| ២១ | ក្រឡេច | ~~ក្រលេច~~ |
| ២២ | ក្រឡេចក្រឡុច | ~~ក្រលេចក្រលុច~~ |
| ២៣ | ក្រឡែត | ~~ក្រលែត~~ |
| ២៤ | ក្រឡោ | ~~ក្រលោ~~ |
| ២៥ | ក្រឡោត | ~~ក្រលោត~~ |

| ល.រ. | អក្ខរាវិរុទ្ធត្រឹមត្រូវតាមវចនានុក្រម ស.ជួន ណាត | អក្ខរាវិរុទ្ធ<u>មិន</u>ត្រឹមត្រូវ |
|---|---|---|
| **ច** | | |
| ២៦ | ក្រឡៅ | ~~ក្រលៅ~~ |
| ២៧ | ចម្លង | ~~ចំលង~~ |
| ២៨ | ចម្លាក់ | ~~ចំលាក់~~ |
| ២៩ | ចម្លើយ | ~~ចំលើយ~~ |
| ៣០ | ចម្លែក | ~~ចំលែក~~ |
| ៣១ | ចំឡក | ~~ចំលក~~ |
| ៣២ | ចំឡក់ | ~~ចំលក់~~ |
| ៣៣ | ចំឡៅក្អែក | ~~ចំលៅក្អែក~~ |
| ៣៤ | ច្រឡាស់ | ~~ច្រលាស់~~ |
| ៣៥ | ច្រឡឹង | ~~ច្រលឹង~~ |
| ៣៦ | ច្រឡឹម | ~~ច្រលឹម~~ |
| ៣៧ | ច្រឡុង | ~~ច្រលុង~~ |
| ៣៨ | ច្រឡូក | ~~ច្រលូក~~ |
| ៣៩ | ច្រឡោ | ~~ច្រលោ~~ |
| ៤០ | ច្រឡោត | ~~ច្រលោត~~ |
| ៤១ | ច្រឡំ | ~~ច្រលំ~~ |
| **ដ** | | |
| ៤២ | ដំឡាន់ | ~~ដំលាន់~~ |
| ៤៣ | ដំឡូង | ~~ដំលូង~~ |
| ៤៤ | ដំឡើង | ~~តំលើង~~ |
| ៤៥ | ដំឡោក | ~~ដំលោក~~ |
| **ត** | | |
| ៤៦ | តម្លង់ | ~~តំលង់~~ |
| ៤៧ | តម្លា | ~~តំលា~~ |
| ៤៨ | តម្លឹង | ~~តំលឹង~~ |
| ៤៩ | តម្លុញ | ~~តំលុញ~~ |
| ៥០ | តម្លៃ | ~~តំលៃ~~ |
| ៥១ | តម្លោះ | ~~តំលោះ~~ |
| ៥២ | ត្រឡក | ~~ត្រលក~~ |
| ៥៣ | ត្រឡាច | ~~ត្រលាច~~ |
| ៥៤ | ត្រឡាយ | ~~ត្រលាយ~~ |
| ៥៥ | ត្រឡែងកែង | ~~ត្រលែងកែង~~ |
| ៥៦ | ត្រឡោក | ~~ត្រលោក~~ |

| ល.រ. | អក្ខរាវិរុទ្ធត្រឹមត្រូវតាមវចនានុក្រម ស.ជួន ណាត | អក្ខរាវិរុទ្ធ<u>មិន</u>ត្រឹមត្រូវ |
|---|---|---|
| ៥៧ | ត្រឡុំ | ~~ត្រលុំ~~ |
| ៥៨ | ប្រឡាក់ | ~~ប្រលាក់~~ |
| ៥៩ | ប្រឡាយ | ~~ប្រលាយ~~ |
| ៦០ | ប្រឡិងប្រឡាំង | ~~ប្រលិងប្រលាំង~~ |
| ៦១ | ប្រឡិមប្រឡុំ | ~~ប្រលិមប្រលុំ~~ |
| ៦២ | ប្រឡុបប្រឆា | ~~ប្រលុបប្រឆា~~ |
| ៦៣ | ប្រឡែប្រកោ | ~~ប្រលែប្រកោ~~ |
| ៦៤ | ប្រឡៅ | ~~ប្រលៅ~~ |
| ៦៥ | ប្រឡាំងកាស | ~~ប្រលាំងកាស~~ |
| **ស** | | |
| ៦៦ | សម្ល | ~~សំល~~ |
| ៦៧ | សម្លក់ | ~~សំលក់~~ |
| ៦៨ | សម្លប | ~~សំលប~~ |
| ៦៩ | សម្លាក | ~~សំលាក~~ |
| ៧០ | សម្លាក់សំខាន់ | ~~សំលាក់សំខាន់~~ |
| ៧១ | សម្លោក | ~~សំលោក~~ |
| ៧២ | សម្លាញ់ | ~~សំលាញ់~~ |
| ៧៣ | សម្លាប់ | ~~សំលាប់~~ |
| ៧៤ | សម្លិច | ~~សំលិច~~ |
| ៧៥ | សម្លី ឬ សំឡី | ~~សំលី~~ |
| ៧៦ | សម្លឹង | ~~សំលឹង~~ |
| ៧៧ | សម្លុក | ~~សំលុក~~ |
| ៧៨ | សម្លុត | ~~សំលុត~~ |
| ៧៩ | សម្លូត | ~~សំលូត~~ |
| ៨០ | សម្លុយ | ~~សំលុយ~~ |
| ៨១ | សម្លើត | ~~សំលើត~~ |
| ៨២ | សម្លេក | ~~សំលេក~~ |
| ៨៣ | សម្លេច | ~~សំលេច~~ |
| ៨៤ | សំឡាញ | ~~សំលាញ~~ |
| ៨៥ | សំឡេង | ~~សំលេង~~ |
| ៨៦ | សំឡេះ | ~~សំលេះ~~ |
| ៨៧ | សំឡែះ | ~~សំលែះ~~ |
| ៨៨ | ស្រឡក់ | ~~ស្រលក់~~ |
| ៨៩ | ស្រឡប់ | ~~ស្រលប់~~ |

| ល.រ. | **អក្ខរាវិរុទ្ធ ត្រឹមត្រូវតាម វចនានុក្រម ស.ជួន ណាត** | **អក្ខរាវិរុទ្ធ មិនត្រឹមត្រូវ** | ល.រ. | **អក្ខរាវិរុទ្ធ ត្រឹមត្រូវតាម វចនានុក្រម ស.ជួន ណាត** | **អក្ខរាវិរុទ្ធ មិនត្រឹមត្រូវ** | ល.រ. | **អក្ខរាវិរុទ្ធ ត្រឹមត្រូវតាម វចនានុក្រម ស.ជួន ណាត** | **អក្ខរាវិរុទ្ធ មិនត្រឹមត្រូវ** |
|---|---|---|---|---|---|---|---|---|
| ៩០ | ស្រឡាង | ~~ប្រឡាង~~ | ៩៤ | ស្រឡេត | ~~ប្រឡេត~~ | ៩៨ | ស្រឡៅ | ~~ប្រឡៅ~~ |
| ៩១ | ស្រឡិត | ~~ប្រឡិត~~ | ៩៥ | ស្រឡៃ | ~~ប្រឡៃ~~ | ៩៩ | ស្រឡំ | ~~ប្រឡំ~~ |
| ៩២ | ស្រឡើ | ~~ប្រឡើ~~ | ៩៦ | ស្រឡោកោ | ~~ប្រឡោកោ~~ | ១០០ | ស្រឡាំងកាំង | ~~ប្រឡាំងកាំង~~ |
| ៩៣ | ស្រឡើកើ | ~~ប្រឡើកើ~~ | ៩៧ | ស្រឡោច | ~~ប្រឡោច~~ | | | |

# គោលការណ៍បង្កើតពាក្យ

**បុព្វយោគ** :

- *គោលការណ៍បង្កើតពាក្យ*, *គោលការណ៍កម្ចីពាក្យ* ,... ខាងក្រោមនេះ ត្រូវបានស្នើឡើងដោយ *គណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ* នៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.)។ សំណើនេះត្រូវបាន ពិនិត្យ បន្ថែមបន្ថយខ្លះៗ កែសម្រួល និង អនុម័ត ពីថ្ងៃពុធ ០១-០៤-០៩ ដល់ថ្ងៃពុធ ២៧-០៥-០៩។
- នៅសម័យប្រជុំលើកទី១ (ថ្ងៃពុធ ០១-០៤-០៩) ប្រធានអង្គប្រជុំបានបញ្ជាក់ថា *គោលការណ៍បង្កើតពាក្យ* ស្នើឡើងនេះ ជាសម្រង់នៃវិធីនៃការបង្កើតពាក្យដែលមានក្នុងភាសាខ្មែរស្រាប់ ប៉ុន្តែ ការបែងចែកនិងការហៅឈ្មោះវិធីខ្លះ ត្រូវបានគណៈ-កម្មការនេះបែងចែកនិងឱ្យឈ្មោះផ្សេងពីសៀវភៅវេយ្យាករណ៍ដែលសាធារណជនធ្លាប់ស្គាល់[១] : សំណើនេះជាការឆ្លុះបញ្ចាំងមួយដ៏មានប្រយោជន៍។ ប្រធានអង្គប្រជុំបានសុំឱ្យគ.ជ.ភ.ខ.ទទួលយកការបែងចែកនិងការហៅឈ្មោះតាមសំណើនេះតាមដែលអាចទទួលយកបាន ប៉ុន្តែ គ.ជ.ភ.ខ.ក៏ត្រូវទទួលស្គាល់ថា វិធីបង្កើតពាក្យជាវិធីដែលមានស្រាប់ក្នុងភាសាខ្មែរ ហើយ អ្នកវេយ្យាករណ៍គ្រាន់តែ វិភាគ ដកស្រង់ បែងចែក និង ឱ្យឈ្មោះ តាមទស្សនៈរបស់ខ្លួនប៉ុណ្ណោះ។ អ្នកធ្វើវេយ្យាករណ៍អាចស្រង់និងបែងចែកវិធីនៃការបង្កើតពាក្យបែបណាៗ តាមដែលអាចធ្វើបាន ឱ្យតែវិធីនោះពិតជាមានក្នុងភាសា ប្រហាក់ប្រហែលនឹងអ្នកធ្វើវចនានុក្រមដែរ ដែលអាចពន្យល់យ៉ាងណាៗតាមសុភនិច្ឆ័យនិងសមត្ថភាពរបស់ខ្លួន ឱ្យតែពាក្យទាំងប៉ុន្មានពិតជាមានក្នុងភាសា និង ឱ្យតែខ្លួនគោរពអក្ខរាវិរុទ្ធរបស់ជាតិ។

នៅពេលបច្ចុប្បន្ននេះ ការវិវត្តនៃសង្គមនិងវិទ្យាសាស្ត្រ នាំមកនូវបញ្ញត្តិថ្មីៗជាបន្តបន្ទាប់។ ក្រសួង/ស្ថាប័ននីមួយៗតែងតែខិតខំបង្កើតពាក្យទៅតាមតម្រូវការរបស់ខ្លួន។ ហេតុដូច្នេះ ការបង្កើតពាក្យពុំទាន់មានលក្ខណៈឯកភាពគ្នានៅឡើយ។ ដោយចៀសវាងការបង្កើតពាក្យខ្វះឯកភាពគ្នានេះហើយ ទើបគណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យនៃគណៈកម្មា-ធិការជាតិភាសាខ្មែរ លើកជាគោលការណ៍នេះឡើង ដើម្បីរកឯកភាពក្នុងការបង្កើតពាក្យ។

## ១-និយមន័យ

គោលការណ៍បង្កើតពាក្យជាក្បួនទូទៅមួយដែលជួយដល់អ្នកបង្កើតពាក្យឱ្យមានភាពងាយស្រួលក្នុងការបង្កើតពាក្យ

---

[១] ប្លែកពីបច្ចេកសព្ទ *គោលការណ៍បង្កើតពាក្យ* ស្នើដោយ *គណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ* នៃ គ.ជ.ភ.ខ. ជាការវិភាគដែលមានលក្ខណៈជាវេយ្យាករណ៍ : អ្នកវេយ្យាករណ៍/អ្នកភាសាវិទ្យាដែលបានសរសេរសៀវភៅទាក់ទងនឹងការបង្កើតពាក្យប្រាកដជាមានឥទ្ធិពលខ្លាំងនៅក្នុងក្រុម ។

នៅពេលគេប្រឈមនឹងបញ្ញត្តិថ្មីមួយ ។ វាក៏ជាមធ្យោបាយមួយដែលអាចរក្សាបាននូវឯកភាពក្នុងភាសាជាតិផងដែរ ។

ដើម្បីបង្កើតពាក្យ គេត្រូវស្គាល់កត្តាបីធំៗគឺ លក្ខខណ្ឌនៃការបង្កើតពាក្យ វិធីនៃការបង្កើតពាក្យ និង ធាតុដែលត្រូវយកមកប្រើសម្រាប់បង្កើតពាក្យ ។

## ២- លក្ខខណ្ឌនៃការបង្កើតពាក្យ

លក្ខខណ្ឌនេះជាដែនកំណត់ឱ្យមានភាពរលូននៅក្នុងការបង្កើតពាក្យនិងក្នុងការប្រើប្រាស់ពាក្យ ហើយ ក៏អាចរក្សាបាននូវឯកភាពក្នុងភាសាខ្មែរ ។

### ២.១- លក្ខខណ្ឌទីមួយ

ត្រូវបង្កើតពាក្យថ្មី ដើម្បីសម្គាល់តែបញ្ញត្តិថ្មី ។ បញ្ញត្តិថ្មីជាបញ្ញត្តិដែលគេមិនធ្លាប់ស្គាល់ឬមិនទាន់មានពាក្យដើម្បីសម្គាល់វា ។ ក្នុងក្របខ័ណ្ឌនេះ យើងមិនត្រូវបង្កើតពាក្យថ្មីដើម្បីសម្គាល់បញ្ញត្តិដែលមានពាក្យសម្រាប់ហៅរួចមកហើយនោះឡើយ បើពុំនោះសោតទេ វានឹងបង្កឱ្យមានការខ្វះឯកភាពនៅក្នុងភាសាខ្មែរ ។

ឧទាហរណ៍ ពាក្យ *វាទករ*[២] *វាទកាល*[៣] ។ល។ ជាពាក្យថ្មីដែលបានបង្កើតឡើង នាឆ្នាំ១៩៩៣ ដើម្បីសម្គាល់បញ្ញត្តិថ្មី ហើយមាននិយមន័យដូចតទៅ ៖

*វាទករ* គឺជាអ្នកថ្លែងដោយបញ្ជាក់អះអាងពីការពិតនូវអ្វីដែលខ្លួនបានពោល ។ ក្នុងន័យនេះ *វាទករ* មិនមែនគ្រាន់តែជាអ្នកនិយាយឬអ្នកពោលតែប៉ុណ្ណោះទេ ។ រីឯ *វាទកាល* គឺជាកាលនៃវាទកម្ម ដែលជាគោលធៀបនៃការថ្លែងរបស់វាទករពោលគឺ អ្នកនិយាយដែលអះអាងនិងធានាពីសច្ចភាពនៃសម្ដីឬសុន្ទរកថារបស់ខ្លួន ។ វាទកាលនេះតែងតែមានជានិច្ច នៅរាល់ពេលដែលមានវាទកម្មមួយកើតឡើង ប៉ុន្តែ វាទកាលនីមួយៗមិនដូចគ្នាទេ ហើយ វាក៏មិនអាចលេចជារូបរាងឡើងបាន តាមរយៈពាក្យណាមួយឡើយ ។

### ២.២- លក្ខខណ្ឌទីពីរ

អាចបង្កើតពាក្យថ្មី ដើម្បីសម្គាល់បញ្ញត្តិចាស់ តែក្នុងករណីដែលបច្ចេកសព្ទចាស់មានបញ្ហា ។ ឧទាហរណ៍ គេអាចបង្កើតពាក្យ *ធ្នាក់* ដើម្បីជំនួសពាក្យ *អាយតនិបាត* ព្រោះពាក្យ *អាយតនិបាត* ជាពាក្យបាលីដែលមានលក្ខណៈវែងនិងពិបាកយល់ ។ល។ ហើយពាក្យថ្មីមានសុក្រឹតភាពជាង ។ ម្យ៉ាងទៀត នៅក្នុងស្នាដៃស្ដីពីវេយ្យាករណ៍អន្តរកម្មនិយម គេបានបង្កើតបច្ចេកសព្ទ *ឯកតភាព* ដើម្បីជំនួសបច្ចេកសព្ទ *ឯកវចនៈ* ព្រោះបច្ចេកសព្ទចាស់ *ឯកវចនៈ* មិនសម្គាល់បញ្ញត្តិដែលមាននៅក្នុងការសិក្សាពីនាមសព្ទខ្មែរនោះទេ ។ ដោយហេតុនេះហើយបានជានៅក្នុងភាសាខ្មែរ យើងគ្មានឈ្នាក់វេយ្យាករណ៍ដើម្បីបញ្ជាក់ពីវចនៈរបស់នាមនោះទេ ។

ប្រការនេះបណ្ដាលមកពីនាមខ្មែរគ្មានវចនៈ ហើយ អ្វីដែលគេយល់ច្រឡំថាជាឯកវចនៈនោះ តាមពិតទៅ វាគ្រាន់តែជាបញ្ញត្តិមួយទាក់ទងទៅនឹងចំនួនដែលបញ្ជាក់ពីភាពមានមួយឯកតា ហើយដែលគេហៅថា *ឯកតភាព* ។

### ២.៣- លក្ខខណ្ឌទីបី

ការបង្កើតពាក្យត្រូវធ្វើឡើងតាមរយៈវិធីណាមួយក្នុងចំណោមវិធីទាំងអស់របស់ខ្មែរ ដែលមានភាពសមស្របជាងគេបំផុតទៅនឹងតម្រូវការជាក់ស្ដែង ។

---

[២] ការបង្កើតពាក្យនេះគឺដើម្បីសម្គាល់បញ្ញត្តិមួយដែលគេហៅជាភាសាបារាំងថា *énonciateur* ។

[៣] ពាក្យ *វាទកាល* នេះត្រូវបានបង្កើតឡើងដើម្បីសម្គាល់បញ្ញត្តិមួយទៀតដែលភាសាបារាំងហៅថា *temps de l’énonciation* ។

យើងត្រូវខិតខំជ្រើសរើសយកវិធីណាមួយដែលមានសុក្រឹតភាពជាង និង អាចផ្តល់ជាពាក្យដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់ ។ ម្យ៉ាងទៀត បើសម្រេចជ្រើសរើសយកវិធីណាមួយដែលមានលក្ខណៈសមស្របជាងគេបំផុតមកប្រើដើម្បីបង្កើតពាក្យសម្រាប់សម្គាល់បញ្ញត្តិមួយហើយ មិនគួរគប្បីប្រើវិធីផ្សេងទៀតដើម្បីបង្កើតពាក្យសម្រាប់ហៅបញ្ញត្តិដដែលនោះទៀតទេ ព្រោះវាអាចនាំឱ្យមានបញ្ហានៅក្នុងអក្សរសាស្ត្រជាតិ ។

### ២.៤- លក្ខខណ្ឌទីបួន

ការបង្កើតពាក្យត្រូវឈរលើមូលដ្ឋាននៃវេយ្យាករណ៍មួយច្បាស់លាស់ ដោយអនុលោមទៅតាមគោលការណ៍ន័យ-និយម មានន័យថា ពាក្យដែលបង្កើតមកត្រូវមានន័យច្បាស់លាស់ឬត្រូវសម្គាល់បញ្ញត្តិណាមួយដែលខ្មែរយើងបានជួបប្រទះ ។

## ៣- វិធីបង្កើតពាក្យ

### ៣.១- និយមន័យ

វិធីបង្កើតពាក្យ គឺជាក្បួនដែលបានប្រើរួចមកហើយ ហើយ អាចប្រើបន្តទៅទៀតបាន ដោយអនុលោមទៅតាមភាពសមស្របនៃតម្រូវការចំពោះមុខ ។

### ៣.២- វិធីផ្សេងៗ

យោងលើទម្លាប់និងឯកសារស្រាវជ្រាវ[៤] នានាដែលបានបោះពុម្ពកន្លងមក ខ្មែរមានវិធីច្រើនយ៉ាងក្នុងការបង្កើតពាក្យ ។

វិធីទាំងនោះរួមមានដូចតទៅ ៖

### ៣.២.១- វិធីបន្សំ

#### ៣.២.១.១- និយមន័យ

*វិធីបន្សំ* ជាវិធីបង្កើតពាក្យដោយដាក់ធាតុទាំងអស់បន្តបន្ទាប់គ្នា ហើយ ធាតុទាំងនោះនៅរក្សាទម្រង់រូបសាស្ត្រដើមទាំងស្រុង ។ ឧទាហរណ៍ : *ចុងផ្លូវ ដើមផ្លូវ ដំឡូងដៃខ្លា ផ្ទះថ្ម ទឹកដោះគោ ការងារអនុវត្ត* ។ ល ។

#### ៣.២.១.២- វិធាន

យកពាក្យដែលមានស្រាប់មកធ្វើជាធាតុផ្សំ ដោយដាក់រាយធាតុទាំងនោះជាបន្តបន្ទាប់គ្នា និង ដោយគ្មានការផ្លាស់ប្តូរទម្រង់[៥] រូបសាស្ត្ររបស់ធាតុទាំងនោះឡើយ ។

ឧទាហរណ៍ ការផ្សំពាក្យ *ឪពុក* និង *ធម៌* បង្កើតបានទៅជាពាក្យបន្សំ *ឪពុកធម៌* ដែលធាតុផ្សំ *ឪពុក* និង *ធម៌* របស់វា មិនមានការកែប្រែសំណេរនិងសំណួរ[៦] ឡើយ ។

#### ៣.២.១.៣- ទម្រង់

អាស្រ័យលើទំនាក់ទំនងធាតុរបស់វា ពាក្យបន្សំអាចចែកជាទម្រង់ផ្សេងៗដូចខាងក្រោមនេះ ៖

---

[៤] សូមអាន ច័ន្ទ សំណព្វ ( ២០០៨), ព្រុំ ម៉ល់ ( ២០០៦), យៀង វីរបុត្រ ( ២០០៦), សូ មុយឃៀង ( ១៩៨៥), អៀវ កើស ( ១៩៦៧), កេង វ៉ាន់សាក់ ( ១៩៦៤) ។

[៥] ប៉ុន្តែលក្ខណៈរូបសាស្ត្ររបស់ធាតុផ្សំអាចមានការកែប្រែទៅតាមទម្រង់នៃពាក្យបន្សំ ។ សូមកុំច្រឡំ *ធាតុផ្សំ* ( *ឪពុក* និង *ធម៌* ) នៃពាក្យបន្សំ *ឪពុកធម៌* ទៅនឹងពាក្យ *ឪពុក* និង *ធម៌* ដែលត្រូវយកមកផ្សំដើម្បីបង្កើតជាពាក្យបន្សំ ។ វាមានទម្រង់រូបសាស្ត្រដូចគ្នាមែន តែលក្ខណៈរូបសាស្ត្ររបស់វាអាចដូចឬខុសគ្នា ទៅតាមបរិបទ ។

[៦] លើកលែងតែមានការគោរពទៅតាមច្បាប់ទំនាញសូរ ។

### ៣.២.១.៣.១- ទម្រង់ ស.ប. (ស្នូល-បន្សំ)

ជាទម្រង់មួយដែលគេដាក់ធាតុស្នូលនៅខាងដើម រួចទើបដាក់ធាតុបន្សំជាព្យាង្គ (បន្ត) បន្ទាប់ ។

ឧទាហរណ៍ : ***ស្បែក**គោ **ស្គរ**ខ្មោត **កង់**ឡាន **ផ្ទះ**ថ្ម **ជំឡូង**ឈាមមាន់ **កាហ្វេ**ខ្មៅ **ឆ្អក**ស្នេហាជាតិ **ការងារ**អនុវត្ត **ត្រី**ទឹកសាប* ។ល។

ធាតុដែលសរសេរជិត គឺជាធាតុស្នូល ព្រោះវាជាទម្រង់ន័យគ្រឹះនៃពាក្យបន្សំ ។ *ស្បែកគោ* គឺជាស្បែក មិនមែន គោ ទេ ។ *គោ* គឺជាធាតុបន្សំដែលមានតួនាទីគ្រាន់តែបញ្ជាក់ពីប្រភេទម្យ៉ាងនៃ *ស្បែក* តែប៉ុណ្ណោះ ។ ធាតុនេះ គេអាចលុប ជំនួស ឬ ញែកវាចេញពីធាតុស្នូលបាន ហើយ ការធ្វើបែបនេះមិននាំឱ្យបាត់ទម្រង់ន័យគ្រឹះរបស់ពាក្យបន្សំឡើយ ។

### ៣.២.១.៣.២- ទម្រង់ ប.ស. (បន្សំ-ស្នូល)

ជាទម្រង់មួយដែលគេដាក់ធាតុបន្សំនៅខាងដើម រួចទើបដាក់ធាតុស្នូលជាព្យាង្គ(បន្ត) បន្ទាប់ ។

ឧទាហរណ៍ : *កូន**សោ** មេ**សោ** ចុង**ផ្លូវ** ដើម**ផ្លូវ** លោក**គ្រូ** អ្នក**គ្រូ** ការងារ**អនុវត្តន៍*** (ក្នុងន័យ *ការអនុវត្តការងារ* តែមិនមែនក្នុងន័យ *ការងារដែលបានឬត្រូវអនុវត្ត* នោះទេ ព្រោះក្នុងករណីក្រោយនេះ គេត្រូវសរសេរ *ការងារអនុវត្ត* បែបនេះទៅវិញ) ។

ធាតុសរសេរជិតជាធាតុស្នូល ហើយធាតុផ្សេងទៀតជាធាតុបន្សំ ។ ពាក្យ *លោក**គ្រូ** អ្នក**គ្រូ*** សម្គាល់ពីគ្រូ ។ បើគេលុប ធាតុ *គ្រូ* ចេញពីពាក្យ *លោកគ្រូ* និង *អ្នកគ្រូ* គេនឹងបានពាក្យ *លោក* និង *អ្នក* ដែលមិនសម្គាល់ពីគ្រូទេ ។ ផ្ទុយទៅវិញ បើគេ លុបធាតុ *លោក* និង *អ្នក* វិញនោះ គេបានពាក្យ *គ្រូ* ដែលនៅរក្សាបញ្ញត្តិដើម ។

### ៣.២.១.៣.៣- ទម្រង់ ស.ម. (សមាស)

*ទម្រង់សមាស* ជាទម្រង់មួយដែលទំនាក់ទំនងធាតុរបស់ពាក្យបន្សំមានលក្ខណៈដូចទម្រង់ ប.ស.ផង និង ដូចទម្រង់ ស.ប. ផង ។

ឧទាហរណ៍ : *កងទ័ពព្រៃម៉ៅនិយម លទ្ធិពុទ្ធសាសនា មនុស្សអាត្មានិយម* ។ល។ ពាក្យទាំងនេះមានទម្រង់សមាស ព្រោះបញ្ញត្តិវារួមបង្កើតឡើងដោយធាតុទីមួយ ទីបី និង ទីពីរ ដែលនាំឱ្យគេអាចប្រែរៀងគ្នាថា *កងទ័ពព្រៃដែលចូលចិត្តម៉ៅ លទ្ធិនៃសាសនាព្រះពុទ្ធ* ។

### ៣.២.១.៣.៤- ទម្រង់ ប.គ. (បង្គុំ)

ជាទម្រង់ដែលធាតុរបស់ពាក្យបន្សំមិនចំណុះគ្នា ពោលគឺវាមិនអាចបែងចែកជាធាតុស្នូលឬធាតុបន្សំឡើយ ដោយហេតុថា បើលុបធាតុណាមួយចោលក៏មិនបាន ព្រោះវានាំឱ្យបាត់ទម្រង់ន័យគ្រឹះនៃពាក្យបន្សំ ។

ឧទាហរណ៍ : *ឪពុកម្ដាយ បងប្អូន កូនចៅ* ។ល។ ពាក្យ *បងប្អូន* បញ្ជាក់ពីញាតិមិត្តដែលមានអាយុច្រើននិងតិចជាងវាទករឬអ្នកនិយាយ ។ វាមិនសម្គាល់តែ *បង* ប៉ុណ្ណោះទេ ។ ធាតុ *បង* មិនមែនជាទម្រង់ន័យគ្រឹះនៃពាក្យ *បងប្អូន* ឡើយ ហើយ ធាតុ *ប្អូន* ក៏មិនមែនសម្គាល់ប្រភេទមួយនៃ *បង* ដែរ ។ បើគេលុប ជំនួស ឬ ញែកធាតុ *បង* ឬ *ប្អូន* នោះ គេនឹងបាត់នូវបញ្ញត្តិដើមរបស់ពាក្យ *បងប្អូន* ។

### ៣.២.១.៣.៥- ទម្រង់ ប.ថ. (បន្ថែម)

ជាទម្រង់ដែលធាតុបន្ថែមមានលក្ខណៈជារូបតាដែលគ្មានស្វ័យភាពផ្នែកសម្ព័ន្ធ ហើយ ប្រើដាក់បន្ថែមទៅលើមូលតា

ណាមួយ ។ អាស្រ័យលើទីតាំងនៃធាតុបន្ថែម គេអាចចែកទម្រង់នេះជាពីរបែបគឺ ទម្រង់បន្ថែមដើម និង ទម្រង់បន្ថែមចុង ។

#### ៣.២.១.៣.៥.១- ទម្រង់ ប.ថ.ដ. (បន្ថែមដើម)

ជាទម្រង់នៃពាក្យបន្សំដែលមានធាតុបន្ថែមជាព្យាង្គដើមនៃពាក្យ ។

ឧទាហរណ៍ : ***ការ****រៀនសូត្រ* ***ភាព****អង់អាច* ***សុ****ច្ឆន្ទៈ* ***វិ****សាមញ្ញ* ***អ****គតិ* ។ល។

*ការ ភាព សុ វិ អ* សុទ្ធតែជាធាតុបន្ថែមដែលយើងប្រើដើម្បីធ្វើឱ្យមូលតា ដែលត្រូវប្រើភ្ជាប់ជាមួយវា មានការផ្លាស់ប្តូរប្រភេទពាក្យ (ករណី *ការ ភាព*) ឬ ផ្លាស់ប្តូរកម្រិតគុណធាតុ (ករណី *សុ វិ*) ឬ ផ្លាស់ប្តូរគោលនៃបញ្ញត្តិរបស់មូលតា (ករណី *អ*) ។ បើនៅតែឯង ធាតុបន្ថែមនេះគ្មានឯករាជ្យផ្នែកសម្ព័ន្ធទេ ។

#### ៣.២.១.៣.៥.២- ទម្រង់ ប.ថ.ច. (បន្ថែមចុង)

ជាទម្រង់នៃពាក្យបន្សំដែលមានធាតុបន្ថែមជាព្យាង្គឬធាតុរបស់ព្យាង្គចុងនៃពាក្យ ។

ឧទាហរណ៍ : *កុមា****រា*** *កុមា****រី*** *នាយ****ក*** *នាយិ****កា*** *ឧក្រិដ្ឋ****កម្ម*** *សកល****ភាព*** *សុក្រឹត****ភាព*** ។ល។

ពាក្យ *កុមារា* និង *កុមារី* កើតឡើងដោយការបន្ថែម *ធាតុបន្ថែមចុង* ដែលភាសាបាលីសំស្ក្រឹតហៅថា វិភត្តិ *ា* និង ការន្ត ី បន្ថែមលើមូលតា *កុមារ* ។ ចំណែកពាក្យ *នាយ****ក*** *នាយិ****កា*** *ឧក្រិដ្ឋ****កម្ម*** *សកល****ភាព*** *សុក្រឹត****ភាព*** ក៏សុទ្ធតែកើតឡើងដោយការបន្ថែមធាតុនៅខាងចុងមូលតាដែរ គ្រាន់តែធាតុបន្ថែមនេះមានលក្ខណៈខុសពីវិភត្តិ *ា* និង ការន្ត ី ដែលប្រើបន្ថែមទៅលើពាក្យ *កុមារ* នោះ ។

#### ៣.២.១.៣.៦- កំណត់សម្គាល់ (ក.ស.)

ការស្គាល់យល់ច្បាស់ពីរបៀបប្រើប្រាស់និងមុខងាររបស់ធាតុបន្ថែមទាំងនេះ មានសារៈសំខាន់ណាស់ នៅក្នុងការបង្កើតពាក្យ ។

ធាតុបន្ថែមទាំងអស់គ្មានឯករាជ្យផ្នែកសម្ព័ន្ធទេ ។ គេប្រើវាបានដោយដាក់ភ្ជាប់ទៅនឹងមូលតាណាមួយ ។ វាមានតួនាទីមួយច្បាស់លាស់នៅក្នុងអន្តរកម្មជាមួយមូលតាដែលអាចស្តែងឡើងបានទៅតាមករណីនៃធាតុ[៧] នីមួយៗ ។

## ៣.២.២-វិធីសំយោគ

### ៣.២.២.១- និយមន័យ

ជាវិធីបង្កើតពាក្យសមាសដោយភាគច្រើនមានការរំលាយផ្នែកខ្លះនៃធាតុផ្សំបញ្ចូលគ្នា ។

ឧទាហរណ៍ វិធីផ្សំដែលបង្កើតបានជាពាក្យ *រូបារម្មណ៍* *រាជាណាចក្រ* *យុទ្ធោបករណ៍* *យានដ្ឋាន* ។ល។ គឺជាវិធីសំយោគ ។

### ៣.២.២.២- វិធាន

យកធាតុដែលត្រូវប្រើដើម្បីបង្កើតពាក្យមកធ្វើសំយោគបញ្ចូលគ្នា ដោយអនុលោមទៅតាមក្បួននៃវេយ្យាករណ៍មួយច្បាស់លាស់ ។

ឧទាហរណ៍ ការសំយោគធាតុ *យុទ្ធ* និង *ឧបករណ៍* តម្រូវឱ្យប្តូរ *ឧ* ទៅជា *ោ* ដែលត្រូវយកទៅប្រកបជាមួយនឹងជើងនៃព្យញ្ជនៈ *ធ* ហើយពាក្យសមាសដែលបានមកមានទម្រង់បែបនេះ *យុទ្ធោបករណ៍* ។ ឯការសំយោគធាតុ *រូប* និង *អារម្មណ៍* តម្រូវឱ្យភ្ជាប់ព្យញ្ជនៈ *ប* ទៅនឹង *ា* ដោយតម្រូវឱ្យលុប *អ* ចេញពី *ប* ហេតុនេះ ពាក្យសមាសដែលបានមកត្រូវ

---

[៧] សូមអាន ច័ន្ទ សំណព្វ (២០០៧) ធាតុវេយ្យាករសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ ។

សរសេរជា *រូបារម្មណ៍* បែបនេះ ។

**៣.២.២.៣- កំណត់សម្គាល់** ( សម្រាប់ចំណុច ៣.២.២. ស្ដីពីវិធីសំយោគ )

វិធីសំយោគត្រូវបានយកមកអនុវត្តក្នុងករណីដែលធាតុផ្សំជាធាតុដែលខ្ចីពីបាលីសំស្ក្រឹត ។

យើងមិនអាចហៅវិធីសំយោគនេះថាជា *វិធីសមាស* ទេ ព្រោះវានាំឱ្យច្រឡំថា វាជាវិធីដែលកើតឡើងដោយការសំយោគវិធីច្រើនបញ្ចូលគ្នា។ ម្យ៉ាងទៀត យើងគួរទុកបច្ចេកសព្ទ *វិធីសមាស* នេះសម្រាប់ហៅវិធីបង្កើតពាក្យមួយប្រភេទផ្សេងទៀត ដូចមានបង្ហាញជូននៅខាងក្រោមនេះស្រាប់ ។

## ៣.២.៣-វិធីសមាស

### ៣.២.៣.១- និយមន័យ

*វិធីសមាស* ជាវិធីដែលកើតឡើងដោយការប្រើវិធីពីរឬច្រើនបញ្ចូលគ្នា នៅក្នុងការបង្កើតពាក្យមួយដែលយើងអាចហៅបានថាជាពាក្យ *បន្សំសមាស* ។

ឧទាហរណ៍ ការបង្កើតពាក្យ *សកលភាវូបនីយកម្ម* *សក្តានុពលភាព* គឺកើតឡើងតាមរយៈវិធីសមាស ព្រោះមានការប្រើវិធីបន្សំនិងវិធីសំយោគបញ្ចូលគ្នា។

### ៣.២.៣.២- វិធាន

ប្រើវិធីផ្សេងៗរួមគ្នាដើម្បីបង្កើតពាក្យមួយដែលមានច្រើនព្យាង្គ។

ឧទាហរណ៍ : ការបង្កើតពាក្យ *សកលភាវូបនីយកម្ម* តម្រូវឱ្យមានការអនុវត្តវិធីបន្សំផងនិងវិធីសំយោគផង។ គេផ្សំ *សកល* និង *ភាព* ឱ្យបានទៅជា *សកលភាព* ហើយផ្សំ *ឧប* ជាមួយ *នីយ* និង *កម្ម* ឱ្យបានទៅជា *ឧបនីយកម្ម* រួចគេសំយោគលទ្ធផលទាំងពីរបញ្ចូលគ្នា ពោលគឺ សំយោគ *សកលភាព* និង *ឧបនីយកម្ម* ដោយប្តូរ *ព* ទៅ *វ* និង *ឧ* ទៅស្រៈ ូ ឱ្យកើតបានទៅជាពាក្យ *សកលភាវូបនីយកម្ម* ។

ដូចគ្នាដែរ ការបង្កើតពាក្យ *សក្តានុពលភាព* តម្រូវឱ្យមានការអនុវត្តវិធីសំយោគទៅលើធាតុ *សក្ត* និង *អានុពល* ឱ្យកើតបានទៅជា *សក្តានុពល* ផង និង ក៏តម្រូវឱ្យមានការអនុវត្តវិធីបន្សំធាតុដែលសំយោគបាននោះជាមួយធាតុ *ភាព* ផង។

### ៣.២.៣.៣- កំណត់សម្គាល់

វិធីនេះអាចអនុវត្តបានចំពោះតែការបង្កើតពាក្យខ្លះដែលមានចំនួនព្យាង្គចាប់ពីបីឡើងទៅ។

## ៣.២.៤-វិធីកម្លាយ

### ៣.២.៤.១- និយមន័យ

ជាវិធីបង្កើតពាក្យដោយប្រើផ្នត់មកកម្លាយឫសដើម្បីបង្កើតពាក្យថ្មី។

### ៣.២.៤.២- វិធាន

យកផ្នត់ណាមួយទៅកម្លាយពាក្យឫស ដោយអនុលោមទៅតាមគោលការណ៍នៃការប្រើប្រាស់ផ្នត់ដែលអនុញ្ញាតឱ្យសម្គាល់បញ្ញត្តិដែលចង់បាន។

ជាទូទៅ ផ្នត់ដែក [-ម-] ប្រើសម្រាប់កម្លាយពាក្យឱ្យកើតបានជាពាក្យមួយដែលសម្គាល់មនុស្ស។ ឯផ្នត់ដែក [-ន-] ប្រើសម្រាប់កម្លាយឫសឱ្យបានទៅជានាមសព្ទដែលសម្គាល់ឧបករណ៍ឬសម្គាល់បញ្ញត្តិផ្សេងទៀត។ ល។

ឧទាហរណ៍ គេប្រើផ្នត់ដែក [-ម-] ដើម្បីកម្លាយឫស *ចាំ* ឱ្យកើតបានទៅជាពាក្យ *ឆ្មាំ* ដែលមានន័យថា *អ្នកចាំ* ហើយ ប្រើផ្នត់ដែក [-ន-] ដើម្បីកម្លាយឫស *ជាន់* ឱ្យកើតបានទៅជា ពាក្យ *ឈ្នាន់* ដែលមានន័យថា *ឧបករណ៍សម្រាប់ជាន់*។ ដូចគ្នាដែរ គេអាចបង្កើតពាក្យ *ខ្មាន់* (អ្នកកាន់) *ថ្មើរ* (អ្នកដើរ) *ឆ្នុក* (វត្ថុឬឧបករណ៍សម្រាប់ចុក) *ខ្នើយ* (វត្ថុឬឧបករណ៍សម្រាប់កើយ)[៨] ។

### ៣.២.៤.៣- កំណត់សម្គាល់

ផ្នត់ផ្សេងៗដែលខ្មែរបានប្រើក្នុងការកម្លាយពាក្យរហូតមកដល់បច្ចុប្បន្នកាលនេះ មានពីរប្រភេទគឺ *ផ្នត់ដើម* និង *ផ្នត់-ដែក* ។ ផ្នត់ទាំងពីរប្រភេទនេះមានទម្រង់ជាច្រើន ហើយទម្រង់នីមួយៗមានមុខងារច្បាស់លាស់ក្នុងការកំណត់ពីបញ្ញត្តិនៃពាក្យដែលត្រូវបង្កើត។

## ៣.២.៥-វិធីតម្រាប់សូរ

### ៣.២.៥.១- និយមន័យ

ជាវិធីបង្កើតពាក្យដោយត្រាប់តាមសូរដែលបានឮ។

ឧទាហរណ៍ : *តក់ៗ តឹកកែ ត្រឹមៗ តាវៅ កុកកែកឹត កាក់គីងកាងកឹត* ។ល។

### ៣.២.៥.២- វិធាន

យកសូរដែលឮមកកត់ត្រាបង្កើតជាពាក្យដើម្បីសម្គាល់បញ្ញត្តិដែលកើតមានតាមរយៈសូរនោះ។ ឧទាហរណ៍ : គេច្រើនតែត្រាប់សូរតាមសំឡេងស្រែកឬយំរបស់សត្វ ដើម្បីដាក់ឈ្មោះសត្វនោះ ឬ ក៏ត្រាប់តាមសូរដែលបាតុភូតមួយបង្កឡើងដើម្បីសម្គាល់បាតុភូតនោះ។ ឧទាហរណ៍ *តឹកកែ តក់ៗ ផាំង ត្រឹមៗ ក្ទាំង* ។ល។ សុទ្ធតែជាពាក្យដែលបង្កើតឡើងតាមវិធីតម្រាប់សូរទាំងអស់។

### ៣.២.៥.៣- កំណត់សម្គាល់

ពាក្យតម្រាប់សូរដែលមានលក្ខណៈជាវចនតា ហើយដែលត្រូវបានកត់ត្រាទុកនៅក្នុងវចនានុក្រម ហើយគឺមិនអនុញ្ញាតឱ្យសរសេរប្រែប្រួលទៅតាមសូរដែលឮផ្សេងៗគ្នានោះទេ។ *តឹកកែ តាវៅ* ត្រូវតែសរសេរនិងអានបែបនេះជារៀងដរាបទៅ ទោះបីពេលខ្លះ សត្វទាំងនោះយំឮសូរផ្សេងក៏ដោយចុះ។ ឧទាហរណ៍ : *ផ្គរលាន់គ្រាំៗ ផ្គរលាន់ត្រឹមៗ* ។ល។

ប៉ុន្តែ ចំពោះពាក្យដែលគ្រាន់តែត្រាប់សូរសុទ្ធ ដូចជា *ត្រឹមៗ* ឬ *គ្រាំៗ* គួរទុកលទ្ធភាពឱ្យគេកត់ត្រាសូរទៅតាមអ្វីដែលគេបានឮទៅចុះ។

## ៣.២.៦-វិធីសន្មត

### ៣.២.៦.១- និយមន័យ

*វិធីសន្មត* ជាវិធីមួយនៃការបង្កើតពាក្យដែលគេប្រើនៅពេលដែលគេគ្មានលទ្ធភាពបង្ហាញពីហេតុផល។

ឧទាហរណ៍ : *ទៅ លេង ស លឿង ផង ដាវ* ។ល។

### ៣.២.៦.២- វិធាន

គេសន្មតបង្កើតពាក្យថ្មីមួយដើម្បីសម្គាល់បញ្ញត្តិមួយដែលទើបនឹងជួបប្រទះ ដោយគ្មានលទ្ធភាពបញ្ជាក់ពីហេតុផល

[៨] សូមអានអត្ថបទរបស់លោក សូ មុយឃៀង (១៩៨៥) និង អត្ថបទរបស់សាស្ត្រាចារ្យបណ្ឌិត ព្រុំ ម៉ល់ (២០០៦)។

ស្ដីពីទំនាក់ទំនងរវាងពាក្យដែលបង្កើតមកនិងបញ្ញត្តិនោះទេ ។

### ៣.២.៦.៣- កំណត់សម្គាល់

វិធីនេះ គេច្រើនប្រើនៅសម័យដើម ។ នាពេលឥឡូវនេះ គេកម្រនឹងប្រើណាស់ ។ យើងត្រូវចៀសវាងវិធីនេះ បើអាចធ្វើទៅបាន ព្រោះសម័យបច្ចុប្បន្ន យើងមានពាក្យច្រើនណាស់ដែរហើយ ដែលសមល្មមអាចឱ្យយើងប្រើដើម្បីផ្សំបង្កើតជាពាក្យសម្រាប់សម្គាល់បញ្ញត្តិផ្សេងៗបាន ។

### ៣.២.៧-វិធីរូប-សទ្ទតា [៩]

វិធីរូប-សទ្ទតា ជាលទ្ធផលនៃការបកប្រែស្ទើរតែចំៗពីបច្ចេកសព្ទបារាំងថា procédés morpho-phonologiques គឺពាក្យមួយសងពាក្យមួយ : procédés =វិធី , morpho ( < morphologie) = រូប/រូបតា , phonologiques ( < phonologie) = សទ្ទតា(វិទ្យា) ។ ទាំងក្នុងភាសាបារាំង ទាំងក្នុងភាសាខ្មែរ បច្ចេកសព្ទនេះឥតមានន័យឱ្យគេចាប់បាន ដូចជា *វិធីកម្លាយ* ឬ *វិធីសមាស* ជាដើម នោះឡើយ ។ បច្ចេកសព្ទនេះមានអរូបីកម្មខ្ពស់ទៅលើន័យ បានសេចក្ដីថា ន័យរបស់បច្ចេកសព្ទត្រូវបានគេសន្មតឡើង ប្រហាក់ប្រហែលនឹងន័យនៃពាក្យ atome នៅពេលដំបូងដែលគេដាក់ឱ្យប្រើនោះដែរ ។ នៅក្នុងវិធីនេះ មានការកាត់ពាក្យ (ពាក្យក្រៅ/ក្នុងកន្សោម) ដោយបែបផ្សេងៗ ហើយ គេសម្រួលរូបសាស្ត្រឬទុកដដែល តាមការចាំបាច់ ។ យើងមិនទាន់មានការសិក្សាឱ្យដឹងថា តើភាសាខ្មែរមានប្រើវិធីនេះតាំងពីពេលណាមកនៅឡើយ ។ ចំពោះភាសានៅលោកខាងលិច គេមានភស្តុតាងនៃការប្រើវិធីនេះជាយូរយារមកហើយ ។ ដោយវិធីនេះមានច្រើនបែប និង ដោយភាសាខ្មែរមិនទាន់មានឧទាហរណ៍គ្រប់បែបនៅឡើយ គប្បីយើងយកឧទាហរណ៍ចេញពីភាសាបារាំងនិងអង់គ្លេសផង ដើម្បីបង្គ្រប់បែបទាំងនោះ ។

**៣.២.៧.១- ពាក្យអក្សរកាត់** (sigle) បានពីការរក្សាទុកតែអក្សរទី១ខាងដើមនៃពាក្យនីមួយៗក្នុងកន្សោមពាក្យ, ឧទាហរណ៍ :

- គ.ជ.ភ.ខ. < គណៈកម្មាធិការជាតិភាសាខ្មែរ [១០] ,
- គ.ជ.ប. < គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ,
- ENA < E.N.A. < Ecole Nationale d'Administration,
- CAPES < C.A.P.E.S. < Certificat d'Aptitude Pédagogique à l'Enseignement Secondaire,
- AIDS < A.I.D.S. < Acquired Immuno-Deficient Syndrome,
- Laser < LASER < L.A.S.E.R. < Light Amplification by Simulated Emission of Radiation ។

កំណត់សម្គាល់ : គេអាចបង្កើតពាក្យកម្លាយចេញពីពាក្យអក្សរកាត់ ដោយមានការសម្រួលសូរឬអក្ខរាវិរុទ្ធបន្តិចបន្តួច, ឧទាហរណ៍ :

- Enarque < ENA + arque ,
- capésien < CAPES + ien ,

**៣.២.៧.២- ពាក្យកន្សោមកាត់** : ការកាត់បំភាគ/ពាក្យខាងដើមនៃកន្សោម, ឧទាហរណ៍ :

- La capitale < la ville capitale,
- សមត្ថកិច្ច < អាជ្ញាធរមានសមត្ថកិច្ច ,
- Une Toyota < une voiture Toyota,
- Un sommet < une réunion au sommet ។

**៣.២.៧.៣- ពាក្យកាត់ :**

---

[៩] វិធីនេះត្រូវបានបន្ថែមដោយ គ.ជ.ភ.ខ. ។

[១០] ភាគ/ពាក្យដែលគូសពីក្រោម ជាភាគ/ពាក្យដែលគេរក្សាទុក ។

**៣.២.៧.៣.១- ពាក្យកាត់ខាងចុង,** ឧទាហរណ៍ :

- ឯកឧត្ដមឧប. < ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី ,
- Ciné < cinéma < cinématographie,
- i < il,
- D'acc! < d'accord!,

**៣.២.៧.៣.២- ពាក្យកាត់ខាងដើម,** ឧទាហរណ៍ :

- Bus < autobus,
- Car < autocar, ។

កំណត់សម្គាល់ : គេអាចបង្កើតពាក្យកម្លាយចេញពីពាក្យកាត់ (ទោះពាក្យកាត់នោះមានប្រើឬគ្មានក្នុងភាសាខ្មែរក៏ដោយ) ដោយ ជួនកាល មានការសម្រួលសូរឬអក្ខរាវិរុទ្ធបន្តិចបន្តួច, ឧទាហរណ៍ :

- ស្មេរ[១១] < (សរ)សេរ + [-ម-] ,
- សំណេរ < (សរ)សេរ + [-αmn-][១២] ។

**៣.២.៧.៤ - ពាក្យកាត់ត (acronyme),** ឧទាហរណ៍ :

**៣.២.៧.៤.១ - ការកាត់ប៉ះភាគចុងនៃពាក្យទី១ និង ភាគដើមនៃពាក្យទី២ នៃកន្សោមពាក្យ,** ឧទាហរណ៍ :

- (ច្រក) អធិកិច្ច < (ច្រក) + អាទិភាព + សេដ្ឋកិច្ច
- Stagflation < stagnation + inflation,
- Foultitude < foule + multitude,
- Bit < binary + digit ។

**៣.២.៧.៤.២- ការកាត់អាចប៉ះភាគចុងនៃពាក្យក្នុងកន្សោម,** ឧទាហរណ៍ :

- (ច្រក) អធិទីសែត < (ច្រក) + អាទិភាព + សេដ្ឋកិច្ច,
- Polmar < pollution + maritime,
- Euratom < Europe + atome ។

**៣.២.៧.៤.៣- ការកាត់អាចមានលក្ខណៈល្បាយ អាចប៉ះភាគចុងផងនិងភាគដើមផងនៃពាក្យណាមួយនៃកន្សោម (ឬ លើសពីមួយ) ព្រមទាំងជួនកាលមានប្រើធាតុភ្ជាប់ផ្សេងៗ និង មានការសម្រួលអក្ខរាវិរុទ្ធឬការសម្រួលសូរផងទៀត,** ឧទាហរណ៍ :

- (ភ្នំ) សន្ទុក < (ភ្នំ) អាសន្នទុក្ខ < (ភ្នំ) + អាសន្ន + ទុក្ខ[១៣]
- **Nitan** < nickel + titane,
- Nitinol < nitanol < **nitan** + ol (nita- > niti- , nitinol ជាលោហៈសំយោគ (alliage) មួយបែប ។)

---

[១១] - ពាក្យ *ស្មេរ* ឬ *សំណេរ* អាចចាត់ទុកថាជាពាក្យកើតពី *សរសេរ* ដែលគេបានកាត់ភាគដើមចេញ ។

[១២] - អ្នកខ្លះយល់ថា ភាសាខ្មែរឥតមានអន្តេបទ[-αmn-/-□mn-]ទេ មានតែ [-αm-/-□m-] : ដូច្នេះពាក្យ *ចំណូល* ត្រូវឆ្លងតាមពាក្យ ⋆*ឆ្នូល* សិន (បញ្ហាចម្រូងចម្រាសបែបនេះ ត្រូវអ្នកភាសាវិទ្យាស្រាវជ្រាវ ពិគ្រោះពិភាក្សាគ្នា តទៅទៀត) ។

[១៣] - ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម យល់ថា *ភ្នំសន្ទុក* មិនកើតចេញពី "ភ្នំអាសន្នទុក្ខ" ទេ ពីព្រោះ "អាសន្នទុក្ខ" ជាកន្សោមឥតទំនងប្រឌិតឡើងដើម្បីសម្រេចបំណង ។

## ៤- ធាតុសម្រាប់បង្កើតពាក្យ

### ៤.១- និយមន័យ

ធាតុជាឯកតាភាសា ( *សទ្ទតា រូបតា ពាក្យ* ) ។ល។ ដែលប្រើដើម្បីបង្កើតពាក្យ ។

ឧទាហរណ៍ :

- *បង* និង *ប្អូន* ជាធាតុដែលប្រើបង្កើតពាក្យ *បងប្អូន* ។
- ផ្នត់ដើម [ក-] និង ពាក្យឫស *ចាំង* ជាធាតុដែលប្រើសម្រាប់បង្កើតពាក្យ *ក្បាំង* ។

### ៤.២- ប្រភេទធាតុ

ជាទូទៅ ធាតុប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរច្រើនមានប្រភពមកពីភាសាខ្មែរ-មន និង ពីភាសាបាលីសំស្ក្រឹត ។ មានធាតុមួយចំនួនតូចដែលជាពាក្យខ្ចីពីភាសានៃប្រទេសជិតខាង និង ពីប្រទេសដែលធ្លាប់មានទំនាក់ទំនងជាមួយខ្មែរ ។

អាស្រ័យលើលក្ខណៈសម្ព័ន្ធ មុខងារ និង តួនាទីរបស់វា ធាតុដែលខ្មែរប្រើសម្រាប់បង្កើតពាក្យមានច្រើនប្រភេទ ហើយវាបានផ្តល់លទ្ធភាពគ្រប់បែបយ៉ាងដែលអាចឱ្យយើងបង្កើតពាក្យបានតាមតម្រូវការ ។

( សូមអានសេចក្តីពន្យល់ពីលក្ខណៈធាតុមួយចំនួនដែលបានចុះផ្សាយក្នុងទស្សនាវដ្តី*សង្គមសាស្ត្រនិងមនុស្សសាស្ត្រ* លេខ៥៧) ។

### ៤.៣- បម្រើបម្រាស់ធាតុ

ការប្រើប្រាស់ធាតុខ្ចីពីបរទេសមកផ្សំបង្កើតជាពាក្យ ជាអាទិ៍ ធាតុខ្ចីពីបាលីសំស្ក្រឹតដែលមានប្រើយុគលពិន្ទុ គេអនុវត្តអក្ខរាវិរុទ្ធ ដូចខាងក្រោម៖

- *ករណីទីមួយ* កាលណាព្យាង្គចុងនៃពាក្យ អានឮសូរ *អាក់* ឬ *អ៊ាក់* គេត្រូវរក្សាទុកយុគលពិន្ទុនៅក្នុងសំណេរពាក្យ ។
  ឧទាហរណ៍ : *លក្ខណៈ សុខៈ ពលៈ បដិភាណៈ សួនសាធារណៈ* ។ល។
- *ករណីទីពីរ* កាលណាពាក្យដែលមានប្រើយុគលពិន្ទុចូលផ្សំនិងពាក្យបាលីដទៃទៀត ហើយវាក្លាយទៅជាធាតុបន្ទំ ពោលគឺធាតុដែលមិនសម្គាល់ទម្រន័យគ្រឹះនៃពាក្យបន្សំ នោះយុគលពិន្ទុមិនត្រូវរំលេចក្នុងផ្នែកសំណេរនោះទេ ។
  ឧទាហរណ៍ : *លក្ខណសម្បត្តិ វីរភាព គណបក្ស សារប្រយោជន៍* ។ល។
- *ករណីទីបី* កាលណាពាក្យដែលមានប្រើយុគលពិន្ទុចូលផ្សំនឹងពាក្យបាលីដទៃទៀត ហើយវាក្លាយទៅជាធាតុស្នូល ពោលគឺធាតុដែលសម្គាល់ទម្រន័យគ្រឹះនៃពាក្យបន្សំ នោះយុគលពិន្ទុត្រូវតែរំលេចចេញក្នុងផ្នែកសំណេរ ។
  ឧទាហរណ៍ : *អាសនៈសភា លក្ខណៈវិនិច្ឆ័យ* ។ល។
- *ករណីទីបួន* កាលណាពាក្យដែលមានប្រើយុគលពិន្ទុចូលផ្សំនឹងពាក្យបាលីដទៃទៀតដែលមានប្រើយុគលពិន្ទុ ហើយវាក្លាយទៅជាធាតុបង្គុំ ពោលគឺជាធាតុដែលសុទ្ធមិនសម្គាល់ទម្រន័យគ្រឹះនៃពាក្យបន្សំ នោះយុគលពិន្ទុត្រូវតែរំលេចចេញក្នុងផ្នែកសំណេរ ។ ឧទាហរណ៍ : *កាលៈទេសៈ* ។
- *ករណីទីប្រាំ* កាលណាពាក្យដែលមានប្រើយុគលពិន្ទុចូលផ្សំនឹងពាក្យខ្មែរ នោះយុគលពិន្ទុត្រូវតែរំលេចចេញក្នុងផ្នែកសំណេរ ។ ឧទាហរណ៍ : *សារៈសំខាន់* ។

### ៤.៤- លក្ខខណ្ឌនៃការជ្រើសរើសធាតុក្នុងការបង្កើតពាក្យ

ដើម្បីអភិរក្សភាសាខ្មែរនិងអត្តសញ្ញាណជាតិ យើងត្រូវគោរពទៅវលក្ខខណ្ឌដូចតទៅ៖

### ៤.៤.១- លក្ខខណ្ឌទីមួយ

ត្រូវប្រើប្រាស់ជាចម្បងនិងឱ្យអស់ពីលទ្ធភាពនូវធាតុដែលមានលក្ខណៈជាខ្មែរ-មន។

### ៤.៤.២- លក្ខខណ្ឌទីពីរ

ប្រើប្រាស់ធាតុបាលីសំស្ក្រឹតបែបខ្មែរក្នុងករណីចាំបាច់ឬក្នុងករណីដែលធាតុខ្មែរ-មនមិនអាចយកមកប្រើបាន។

### ៤.៤.៣- លក្ខខណ្ឌទីបី

រក្សាទម្លាប់ល្អដែលមានកន្លងមក ដោយបន្តមិនប្រើប្រាស់ធាតុដែលមានក្នុងភាសាដទៃទៀត ក្រៅពីភាសាខ្មែរ-មន និង បាលីសំស្ក្រឹត លើកលែងតែក្នុងករណីខានមិនបាន ដូចមាននៅក្នុងឧទាហរណ៍ខាងក្រោមនេះ។

ឧទាហរណ៍ : *ទូកម៉ាស៊ីន ទឹកតែ មីឆា ស៊ុបគោ រ៉ឺម៉កម៉ូតូ មីក្រូសេដ្ឋកិច្ច ម៉ាក្រូសេដ្ឋកិច្ច* ។ល។

## គោលការណ៍កម្ចីពាក្យ

### ១- និយមន័យ

### ១.១- និយមន័យនៃគោលការណ៍កម្ចីពាក្យ

គោលការណ៍កម្ចីពាក្យ ជាក្បួនទូទៅមួយដែលជួយដល់អ្នកបច្ចេកទេសឱ្យបានដឹងពីព្រំដែននៃកម្ចីពាក្យ។ គោល-ការណ៍នេះនឹងផ្តល់នូវលទ្ធភាពក្នុងការខ្ចីពាក្យពីភាសាបរទេសមកប្រើប្រាស់ផង និង ផ្តល់នូវលក្ខខណ្ឌដើម្បីរក្សាឱ្យបាននូវអត្ត-សញ្ញាណភាសាខ្មែរផង។

### ១.២- និយមន័យនៃពាក្យកម្ចី

*ពាក្យកម្ចី* គឺជាពាក្យដែលខ្មែរខ្ចីពីភាសាបរទេស ដោយនាំយកមកជាមួយទាំងដុលឬដោយអន្លើនូវបញ្ញត្តិដែលពាក្យបរទេសនោះសម្គាល់ ហើយ ដែលខ្មែរមិនទាន់មានពាក្យឬមិនអាចបង្កើតពាក្យមកសម្គាល់បញ្ញត្តិនោះបាន។

ឧទាហរណ៍ : *សាមញ្ញ វិជ្ជា ស៊ីម៉ងត៍ ម៉ូតូ កុំព្យូទ័រ* ។ល។

### ២- លក្ខខណ្ឌនៃកម្ចីពាក្យ

ដើម្បីបន្តអភិរក្សភាសាខ្មែរនិងរក្សាឱ្យបាននូវចីរភាពនៃគំនិតច្នៃប្រឌិតរបស់បុព្វបុរសខ្មែរ ការខ្ចីពាក្យពីភាសាបរទេសមកប្រើក្នុងភាសាខ្មែរទំនើប ត្រូវគោរពតាមគោលការណ៍ដូចតទៅនេះ៖

### ២.១- លក្ខខណ្ឌទីមួយ

អាចខ្ចីពាក្យពីបរទេសមកប្រើតែក្នុងករណីដែលមិនអាចបង្កើតពាក្យក្នុងភាសាខ្មែរ ដើម្បីសម្គាល់បញ្ញត្តិដែលមាននៅក្នុងភាសាបរទេសនោះបាន។

ឧទាហរណ៍ : *ស៊ីម៉ងត៍ អេតចាយ កាហ្វេ តែ* ។ល។

### ២.២- លក្ខខណ្ឌទីពីរ

អាចខ្ចីពាក្យពីបរទេសមកប្រើបានតែក្នុងករណីដែលការបង្កើតពាក្យក្នុងភាសាខ្មែរអាចធ្វើទៅបានដែរ តែវាចោទជាបញ្ហា ដូចជាវែងពេក ពិបាកអាន ពិបាកយល់ន័យ មិនចំន័យ ឬ មានន័យខុសពីពាក្យដើម។ល។

### ២.៣- លក្ខខណ្ឌទីបី

ហាមមិនឱ្យខ្ចីពាក្យពីភាសាបរទេសមកប្រើជំនួសពាក្យដែលមានក្នុងភាសាខ្មែររួចហើយ។ <u>ឧទាហរណ៍</u> មិនត្រូវខ្ចីពាក្យ *ស៊ីញ៉ៅ កុងត្រា លីង សៀវ៉ៃយ៉ង់ កុងត្រូល័រ* ។ល។ មកប្រើជំនួសរៀងគ្នាឱ្យពាក្យ *(ចុះ)ហត្ថលេខា កិច្ចសន្យា ខ្មៅ អនុរក្ស អប្បមាទ* ។ល។ ដែលខ្មែរបានប្រើរួចមកហើយនោះទេ ទោះបីពាក្យនេះជាពាក្យកម្ចីពីភាសាបរទេសដែរក៏ដោយចុះ។

### ២.៤- លក្ខខណ្ឌទីបួន

ត្រូវព្យាយាមខ្ចីពាក្យពីភាសានៃប្រទេសដែលស្ថិតនៅឆ្ងាយពីប្រទេសខ្មែរ ហើយដែលគ្មានចេតនាសាបព្រោះឥទ្ធិពលមកលើភាសាវប្បធម៌ និង អត្តសញ្ញាណកម្មខ្មែរ ទោះក្នុងកាលៈទេសៈណាក៏ដោយ។

### ២.៥- លក្ខខណ្ឌទីប្រាំ

កម្ចីពាក្យត្រូវឈរលើមូលដ្ឋានសម្របសម្រួលផ្នែកសំណេរនិងសំណួរដែលមានលក្ខណៈជាឡាតាំងបែបខ្មែរ[១៤] ទោះបីជា ពាក្យទាំងនោះមានប្រភព (យោងលើលក្ខខណ្ឌទីបួនផង) មកពីភាសាណាក៏ដោយ។

## <u>ជម្រើសរវាងការបង្កើតពាក្យនិងកម្ចីពាក្យ</u>

នៅពេលជួបប្រទះនឹងបញ្ញត្តិថ្មី តាមរយៈការស្រាវជ្រាវនិងការបកប្រែ គួរមានទម្លាប់រិះរកបង្កើតពាក្យឱ្យអស់លទ្ធភាពសិនមុននឹងខ្ចីពាក្យពីភាសាបរទេស។ ក្នុងស្មារតីនេះ យើងត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដែលមានចែងបន្ទាប់ពីនិយមន័យខាងក្រោមនេះ។

### ១- និយមន័យ

*ជម្រើស* ពុំមែនជាទ្វេបថដែលមានន័យថាយកគោលការណ៍ណាមួយណាក៏បាននោះទេ តែវាប្រើក្នុងន័យតម្រូវឱ្យជ្រើសរើសយកគោលការណ៍ណាមួយក្នុងចំណោមការបង្កើតពាក្យនិងកម្ចីពាក្យដែលសមស្របទៅនឹងភាពចាំបាច់បំផុត។

### ២- លក្ខខណ្ឌ

ជាចំណងមួយដែលមិនអនុញ្ញាតឱ្យប្រើគោលការណ៍បង្កើតពាក្យឬគោលការណ៍កម្ចីពាក្យតាមតែចិត្តចង់បាននោះទេ។

### ២.១- លក្ខខណ្ឌទីមួយ

ផ្តល់អាទិភាពទៅលើការបង្កើតពាក្យជាជាងកម្ចីពាក្យមកប្រើភ្លាមៗ។ លក្ខខណ្ឌនេះមានបំណងអភិរក្សភាសាខ្មែរ និង ទប់ស្កាត់ឥទ្ធិពលពីភាសាដទៃ។

### ២.២- លក្ខខណ្ឌទីពីរ

អាចអនុវត្តគោលការណ៍កម្ចីពាក្យបាន តែក្នុងករណីដែលការបង្កើតពាក្យមិនអាចធ្វើទៅបាន។

### ២.៣- លក្ខខណ្ឌទីបី

---

[១៤] មិនត្រូវអនុវត្តប្រព័ន្ធអំណានសូរនៃពាក្យកម្ចីតាមបែបអង់គ្លេសទេ ព្រោះវាមានបម្រែបម្រួលភាពច្រើនទៅតាម អំណានអាមេរិកាំង អង់គ្លេស អូស្ត្រាលី ឬ អាស៊ី។ ម្យ៉ាងទៀត មិនគួរប្រឹងអានកាច់សូរឱ្យដូចទាំងស្រុងទៅនឹងភាសាបារាំងឬភាសាបរទេសណាមួយនោះទេ។ <u>ឧទាហរណ៍</u> ពាក្យអង់គ្លេស *computer* មកប្រើ ខ្មែរអាន*កុំព្យូទ័រ* តាមឡាតាំងបែបខ្មែរ តែគេមិនអានដូចពាក្យអង់គ្លេស *ខំព្យូថឺ* ឬ តាមឡាតាំង *កុំពុយតឺ កុំពុយតេ កុំពុយទ័* នោះទេ។

អាចអនុញ្ញាតឱ្យខ្ចីពាក្យមកប្រើភ្លាមៗ តែក្នុងករណីចាំបាច់ជាបន្ទាន់ដែលការបង្កើតពាក្យដើម្បីយកមកបកប្រែពាក្យបរទេសមិនអាចធ្វើទាន់តាមតម្រូវការ។ ប៉ុន្តែ មិនត្រូវបញ្ចូលពាក្យទាំងនោះទៅក្នុងវចនានុក្រមភ្លាមៗទេ ដោយទុកប្រើជាបណ្ដោះអាសន្នសិន ហើយត្រូវខំបង្កើតពាក្យក្នុងគ្រាបន្ទាប់ដ៏ខ្លីដើម្បីបកប្រែពាក្យនោះជាភាសាជាតិវិញ។

**២.៤- លក្ខខណ្ឌទីបួន**

ផ្តល់អាទិភាពទៅឱ្យការអនុវត្តគោលការណ៍កម្ចីពាក្យតែនៅក្នុងវិស័យវិទ្យាសាស្ត្រពិត ហើយខំចៀសវាងកម្ចីពាក្យក្នុងវិស័យភាសាវិទ្យា អក្សរសាស្ត្រ អក្សរសិល្ប៍ វប្បធម៌ ដើម្បីថែរក្សានិងអភិរក្សអត្តសញ្ញាណកម្មជាតិខ្មែរ។

**២.៥- លក្ខខណ្ឌទីប្រាំ**

មិនត្រូវបង្កើតពាក្យថ្មីមកជំនួសពាក្យកម្ចីដែលមានប្រើយូរមកហើយនោះទេ។

ឧទាហរណ៍ មិនត្រូវខិតខំបង្កើតពាក្យថ្មី ដើម្បីជំនួសពាក្យ *គោ* ដែលខ្មែរខ្ចីពីបាលីសំស្ក្រឹតយូរមកហើយនោះឡើយ ហើយ ក៏មិនត្រូវស្វែងរកបង្កើតពាក្យថ្មីមកជំនួសពាក្យ *ស៊ីម៉ងត៍* ដែលខ្មែរខ្ចីពីបារាំងយូរមកហើយនោះដែរ។

**២.៦- លក្ខខណ្ឌទីប្រាំមួយ**

ជម្រើសរវាងការបង្កើតពាក្យនិងកម្ចីពាក្យ ត្រូវអនុវត្តចំពោះករណីដែលត្រូវសម្គាល់បញ្ញត្តិថ្មីតែប៉ុណ្ណោះ។ បើយើងជ្រើសយកការបង្កើតពាក្យមកអនុវត្តហើយ ហាមខ្ចីពាក្យបរទេសមកប្រើដើម្បីសម្គាល់បញ្ញត្តិដដែលនោះទៀត។ ផ្ទុយទៅវិញ បើខ្ចីពាក្យពីភាសាបរទេសមកប្រើជាអចិន្ត្រៃយ៍ហើយ ហាមមិនឱ្យបង្កើតពាក្យមកជំនួសពាក្យកម្ចីនោះឡើយ។

# មាតិកា
## នៃ
## គោលការណ៍បង្កើតពាក្យ

**ចំណងជើង** **ទំព័រ**


១- និយមន័យ ........ ១៦
២- លក្ខខណ្ឌនៃការបង្កើតពាក្យ ........ ១៧
២.១- លក្ខខណ្ឌទីមួយ ........ ១៧
២.២- លក្ខខណ្ឌទីពីរ ........ ១៧
២.៣- លក្ខខណ្ឌទីបី ........ ១៧
២.៤- លក្ខខណ្ឌទីបួន ........ ១៨
៣- វិធីបង្កើតពាក្យ ........ ១៨
៣.១- និយមន័យ ........ ១៨
៣.២- វិធីផ្សេងៗ ........ ១៨

៣.២.១-វិធីបន្សំ ....... ១៨
៣.២.១.១- និយមន័យ ....... ១៨
៣.២.១.២- វិធាន ....... ១៨
៣.២.១.៣- ទម្រង់ ....... ១៨
៣.២.១.៣.១- ទម្រង់ ស.ប. (ស្នូល-បន្សំ) ....... ១៨
៣.២.១.៣.២- ទម្រង់ ប.ស. (បន្សំ-ស្នូល) ....... ១៩
៣.២.១.៣.៣- ទម្រង់ ស.ម. (សមាស) ....... ១៩
៣.២.១.៣.៤- ទម្រង់ ប.គ. (បង្គុំ) ....... ១៩
៣.២.១.៣.៥- ទម្រង់ ប.ថ. (បន្ថែម) ....... ១៩
៣.២.១.៣.៥.១- ទម្រង់ ប.ថ.ដ. (បន្ថែមដើម) ....... ២០
៣.២.១.៣.៥.២- ទម្រង់ ប.ថ.ច. (បន្ថែមចុង) ....... ២០
៣.២.១.៣.៦- កំណត់សម្គាល់ (ក.ស.) ....... ២០
៣.២.២-វិធីសំយោគ ....... ២០
៣.២.២.១- និយមន័យ ....... ២០
៣.២.២.២- វិធាន ....... ២០
៣.២.២.៣- កំណត់សម្គាល់ ....... ២១
៣.២.៣-វិធីសមាស ....... ២១
៣.២.៣.១- និយមន័យ ....... ២១
៣.២.៣.២- វិធាន ....... ២១
៣.២.៣.៣- កំណត់សម្គាល់ ....... ២១
៣.២.៤-វិធីកម្ចាយ ....... ២១
៣.២.៤.១- និយមន័យ ....... ២១
៣.២.៤.២- វិធាន ....... ២១
៣.២.៤.៣- កំណត់សម្គាល់ ....... ២២
៣.២.៥-វិធីតម្រាប់សូរ ....... ២២
៣.២.៥.១- និយមន័យ ....... ២២
៣.២.៥.២- វិធាន ....... ២២
៣.២.៥.៣- កំណត់សម្គាល់ ....... ២២
៣.២.៦- វិធីសន្ធត ....... ២២
៣.២.៦.១- និយមន័យ ....... ២២

៣.២.៦.២- វិធាន ..........២២
៣.២.៦.៣- កំណត់សម្គាល់ ..........២៣
៣.២.៧- វិធីរូប-សទ្ទតា ..........២៣
៣.២.៧.១- ពាក្យអក្សរកាត់ (sigle) ..........២៣
៣.២.៧.២- ពាក្យកន្សោមកាត់ ..........២៣
៣.២.៧.៣- ពាក្យកាត់ : ..........២៣
៣.២.៧.៣.១- ពាក្យកាត់ខាងចុង ..........២៤
៣.២.៧.៣.២- ពាក្យកាត់ខាងដើម ..........២៤
៣.២.៧.៤ - ពាក្យកាត់ត (acronyme) ..........២៤
៣.២.៧.៤.១ - ការកាត់ប៉ះភាគចុងនៃពាក្យទី១ និង ភាគដើមនៃពាក្យទី២ នៃកន្សោមពាក្យ ..........២៤
៣.២.៧.៤.២- ការកាត់អាចប៉ះភាគចុងនៃពាក្យក្នុងកន្សោម ..........២៤
៣.២.៧.៤.៣- ការកាត់អាចមានលក្ខណៈល្បាយ ..........២៤
៤- ធាតុសម្រាប់បង្កើតពាក្យ ..........២៥
៤.១- និយមន័យ ..........២៥
៤.២- ប្រភេទធាតុ ..........២៥
៤.៣- បម្រើបម្រាស់ធាតុ ..........២៥
៤.៤- លក្ខខណ្ឌនៃការជ្រើសរើសធាតុក្នុងការបង្កើតពាក្យ ..........២៥
៤.៤.១- លក្ខខណ្ឌទីមួយ ..........២៦
៤.៤.២- លក្ខខណ្ឌទីពីរ ..........២៦
៤.៤.៣- លក្ខខណ្ឌទីបី ..........២៦

## គោលការណ៍កម្មីពាក្យ

១- និយមន័យ ..........២៦
១.១-និយមន័យនៃគោលការណ៍កម្មីពាក្យ ..........២៦
១.២-និយមន័យនៃពាក្យកម្មី ..........២៦
២- លក្ខខណ្ឌនៃកម្មីពាក្យ ..........២៦
២.១- លក្ខខណ្ឌទីមួយ ..........២៦
២.២- លក្ខខណ្ឌទីពីរ ..........២៧
២.៣- លក្ខខណ្ឌទីបី ..........២៧

២.៤- លក្ខខណ្ឌទីបួន ..... ២៧

២.៥- លក្ខខណ្ឌទីប្រាំ ..... ២៧

## ៦.ម៉្យីសរទោខការបង្កើតពាក្យនិខកម្ទីពាក្យ

១- និយមន័យ ..... ២៧

២- លក្ខខណ្ឌ ..... ២៧

២.១- លក្ខខណ្ឌទីមួយ ..... ២៧

២.២- លក្ខខណ្ឌទីពីរ ..... ២៧

២.៣- លក្ខខណ្ឌទីបី ..... ២៧

២.៤- លក្ខខណ្ឌទីបួន ..... ២៨

២.៥- លក្ខខណ្ឌទីប្រាំ ..... ២៨

២.៦- លក្ខខណ្ឌទីប្រាំមួយ ..... ២៨

## បច្ចេកសព្ទរបស់គណៈកម្មការ វិទ្យាសាស្ត្រនយោបាយ និង ការទូត
## ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| ១- **កលិយុគនយោបាយ**<br>អ. political trouble<br>បា. trouble politique | ស្ថានភាពចលាចលជ្រួលច្របល់វឹកវរ ខាងផ្នែកនយោបាយដែលបង្កឱ្យមានបញ្ហាអស្ថិរភាព យ៉ាងធ្ងន់ធ្ងរនៅក្នុងសង្គម ។<br>ឧ. កលិយុគនយោបាយសម័យលង្វែក ក្នុងរជ្ជកាលព្រះសត្ថាទី១ដែលបង្កដោយទំនាស់នយោ-បាយ ក្នុងព្រះរាជវង្សានុវង្សនិងបញ្ហាសាសនា ។ |
| ២- **ការបង្រួបបង្រួមជាតិ**<br>អ. national reconciliation<br>បារ. réconciliation nationale | ការបង្រួបបង្រួមភាគីផ្សេងៗ ដែលមាននិន្នាការនិងមនោគមវិជ្ជានយោបាយខុសគ្នា ឬ ការបែកបាក់គ្នារបស់ជាតិមួយ ឱ្យរួបរួមគ្នាឡើងវិញ ដោយតម្កល់ផលប្រយោជន៍និងបញ្ហាជាតិជាធំ ។<br>ឧ. កិច្ចព្រមព្រៀងក្រុងប៉ារីស នាឆ្នាំ១៩៩១ គឺជាលទ្ធផលនៃការបង្រួបបង្រួមខ្មែរច្រើនភាគី ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ដែលអូសបន្លាយជាងពីរទសវត្ស ។ |
| ៣- **បាតុកម្ម**<br>អ. demonstration<br>បារ. manifestation (f.) | អំពើជាក់ស្តែង ការធ្វើឱ្យដឹង ឬ ឱ្យឃើញប្រាកដ ការលើកគ្នាដើរដង្ហែជាក្បួន ដើម្បីសម្តែងសេចក្តីមិនពេញចិត្តចំពោះអំពើអ្វីមួយ ឬ ទទូចសុំស្រុះគ្នាឱ្យសម្រេចផលប្រយោជន៍អ្វីមួយតាមសេចក្តីពេញចិត្តរបស់ក្រុមខ្លួន ។ |
| ៤- **កូដកម្ម**<br>អ. strike | ការសម្តែងអាកប្បកិរិយាប្រឆាំង ចំពោះរឿងឬកិច្ចការណាមួយ ដែលខ្លួនមិនពេញចិត្ត តាមរយៈការមិនចូលរួមបំពេញភារកិច្ចអ្វីមួយ ការមិនចូលធ្វើការ ការដាក់ទណ្ឌកម្មខ្លួនឯង |

| | |
|---|---|
| បារ. grève (f.) | ហើយ ក្នុងករណីខ្លះ អាចឈានទៅរកការធ្វើអត្តឃាត ។ |
| ៥- **នយោបាយ**<br>អ. politics<br>បារ. politique (f.) | វិធីសាស្ត្រ សិល្បៈ បច្ចេកទេស ក្នុងការដឹកនាំ គ្រប់គ្រងរដ្ឋ ឬ រដ្ឋាភិបាល ។ តាមន័យនេះ យើងអាចសង្កេតឃើញថា ពាក្យ **នយោបាយ** មានទំនាក់ទំនងយ៉ាងជិតទៅនឹងរដ្ឋ មានន័យថា នៅពេលមានព្រំសីមាឬបុរី នៅពេលនោះ ការគ្រប់គ្រងនយោបាយ គឺជាកិច្ចការដែលទាក់ទងទៅនឹងមនុស្សនៅក្នុងរដ្ឋឬបុរី ។<br>ឧ. នៅដើមសតវត្សទី១នៃគ្រិស្តសករាជ ប្រទេសកម្ពុជាបានបង្កើតទៅជារដ្ឋ ដោយមានការគ្រប់គ្រងតាមបែបនយោបាយដែលមានក្សត្រី លីវ យី ជាប្រមុខដឹកនាំ ។ |
| ៦- **កតិកាសញ្ញា**<br>អ. pact<br>បារ. pacte (m.) | កិច្ចព្រមព្រៀងមួយ ដែលត្រូវបានធ្វើឡើងរវាងភាគីពីរឬច្រើន ឬ រវាងរដ្ឋនិងរដ្ឋ ទាំងផ្លូវការ ទាំងមិនផ្លូវការ ដើម្បីធ្វើអ្វីមួយរួមគ្នាក្នុងគោលបំណងបម្រើផលប្រយោជន៍រវាងគ្នាទៅវិញទៅមក ។<br>ឧ. នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) ប្រទេស អាល្លឺម៉ង់ អ៊ីតាលី និង ជប៉ុន បានចុះកតិកាសញ្ញាមួយមានឈ្មោះថា " កតិកាសញ្ញា រ៉ូម ប៊ែរឡាំង តូក្យូ " ដើម្បីរួបរួមកម្លាំងយោធាគ្នាប្រឆាំងនឹងសហរដ្ឋអាមេរិក អង់គ្លេស បារាំង និង សហភាពសូវៀត ។ |
| ៧- **កម្លាំងនយោបាយ**<br>អ. political force<br>បារ. force politique | ការសំដែងចេញឱ្យឃើញជាសាធារណៈនូវឫទ្ធានុភាព ឬ សន្ទុះខាងនយោបាយ ទាំងរូបី ទាំងអរូបី ។<br>ឧ. ការហែក្បួនមានមនុស្សដ៏ច្រើនកុះករ គគ្រឹកគគ្រេង នៅក្នុងការឃោសនាបោះឆ្នោត គឺជាការបង្ហាញឱ្យឃើញពីកម្លាំងនយោបាយរបស់គណបក្សណាមួយ ។ |
| ៨- **ការកសាងសន្តិភាព**<br>អ. peace building<br>បារ. recherche de la paix | ដំណើរការការងារឆ្ពោះទៅរកវត្ថុបំណងរក្សាសន្តិភាពរួមគ្នានៃគូបដិបក្ខ និង ពិភពលោក ។<br>ឧ. ការមិនរីកសាយអាវុធប្រល័យលោក គឺជាមាគ៌ាឆ្ពោះទៅរកការកសាងសន្តិភាព ។ |
| ៩- **ការកាត់សេចក្តីឧក្រិដ្ឋកម្មសង្គ្រាម**<br>អ. war crimes trials<br>បារ. ... | ការកាត់សេចក្តីចំពោះអំពើទាំងឡាយណាដែលត្រូវបានគេចោទប្រកាន់ទៅលើបទរំលោភច្បាប់សង្គ្រាមនិងទំនៀមទម្លាប់សង្គ្រាមធ្ងន់ធ្ងរ និង គោលការណ៍នៃច្បាប់អន្តរជាតិ ។<br>ឧ. ខែវិច្ឆិកា ឆ្នាំ១៩៩៤ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចចិត្តលេខ៩៥៥ បង្កើតសាលាជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់កាត់ទោសនៅប្រទេសរ៉ូវ៉ាន់ដា ។ សាលាជម្រះក្តីនេះមានសិទ្ធិអំណាចកាត់ទោសបុគ្គលទាំងឡាយណាដែលទទួលខុសត្រូវ ចំពោះអំពើប្រល័យពូជសាសន៍និងអំពើរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌ អំឡុងសង្គ្រាមស៊ីវិលឆ្នាំ១៩៩៤ ក្នុងប្រទេសរ៉ូវ៉ាន់ដា ។ |
| ១០- **ការបណ្តេញចេញពីអំណាច**<br>អ. overthrow from a position of power by force<br>បារ. ... | ការបង្ខំនរណាម្នាក់ឬក្រុមណាមួយ ឱ្យចេញពីតំណែង មុខងារ តួនាទី ក្នុងគណបក្សនយោបាយឬស្ថាប័នរដ្ឋ ពីព្រោះពួកគេបានបាត់បង់ជំនឿទុកចិត្តពីក្រុមឬស្ថាប័នរបស់ខ្លួន ឬដោយសារតែពួកគេមិនគោរពតាមលក្ខខណ្ឌច្បាប់និងគោលការណ៍ផ្សេងៗ នៃក្រុមរបស់ខ្លួន ។<br>ឧ. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះនរោត្តមសីហនុត្រូវបានសេនាប្រមុខ |

| | |
|---|---|
| | លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ បានធ្វើរដ្ឋប្រហារបណ្តេញចេញពីអំណាច ដោយសារព្រះអង្គត្រូវបានគេចោទប្រកាន់ថា មិនអាចគ្រប់គ្រងស្ថានភាពនយោបាយ និង វិបត្តិសេដ្ឋកិច្ច នៅពេលនោះបាន។ |
| ១១- **ការទូត**<br>អ. diplomacy<br>បា. diplomacie (f.) | ទំនាក់ទំនងផ្លូវការរវាងរដ្ឋនិងរដ្ឋ ក្នុងគោលបំណងភ្ជាប់ទំនាក់ទំនងការងារជាមួយគ្នា ដូចជា ការស្វែងរកសន្តិភាព ពាណិជ្ជកម្ម សង្គ្រាម សេដ្ឋកិច្ច និង វប្បធម៌ ជាដើម។ មុខងារចម្បងរបស់ការទូត គឺការចរចាដើម្បីបង្ហាញនូវផលប្រយោជន៍ទូទៅរបស់រដ្ឋមួយ ឬ តួអង្គមិនមែនរដ្ឋ ដូចជា អង្គការអន្តរជាតិ និង ដើម្បីដោះស្រាយជម្លោះអ្វីមួយដែលកើតមាន នៅក្នុងទំនាក់ទំនងអន្តរជាតិ។<br>ឧ. សង្គ្រាមស៊ីវិលនៅកម្ពុជាដែលអូសបន្លាយជិតពីរទសវត្សរ៍ត្រូវបានបញ្ចប់ តាមរយៈការប្រើប្រាស់នូវនយោបាយការទូតរបស់គូភាគីបដិបក្ខនៅក្នុងជម្លោះ ដែលរួមមាន ភាគីរដ្ឋ-កម្ពុជា និង ភាគីកម្ពុជាប្រជាធិបតេយ្យ (ហ៊្វុនស៊ិនប៉ិច ខ្មែរក្រហម និង រណសិរ្សរួបរួមជាតិរំដោះប្រជាពលរដ្ឋខ្មែរ) ហើយ ជាលទ្ធផលនៃនយោបាយការទូតនេះ ភាគីទាំងអស់បានឈានដល់កិច្ចព្រមព្រៀងសន្តិភាពមួយដែលធ្វើឡើងនៅទីក្រុងប៉ារីស ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីបញ្ចប់ជម្លោះនៅកម្ពុជា។ |
| ១២- **ការបោះឆ្នោតជាកញ្ចប់**<br>អ. bloc voting<br>បារ. vote bloqué | ការបោះឆ្នោតដើម្បីអនុម័តឬសម្រេចបញ្ហាជាច្រើន ក្នុងពេលតែមួយ ដោយសមាជិកម្នាក់ប្រើសន្លឹកឆ្នោតឬសំឡេងតែមួយ។ នីតិវិធីនេះត្រូវបានដកស្រង់ពីរដ្ឋធម្មនុញ្ញប្រទេសបារាំងយកមកកែច្នៃទៅតាមបរិបទនយោបាយកម្ពុជា ដែលអ្នកនយោបាយខ្មែរយកមកប្រើក្រោយពីជាប់គាំងនយោបាយពីឆ្នាំ២០០៣ រហូតដល់ខែកក្កដា ឆ្នាំ២០០៤។<br>ឧ. ក្រោយការបោះឆ្នោតសកលជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣ គណបក្សប្រជាជន ជាប់ឆ្នោតបាន៧៣អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច២៦អាសនៈ និង គណបក្ស សម រង្ស៊ី បាន២៤ អាសនៈ។ យោងតាមចំនួននេះ គ្មានគណបក្សណាមួយមានសំឡេងគ្រប់ចំនួនពីរភាគបីដើម្បីបង្កើតរដ្ឋាភិបាលតែម្នាក់ឯងបានទេ។ តាមច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ការបោះឆ្នោតជ្រើសរើសប្រធាននិងអនុប្រធានរដ្ឋសភា ក៏ដូចជាជ្រើសរើសនាយករដ្ឋមន្ត្រី ត្រូវការសំ-ឡេងគាំទ្រពីរភាគបី ទើបអាចជ្រើសតាំងបាន ហើយ ដោយសារគណបក្សហ្វ៊ុនស៊ិនប៉ិច និង គណបក្ស សម រង្ស៊ី បានបង្កើតសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យដែលមិនព្រមឱ្យគណបក្សណាមួយចូលជាមួយគណបក្សប្រជាជនដើម្បីបង្កើតរដ្ឋាភិបាល (បើចូល ចូលទាំងអស់គ្នា បើចេញ ចេញទាំងអស់គ្នា) ស្ថានភាពនយោបាយក៏ត្រូវបានកកស្ទះ។ ក្រោយមក ដំណោះស្រាយចំពោះភាពទ័លច្រកបានចេញរួច ដោយគណបក្សហ្វ៊ុនស៊ិនប៉ិចព្រមចូលរួមបង្កើតរដ្ឋាភិបាលចម្រុះជាមួយគណបក្សប្រជាជន។<br>ការជ្រើសតាំងប្រធានសភានិងរដ្ឋាភិបាលអាណត្តិទី៣ តាមច្បាប់រដ្ឋធម្មនុញ្ញ តំណាង- |

| | |
|---|---|
| | រាស្ត្រត្រូវបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធាន និង គណៈកម្មការនានា ជាមុនសិន។ ក្រោយពីបោះឆ្នោតនេះហើយ ទើបបោះឆ្នោតជ្រើសនាយករដ្ឋមន្ត្រីចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ តែដោយការបាត់ជំនឿទុកចិត្តពីគណបក្សដៃគូ គេបានធ្វើវិសោធកម្មរដ្ឋធម្មនុញ្ញបញ្ចូលការបោះឆ្នោតជាកញ្ចប់ ដើម្បីសម្រេចបញ្ហាពីរក្នុងពេលតែមួយ។ |
| ១៣- **ការបោះបង់តំណែង**<br>អ. abandonment of a position<br>បារ. abandon d'une position | ការដើរចេញឬការលាឈប់ពីមុខដំណែង ដោយសារមូលហេតុផ្សេងៗ ដូចជា ការមិនពេញចិត្តនឹងការងារ ទំហំការងារហួសពីសមត្ថភាព ឬ រងសម្ពាធនយោបាយណាមួយ។<br>ឧ. បន្ទាប់ពីទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មករបបកម្ពុជាប្រជាធិបតេយ្យ ដែលមានសម្តេច នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ បានចាប់ផ្តើមឡើងកាន់កាប់អំណាចនៅប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប៉ុន្តែនៅឆ្នាំ១៩៧៦ ព្រះអង្គបានសម្រេចព្រះទ័យបោះបង់អំណាចជាព្រះប្រមុខរដ្ឋចោល។<br>ឧ. ក្រោមការដឹកនាំរបស់លោកប្រធានាធិបតី បូរីស យែលស៊ីន (Borish Yelthsin) ពីឆ្នាំ១៩៩១ ដល់ ឆ្នាំ២000 សហព័ន្ធរុស្ស៊ីបានជួបប្រទះនូវវិបត្តិនយោបាយនិងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ មូលហេតុដែលធ្វើឱ្យមានវិបត្តិទាំងនេះ គឺដោយសារការផ្តាច់ខ្លួនរបស់ប្រទេសចំនួន១៥ចេញពីសហភាពសូវៀត បញ្ហានយោបាយនៅអឺរ៉ុបខាងកើត ការដួលរលំជញ្ជាំងប៊ែរឡាំង ការដកកងទ័ពរុស្ស៊ីចេញពីអាហ្គានីស្ថាន និង ការផ្ទុះសង្គ្រាមមួយនៅឆេឆេនី។ ដូច្នេះហើយ ដោយមិនអាចដោះស្រាយវិបត្តិទាំងអស់នេះបាន លោកប្រធានាធិបតី បូរីស យែលស៊ីន បានបោះបង់តំណែងរបស់ខ្លួនជាប្រធានាធិបតី ដោយផ្ទេរអំណាចទៅឱ្យលោក ប្លាឌីមា ពូទីន គ្រប់គ្រងអំណាចជំនួសវិញ ហើយ រង់ចាំរហូតដល់មានការបោះឆ្នោតសាជាថ្មី។<br>ឧ. ក្រោយពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៣ រដ្ឋាភិបាលចម្រុះមួយត្រូវបានបង្កើតឡើង ដែលក្នុងនោះ គណបក្សប្រជាជនកម្ពុជានិងគណបក្សហ៊្វុនស៊ិនប៉ិច បានព្រមព្រៀងគ្នាធ្វើជាដៃគូក្នុងការដឹកនាំរដ្ឋាភិបាលរហូតដល់ចប់អាណត្តិ ប៉ុន្តែក្រោយមកដោយសារគណបក្សប្រជាជន និង គណបក្សសមរង្ស៊ី បានឯកភាពគ្នាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដោយកែប្រែមាត្រានៃរដ្ឋធម្មនុញ្ញស្តីពីការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តបង្កើតរដ្ឋាភិបាលដោយសំឡេងពីរភាគបី មកនៅត្រឹមតែសំឡេងហាសិបបូកមួយនេះ គណបក្សហ៊្វុនស៊ិនប៉ិនក៏លែងជាដៃគូសំខាន់នៅក្នុងការអនុម័តច្បាប់ និង ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ទៀតហើយ។ គឺចំណុចនេះហើយដែលជាគំនាបនយោបាយ ធ្វើឱ្យសម្តេចក្រុមព្រះនរោត្តម រណប្ញទ្ធិ បោះបង់តំណែងជាប្រធានរដ្ឋសភាអាណត្តិទី៣ មុនពេលចប់អាណត្តិ។ |
| ១៤- **ការរក្សាសន្តិភាព**<br>អ. peace keeping | ការរក្សាសន្តិភាពកើតចេញមកពីការដោះស្រាយរវាងគូប្រឈមពីរឬច្រើនក្រុម ហើយចែកជាពីរប្រភេទ : |

| | |
|---|---|
| បារ. maintien de la paix | **ទី១.** សំដៅលើភាគីកងកម្លាំងប្រដាប់អាវុធពីរដែលប្រឈមមុខគ្នា ហើយ បានឯកភាពព្រមព្រៀងលើគោលការណ៍សន្តិភាព ការឈប់បាញ់គ្នា ដើម្បីដោះស្រាយរាល់បញ្ហាទាំងឡាយណាដែលប្រឈម ។<br>ឧ. ក្រោយពីប្រាសាទព្រះវិហារត្រូវបានដាក់ចូលជាបេតិកភណ្ឌពិភពលោកកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ កងទ័ពថៃបានចូលមករំលោភបូរណភាពទឹកដីប្រទេសកម្ពុជា។ បញ្ហានេះបានបង្កើតឱ្យមានការផ្ទុះអាវុធជាច្រើនលើក។ ក្រោយមក ភាគីទាំងពីរបានចរចាគ្នាដើម្បីរក្សាសន្តិភាពរវាងភាគីកងទ័ពកម្ពុជានិងកងទ័ពថៃ នៅតាមខ្សែព្រំដែនស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។<br>**ទី២.** សំដៅលើភាគីកងកម្លាំងប្រដាប់អាវុធច្រើនក្រុមដែលប្រឈមមុខដាក់គ្នា ហើយបានឯកភាពព្រមព្រៀងលើគោលការណ៍សន្តិភាពបញ្ឈប់ការបាញ់គ្នា ដោយយកតួអង្គណាមួយជាអាជ្ញាកណ្តាល ។<br>ឧ. ជម្លោះរ៉ាំរ៉ៃជាងពីរទសវត្សរ៍រវាងចតុភាគីកម្ពុជា បានឈានទៅរកកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដោយមានអង្គការសហប្រជាជាតិដើរតួជាអ្នកសម្របសម្រួលក្នុងការដោះស្រាយ ។ |
| ១៥- **ការរត់ប្រណាំងសព្វាវុធ**<br>អ. arms race<br>បារ. course aux armements | ការប្រកួតប្រជែងខាងការបង្កើតសព្វាវុធ ដោយភាគីពីរយ៉ាងតិចដែលប្រឈមគ្នា ដើម្បីឧត្តមភាពខាងគ្រឿងសព្វាវុធ ។ ដំណើរការមូលដ្ឋានក្នុងការរត់ប្រណាំងសព្វាវុធនេះ គឺសំដៅទៅលើបែបបទនៃប្រតិកម្មឆ្លើយតបរបស់ភាគីដែលប្រកួតប្រជែង។ ជាទូទៅ ការប្រកួតប្រជែងនេះ ជំរុញឱ្យមានការផ្ទុះឡើងនូវអំពើហិង្សានិងសង្គ្រាម ដូចជាការរត់ប្រណាំងសព្វាវុធរវាងសហភាពសូវៀតនិងសហរដ្ឋអាមេរិក បានធ្វើឱ្យប្រទេសតូចៗនិងប្រទេសជិតខាងជួបប្រទះភាពតានតឹង និង ផ្ទុះសង្គ្រាម។ តែផ្ទុយទៅវិញ ការប្រកួតប្រជែងបែបនេះ ក៏អាចនាំមកនូវការរីកចម្រើនជាវិជ្ជមានជាច្រើនខាងផ្នែកវិទ្យាសាស្ត្រផងដែរ ជាក់-ស្តែងដូចជា ក្នុងសង្គ្រាមលោកលើកទី១ ការរត់ប្រណាំងខាងនាវារវាងចក្រភពអង់គ្លេស និង ចក្រភពអាល្លឺម៉ង់។ |
| ១៦- **ការលើកលែងទោស**<br>អ. amnesty<br>បារ. amnistie (f.) | ការសម្រេចចិត្តមួយដែលបដិសេធ (ដាកចេញពី) នីតិវិធីច្បាប់ឬការផ្តន្ទាទោសចំពោះអ្នកប្រព្រឹត្តទោសកំហុសមួយចំនួន (ជាធម្មតា គឺជាទោសនយោបាយ)។ ការលើកលែងទោស មានន័យប្រហាក់ប្រហែលគ្នាទៅនឹងការអភ័យទោស ប៉ុន្តែគ្មានន័យលាក់កំបាំងនៃការអត់ឱនទោស ដែលអនុវត្តជាធម្មតានោះទេ។ ការលើកលែងទោសអាចធ្វើជាទូទៅ ឬជាផ្នែកជាក់លាក់ពេញលេញ ឬ មិនពេញលេញ។<br>ពាក្យនេះត្រូវបានគេប្រើជាទូទៅក្នុងទំនាក់ទំនងចំពោះអ្នកទោសសង្គ្រាមនិងអ្នកទោសខាងមនសិការ។ អង្គការលើកលែងទោសអន្តរជាតិ គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលយកចិត្តទុកដាក់ចំពោះការមើលខុសត្រូវ (ការពិនិត្យពិច័យ) ទៅលើភាពលម្មៀងយ៉ាងធំ |

| | |
|---|---|
| | ផេង នៅលើពិភពលោក លើករណីផ្សេងៗ ដូចជា បុគ្គលម្នាក់ៗឬក្រុមណាមួយដែលត្រូវគេផ្តន្ទាទោស ពីព្រោះតែទស្សនៈនយោបាយនិងសាសនារបស់ពួកគេ។ |
| ១៧- **ការសម្រុះសម្រួល**<br>អ. accomodation<br>បារ. conciliation (f.) | ដំណើរការដែលធ្វើឱ្យតួអង្គក្នុងទំនាស់ឯកភាពទទួលយកសំណើរបស់ភាគីម្ខាងទៀតដែលមិនប៉ះពាល់ផលប្រយោជន៍មូលដ្ឋានរបស់ពួកគេទាំងសងខាង។ ការសម្រុះសម្រួល ត្រូវសន្មតថាជាជម្លោះអន្តរជាតិ មិនមែនដូចនៅក្នុងទ្រឹស្តីល្បែង ឬ ការប្រកួតប្រជែងដែលក្នុងនោះ ភាគីមួយឈ្នះ ហើយជាស្វ័យប្រវត្តិភាគីម្ខាងទៀតចាញ់នោះទេ។<br>ការសម្រុះសម្រួលអាចសន្មតថាភាពចុះសម្រុងទាំងស្រុងខាងផលប្រយោជន៍មិនអាចសម្រេចបានទេ។ ដូច្នេះ ការសម្រុះសម្រួលជាចំណុចកណ្តាលនៃបញ្ហាប្រឈមនិងការចុះសម្រុងគ្នា។ ពាក្យនេះ ជាធម្មតា ត្រូវបានគេប្រើទាក់ទងនឹងផលប្រយោជន៍ ដូច្នេះមិនមែនគ្មានទឡ្ហីករណ៍ខុសឆ្គង ឬ ការបំភាន់នោះទេ។ |
| ១៨- **ការិយាធិបតេយ្យ**<br>អ. bureaucracy<br>បារ. bureaucratie (f.) | ប្រព័ន្ធរដ្ឋបាលរបស់អង្គភាពមួយដែលតាមរយៈប្រព័ន្ធនេះ ការបែងចែកការងារត្រូវបានរៀបចំជាឋានានុក្រម ដើម្បីអនុវត្តនូវភារកិច្ចជំនាញ ដោយឈរលើមូលដ្ឋានវិធានផ្ទៃក្នុង និង នីតិវិធីរបស់អង្គភាពនេះ។ ពាក្យនេះត្រូវបានគេប្រើសំដៅទៅលើរដ្ឋបាលរបស់រដ្ឋាភិ-បាល ជាពិសេស អំពីមន្ត្រីរាជការនៅក្នុងរដ្ឋាភិបាល និង សេវាសាធារណៈផ្សេងៗ។ តាមន័យ អវិជ្ជមាន គេតែងប្រើពាក្យនេះ ដើម្បីសម្គាល់ប្រព័ន្ធរដ្ឋបាលសាំញ៉ាំដែលអនុញ្ញាតឱ្យមន្ត្រីរាជការឆ្លៀតយកអំណាចដែលរដ្ឋប្រគល់ឱ្យ ដើម្បីបម្រើបុព្វសិទ្ធិរបស់ខ្លួនហើយដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់អ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។<br>ឧ. នៅសហរដ្ឋអាមេរិក ការិយាធិបតេយ្យនេះបានរីកដុះដាលដែលធ្វើឱ្យខូចប្រយោជន៍របស់វណ្ណៈអធន ហើយ បានដកហូតយកអំណាចពីវណ្ណៈនេះ។ |
| ១៩-**កិច្ចព្រមព្រៀងអន្តរជាតិ**<br>អ. international agreement<br>បារ. accord international | មានន័យដូចសន្ធិសញ្ញាដែរ ប៉ុន្តែ មានលក្ខណៈផ្លូវការតិចជាងសន្ធិសញ្ញា។ លក្ខណៈវិ-និច្ឆ័យនៃកិច្ចព្រមព្រៀង គឺ :<br>- ត្រូវបានប្រើជាពិសេសសម្រាប់លិខិតូបករណ៍ ដែលមានលក្ខណៈបច្ចេកទេស ឬ រដ្ឋបាល។<br>- កិច្ចព្រមព្រៀងមិនទាមទារឱ្យមានការផ្តល់សច្ចាប័នពីសភាឡើយ។<br>- ក្នុងករណីខ្លះ កិច្ចព្រមព្រៀងអាចមិនមានទម្រង់ជាលាយលក្ខណ៍អក្សរ ដូចជា កិច្ច-ព្រមព្រៀងផ្ទាល់មាត់ដែលអាចជាកិច្ចសន្យា ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី , រដ្ឋមន្ត្រីការបរទេស នៃប្រទេសមួយជាមួយដៃគូរបស់ខ្លួន ឬ ជាមួយរដ្ឋដទៃទៀត។<br>ឧ. កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មនិងពន្ធគយ (General Agreement on Trade and Tariff) ។ |
| ២០- **កុបកម្ម**<br>អ. riot<br>បារ. émeute (f.) | ការបះបោរឬចលាចលដោយប្រើអំពើហិង្សា បង្កឡើងដោយមនុស្សមួយក្រុមឬច្រើនក្រុម នៅពេលពួកគេមិនពេញចិត្តទៅលើបញ្ហាណាមួយ។ កុបកម្មអាចកើតចេញពីកូដកម្ម ឬបាតុកម្ម នៅពេលដែលកូដករ ឬ បាតុករ ចាប់ផ្តើមប្រែក្លាយការតវ៉ាឬទាមទារដោយសន្តិ- |

| | |
|---|---|
| | វិធី ទៅជាការតវ៉ាឬទាមទារដោយប្រើអំពើហិង្សា ។<br>ឧ. នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ កុបករបាននាំគ្នាធ្វើកុបកម្មវាយបំផ្លាញស្ថានទូតថៃ ។ |
| ២១- **កុម្មុយនីស្ត**<br>អ. communist<br>បារ. communist (m.) | គេច្រើនប្រើពាក្យនេះជាគុណនាម : ប្រទេសកុម្មុយនីស្ត របបកុម្មុយនីស្ត ។ ប្រទេសកុម្មុយនីស្ត ជាសង្គមដែលទ្រព្យផលិតកម្ម ជាកម្មសិទ្ធិរបស់សមូហភាព ហើយ ប្រព័ន្ធដឹកនាំប្រទេសស្ថិតក្រោមអំណាចផ្តាច់មុខរបស់បក្សកុម្មុយនីស្ត ។<br>ឧ. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩១៧ ប្រទេសរុស្ស៊ីបានធ្វើបដិវត្តន៍ផ្តួលរំលំរបបសក្តិភូមិ ហើយ ប្តូររបបដឹកនាំប្រទេសទៅជារបបកុម្មុយនីស្តវិញ ។ |
| ២២- **កំណត់ទូត**<br>អ. note verbale<br>បារ. note verbale | ជាលិខិតទាក់ទងផ្លូវការរវាងក្រសួងការបរទេសនិងក្រសួងការបរទេសរបស់រដ្ឋនានា ឬ ជាលិខិតទាក់ទងរបស់ស្ថាប័ននៃរដ្ឋមួយជាមួយស្ថានទូតបរទេស នៅក្នុងប្រទេសរបស់ខ្លួន ដើម្បីជាការជូនដំណឹងនិងសហប្រតិបត្តិការផ្សេងៗទៀត ។ |
| ២៣- **ខ្លាអាស៊ី**<br>អ. asian tigers<br>បារ. tigres d’Asie | ពាក្យនេះជានិមិត្តរូបដែលនិយាយសំដៅទៅរកក្រុមសេដ្ឋកិច្ចអាស៊ី ដែលធ្លាប់មានបទ-ពិសោធន៍ជឿនលឿនផ្នែកសេដ្ឋកិច្ចយ៉ាងរហ័ស នៅក្នុងអតីតកាលថ្មីៗរបស់ខ្លួន និង ត្រូវបានគេចាត់ទុកថា ជាក្រុមគំរូសម្រាប់សេដ្ឋកិច្ចទីផ្សារសេរីនិងសេរីនិយមខាងសេដ្ឋកិច្ច ។ ជាធម្មតា ក្រុមសេដ្ឋកិច្ចអាស៊ីចំនួនប្រាំដែលគេស្គាល់ មាន ជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី ហុងកុង និង តៃវ៉ាន់ ។<br>ប្រទេសដែលគេសន្មតហៅជាទូទៅថា ជាកូនតោ មាន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និង ថៃ ។ បន្ទាប់ពីឆ្នាំ១៩៩៧ ប្រទេសចិនដែលរួមបញ្ចូលទាំងហុងកុងផងនោះ គេអាចពណ៌នាប្រដូចទៅនឹងនាគ ហៅថា នាគអាស៊ី ហើយ តាមទស្សនៈខ្លះ ខ្លាអាស៊ី គេហៅថាជា នាគអាស៊ី វិញ ។ |
| ២៤- **គោលការណ៍មិនជ្រៀតជ្រែក**<br>អ. non-interference principle<br>បារ. principe de non- ingérence | ជាគោលការណ៍ទូតដែលមិនអនុញ្ញាតឱ្យរដ្ឋមួយមានសិទ្ធិធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុងនៃរដ្ឋមួយទៀត ទាំងផ្នែកនយោបាយ ផ្នែកយោធា សេដ្ឋកិច្ច បច្ចេកទេស និង វប្បធម៌ ។ល ។<br>ឧ. នៅឆ្នាំ១៩៧៥ គោលការណ៍មួយនៃសេចក្តីថ្លែងការណ៍នៅហែលស៊ិនគី បានអនុញ្ញាតឱ្យសហភាពសូវៀតប្រកាសថ្កោលទោសបស្ចិមប្រទេសដែលគាំទ្រអ្នកប្រឆាំងឬអ្នករត់ចោលជួរពីប្រទេសកុម្មុយនីស្ត ។ |
| ២៥-**គោលនយោបាយការបរទេស**<br>អ. foreign policy<br>បារ. principe de politique étrangère | យុទ្ធសាស្ត្រឬផែនការដែលរៀបចំឡើងដោយអ្នកធ្វើសេចក្តីសម្រេចរបស់រដ្ឋមួយ ចំពោះរដ្ឋដទៃទៀត ឬ នីតិបុគ្គលអន្តរជាតិនានា ដើម្បីសម្រេចបាននូវគោលបំណងជាក់លាក់សម្រាប់ជាតិរបស់ខ្លួន ។ គោលដៅនៃនយោបាយការបរទេសមានបីគឺ សន្តិសុខជាតិ សុខុ-មាលភាពសេដ្ឋកិច្ច និង អត្តសញ្ញាណជាតិ ។ សន្តិសុខជាតិមានន័យថា គឺការការពារអធិប-តេយ្យ បូរណភាពទឹកដី , សុខុមាលភាពសេដ្ឋកិច្ច គឺការរីកចម្រើនផ្នែកសេដ្ឋកិច្ច និង អត្ត- |

| | |
|---|---|
| | សញ្ញាណជាតិ គឺការការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ។ |
| ២៦- **ចក្រពត្តិនិយម**<br>អ. imperialism<br>បារ. impérialisme (m.) | នយោបាយមួយនៃការប្រើអំណាចត្រួតត្រារបស់រដ្ឋមួយទៅលើរដ្ឋដទៃទៀត ។ ការត្រួតត្រានេះអាចមានលក្ខណៈជាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជា ពេលដែលអំណាចចក្រពត្តិនិយមលើកទឹកចិត្តឱ្យមានការរៀបចំដាក់ទុននិងតាំងសហគ្រាសរបស់គេ នៅក្នុងប្រទេសមួយផ្សេងទៀតជាដើម ហើយ ទិញមកវិញនូវវត្ថុធាតុដើមក្នុងតម្លៃទាប ។ ការត្រួតត្រានេះអាចមានទម្រង់ជាវប្បធម៌ កាលណាប្រទេសមួយយកភាសា ខ្សែភាពយន្ត និង រចនាបថរបស់ខ្លួន ទៅផ្សព្វផ្សាយនៅបរទេស ក្នុងគោលបំណងបង្ខំឱ្យទទួលយក ។ ចក្រពត្តិនិយមមិនមែនសុទ្ធតែប៉ះពាល់ជាចាំបាច់ដល់ឯករាជ្យនយោបាយនៃប្រទេសដែលគេពង្រីកខ្លួនគេនោះទេ ពីព្រោះប្រទេសទាំងនោះអាចរក្សានូវរដ្ឋាភិបាលរបស់ខ្លួន ។<br>ឧ. ជនជាតិរុស្ស៊ីបានពង្រីកឥទ្ធិពលរបស់ខ្លួនទៅលើប្រជាជនស៊ីបេរី តាមរយៈការប្រើនយោបាយចក្រពត្តិនិយមនៅសតវត្សរ៍ទី១៩ និង ជនជាតិជប៉ុនបានពង្រីកឥទ្ធិពលរបស់ខ្លួនទៅប្រទេសចិននៅឆ្នាំ១៩៣៧ ។ |
| ២៧- **ច្បាប់អន្តរជាតិ**<br>អ. internalional law<br>បារ. droit internalional | ប្រព័ន្ធនៃវិធានស្តីពីសិទ្ធិនិងភារកិច្ចរបស់រដ្ឋនានា នៅក្នុងទំនាក់ទំនងរវាងរដ្ឋទាំងនោះ ។ ច្បាប់អន្តរជាតិ ផ្អែកលើទស្សនទាននៃសមភាពនិងអធិបតេយ្យរបស់រដ្ឋនានា និង ផ្អែកទាំងស្រុងទៅលើការព្រមព្រៀងរវាងរដ្ឋទាំងនោះ ។ ម្យ៉ាងទៀត ច្បាប់អន្តរជាតិគឺជាសំណុំនៃគោលការណ៍និងវិធានដែលគ្រប់គ្រងលើសិទ្ធិនិងភារកិច្ចរបស់រដ្ឋនានា អង្គការអន្តរជាតិនានា និង មនុស្សទូទៅនៅក្នុងទំនាក់ទំនងរបស់ពួកគេនៅលើពិភពលោក ។ ច្បាប់អន្តរជាតិផ្តល់នូវមគ្គុទ្ទេសន៍[១៥] សម្រាប់សកម្មភាពរបស់រដ្ឋជាសមាជិក និង ផ្តល់នូវវិធីសាស្ត្រសម្រាប់ដោះស្រាយជម្លោះរវាងរដ្ឋនានាដោយសន្តិវិធី និង ដោយយោងតាមបទដ្ឋានដែលបានយល់ស្របទាំងអស់គ្នាជាជាងប្រើកម្លាំងបាយ ។<br>ជាទូទៅ ច្បាប់អន្តរជាតិមានគោលដៅគ្រប់គ្រងរាល់សកម្មភាពក្នុងទំនាក់ទំនងអន្តរជាតិរវាងរដ្ឋនិងរដ្ឋ ប៉ុន្តែ បច្ចុប្បន្ននេះ ច្បាប់អន្តរជាតិក៏យកចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើបុគ្គលនានាផងដែរ ជាពិសេសការប្រព្រឹត្តរបស់រដ្ឋទៅលើបុគ្គល ឬ ក៏សកម្មភាពបុគ្គលទៅលើរដ្ឋ ។ ដូច្នេះហើយ ទាំងបុគ្គលក៏ដូចជាប្រទេសនានា មានកាតព្វកិច្ចនិងសិទ្ធិនៅក្រោមច្បាប់អន្តរជាតិនានា ។<br>ឧ. ចំពោះប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិ គេមានច្បាប់អន្តរជាតិដែលប្រទេសជាសមាជិកត្រូវតែគោរព និង អនុវត្តទៅតាមគោលការណ៍នៃច្បាប់ដែលបានអនុម័ត ។ ជាក់ស្តែង នៅថ្ងៃទី០២ សីហា ១៩៩០ ដល់ថ្ងៃ២៨ កុម្ភៈ ១៩៩១ ប្រទេសអ៊ីរ៉ាក់បានធ្វើសង្គ្រាមឈ្លានពានប្រទេសគូវ៉ែត ហើយ ពេលនោះ គេបានយកច្បាប់អន្តរជាតិទៅ |

[១៥] A.P. Buddhadatta MahaÆthera : ENGLISH-PALI DICTIONARY, PTS Edition : London ,1955 ; Reprint : Delhi, 1989,1997 p.234 .

| | |
|---|---|
| | ប្រើ ដោយអង្គការសហប្រជាជាតិបានចាត់កងកម្លាំងសន្តិសុខទៅបង្ក្រាបប្រទេសអ៊ីរ៉ាក់ ដោយជោគជ័យ ។ |
| ២៨- **ឆ្វេងនិយម**<br>អ. leftism<br>បារ. ... | និន្នាការឬមនោគមន៍វិជ្ជានយោបាយដែលនិយមកំណែទម្រង់ជ្រុលនិងនិយមការធ្វើបដិវត្តន៍ ដើម្បីផ្លាស់ប្តូរសណ្តាប់ធ្នាប់សង្គម ក្នុងគោលបំណងពង្រីកសេរីភាពនិងសុខុមាលភាពសង្គមសម្រាប់ប្រជាជន ដោយប្រយុទ្ធតស៊ូប្រឆាំងនឹងវិសមភាពសង្គម ហើយ ប្រកាន់យកគោលការណ៍សមភាព ។ នៅក្នុងវិស័យសេដ្ឋកិច្ច និន្នាការឆ្វេងនិយមប្រកាន់គោលការណ៍អន្តរាគមន៍របស់រដ្ឋតាមរយៈការដាក់បទបញ្ញត្តិនិងជាតូបនីយកម្មជាដើម ។ គេអាចកំណត់ឆ្វេងនិយម បានតាមរយៈការដឹកនាំសង្គម ការគ្រប់គ្រងរដ្ឋ សេដ្ឋកិច្ច និង នយោបាយ . ឧទាហរណ៍ :<br>- មនោគមន៍វិជ្ជាឆ្វេងនិយមមានឥទ្ធិពលក្រោយសង្គ្រាមលោកទី២ ។<br>- នៅសហរដ្ឋអាមេរិក មានគណបក្សបី គឺ League for Progressive Political Action, American Labor Party និង Black Panther Party ដែលប្រកាន់យកលទ្ធិឆ្វេងនិយម ។ |
| ២៩- **ជាតិនិយម**<br>អ. nationalism<br>បារ. nationalisme | ការលើកតម្កើងជាតិសាសន៍ខ្លួនឯងឱ្យដាច់គេ ការឱ្យតម្លៃទាបជាងខ្លួនដល់ជាតិសាសន៍ដទៃដែលជារដ្ឋឯករាជ្យដូចគ្នា ។ លើសពីនេះទៀត ជាតិនិយមគឺជាការធ្វើឱ្យមានមនោសញ្ចេតនា ចំពោះជាតិយ៉ាងពុះកញ្ជ្រោល ការស្រឡាញ់ជាតិរបស់ខ្លួននៅក្នុងមហិច្ឆតា ហើយ នៅពេលខ្លះ រហូតដល់ស្អប់និងរើសអើងជាតិសាសន៍ដទៃថែមទៀត ។<br>ឧ. មុនសង្គ្រាមលោកលើកទី២ ជនជាតិអាល្លឺម៉ង់ជាជនជាតិដែលជាតិនិយមលើកតម្កើងជាតិសាសន៍ខ្លួនឯងជាងគេ ដែលជាបុព្វហេតុនាំឱ្យមានការប្រកាន់ពូជសាសន៍និងការបង្កើតសង្គ្រាម ។ |
| ៣០- **ជំនួយស្មារតី**<br>អ. aides memoire<br>បារ. aide mémoire | លិខិតដែលប្រគល់ឬផ្ញើជូន បន្ទាប់ពីមានកិច្ចសន្ទនាការទូតមួយ ដើម្បីជៀសវាងការយល់ច្រឡំគ្នា ទាក់ទងនឹងសេចក្តីថ្លែងនៅពេលសន្ទនាជាមួយគ្នា ។<br>ឧ. ជំនួយស្មារតីស្តីពីការផ្តល់គ្រូបង្វឹកកីឡារបស់ប្រទេសជប៉ុនមកបង្ហាត់កីឡាករកម្ពុជា ។ |
| ៣១- **តុល្យភាពអំណាច**<br>អ. balance of power<br>បារ. équilibre de pouvoirs | ការបែងចែកអំណាចនៃរដ្ឋនិងរដ្ឋ ឬ បក្សសម្ព័ន្ធនិងសម្ព័ន្ធមិត្ត ដែលប្រឆាំងគ្នា ហើយការបែងចែកនេះមិនមានរដ្ឋ ឬ បក្សសម្ព័ន្ធណាមួយ មានប្រៀបជាងរដ្ឋឬបក្សសម្ព័ន្ធណាមួយទេ ។<br>ឧ. សហរដ្ឋអាមេរិកនិងសហភាពសូវៀតបានរក្សាឱ្យមានតុល្យភាពអំណាចក្នុងការប្រើប្រាស់ចំនួនអាវុធនុយក្លេអ៊ែរស្មើគ្នា នៅក្នុងទសវត្សរ៍៧០-៨០នៃសតវត្សរ៍ទី២០ ដែលបានជួយធ្វើឱ្យមាននិរន្តរភាពនៃតុល្យភាពអំណាចខាងយោធា ។ |
| ៣២- **ទណ្ឌកម្មច្បាប់សង្គ្រាម**<br>អ. sanctions of war laws<br>បារ. ... | ជាវិធានការផ្លូវច្បាប់ ស្តីពីការដាក់ទោសចំពោះអ្នកដឹកនាំរដ្ឋឬក្រុមមនុស្សណាមួយដែលមិនគោរពច្បាប់សង្គ្រាមអន្តរជាតិ ក្នុងការធ្វើសង្គ្រាម ។ ច្បាប់អន្តរជាតិ ជារឿយៗ ត្រូវបានគេរិះគន់ ដោយហេតុថា គ្មានការដាក់ទណ្ឌកម្ម ។ ជាការពិតណាស់ បើប្រៀបធៀបទៅ |

| | |
|---|---|
| | នឹងច្បាប់របស់រដ្ឋ ច្បាប់អន្តរជាតិមានការដាក់ទណ្ឌកម្មតិចតួចណាស់ ។ ច្បាប់សង្គ្រាមជាញឹកញាប់ត្រូវបានគេរំលោភបំពាន ប៉ុន្តែ ច្បាប់អន្តរជាតិពុំមានមធ្យោបាយណាមួយដើម្បីបង្ខំឱ្យរដ្ឋទាំងអស់ប្រតិបត្តិតាមច្បាប់នេះឡើយ ។ ជាទូទៅ នៅក្នុងករណីប្រទេសមហាអំណាចជាអ្នកបង្កសង្គ្រាម ប្រទេសនោះមិនត្រូវបានគេដាក់ទណ្ឌកម្មនោះទេ ។ ផ្ទុយទៅវិញ ប្រទេសតូចតាចនិងទន់ខ្សោយតែងតែទទួលរងការដាក់ទណ្ឌកម្មសង្គ្រាម ។<br>ឧ. លោក Slobodan Milosevic (1941-2006) ដែលជាប្រធានាធិបតីសាធារណរដ្ឋសែប៊ី ពីឆ្នាំ១៩៨៩ ដល់ ១៩៩៧ និង ជាប្រធានសហព័ន្ធសាធារណរដ្ឋយូហ្គោស្លាវី ពីឆ្នាំ ១៩៩៧-២000 ត្រូវបានគេចោទប្រកាន់ជាឧក្រិដ្ឋជនសង្គ្រាម ហើយត្រូវបានគេកាត់ទោសតាមច្បាប់អន្តរជាតិ ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម ។ ទណ្ឌកម្មសង្គ្រាមមានដូចតទៅ :<br>**១**- ការផ្ទាញ់តប : ជាវិធានការដ៏ចំណាស់មួយនៅក្នុងចំណោមវិធានការនានានៃច្បាប់អន្តរជាតិ ។ ការផ្ទាញ់តប គឺជាមធ្យោបាយមួយដើម្បីបង្ខំឱ្យបណ្តារដ្ឋដែលឈ្លោះគ្នាទាំងអស់ប្រតិបត្តិតាមវិធាននៃការធ្វើសង្គ្រាម ។ ក្នុងពេលថ្មីៗនេះ ការផ្ទាញ់តប ជារឿយៗ ធ្វើឱ្យរដ្ឋាភិបាលមានជម្លោះ ប្រតិបត្តិតាមវិធាននៃច្បាប់ស្តីពីសង្គ្រាម ។<br>**២**- ការដាក់ទណ្ឌកម្មលើឧក្រិដ្ឋជនសង្គ្រាម (punishment of war criminals) : ជនណាដែលមានកំហុសពីបទឧក្រិដ្ឋសង្គ្រាមអាចត្រូវបានចាប់ខ្លួននិងកាត់ទោស ។ ក្រោយសង្គ្រាមលោកលើកទី២ មានឧក្រិដ្ឋជនសង្គ្រាមមួយចំនួនត្រូវបានគេឃុំខ្លួន និង ជនដែលគេរកឃើញថាមានកំហុសពីបទឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានគេកាត់ទោស ។ នៅក្នុងចំណោមសវនការស្តីពីបទឧក្រិដ្ឋកម្មសង្គ្រាម មានសវនការនៅទីក្រុងនុយរ៉ុមប៊ែរ និង ទីក្រុងតូក្យូ ។<br>**៣**- សំណង (compensation) : រដ្ឋមានជម្លោះមួយដែលរំលោភបំពានលើច្បាប់នានាដែលទាក់ទងទៅនឹងសង្គ្រាម អាចត្រូវបានបង្ខំឱ្យបង់សំណង សម្រាប់ការរំលោភបំពាននោះ ។<br>មាត្រា៣ នៃអនុសញ្ញាទីក្រុងឡាអេ នាឆ្នាំ១៩០៧ ចែងថា "រដ្ឋមួយដែលបានរំលោភច្បាប់សង្គ្រាម អាចត្រូវបានបង្ខំឱ្យបង់សំណង ចំពោះការរំលោភបំពាននោះ" ។ |
| ៣៣- **ទឹកដីអាណានិគម**<br>អ. colony<br>បារ. colonie (f.) | ទឹកដីរបស់ប្រទេសមួយដែលមានអំណាចទន់ខ្សោយ ត្រូវបានគ្រប់គ្រងដោយរដ្ឋបរទេសមួយដែលមានអំណាចខ្លាំងជាង ។<br>ឧ. នៅចុងសតវត្សរ៍ទី១៩ ប្រទេសកម្ពុជា វៀតណាម ឡាវ គឺជាទឹកដីអាណានិគមរបស់ប្រទេសបារាំង ។ |
| ៣៤-**ធម្មនុញ្ញ**<br>អ. charter<br>បារ. charte (f.) | ក្រមឬលិខិតូបករណ៍នានាដែលមានលក្ខណៈផ្លូវការ ក្នុងការបង្កើតអង្គការអន្តរជាតិណាមួយឬស្ថាប័នណាមួយ ។<br>ឧ. ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាជ្ញាធរជាតិប្រឆាំងនឹងជំងឺអេដស៍ ធម្មនុញ្ញគណៈកម្មាធិការអូឡាំពិកអន្តរជាតិ ។ |

| | |
|---|---|
| ៣៥- **ពិធីសារ**<br>អ. protocol<br>បារ. protocole (m.) | ឯកសារដែលមានតម្លៃស្មើកិច្ចព្រមព្រៀង តែពិធីសារនេះមានលក្ខណៈផ្លូវការតិចជាងកិច្ចព្រមព្រៀង។ ពិធីសារមានឋានានុក្រម ដូចតទៅ :<br>-ពិធីសារចុះហត្ថលេខា គឺជាឯកសារបន្ទាប់បន្សំរបស់សន្ធិសញ្ញា។ ពិធីសារនេះសម្រាប់ដោះស្រាយបញ្ហាបន្ទាប់បន្សំនានា ដូចជា ការបកស្រាយ "ខ" ពិសេសនានារបស់សន្ធិសញ្ញា ដោយ "ខ" ទាំងនេះមិនមានបញ្ចូលក្នុងសន្ធិសញ្ញាឬបទបញ្ញត្តិនៃបញ្ហាបច្ចេកទេសជាដើម, ឧ. ពិធីសារស្ដីពីឋានៈរបស់ជនភៀសខ្លួន ឆ្នាំ១៩៦៦។<br>- ពិធីសារជម្រើស ជាឯកសារដែលត្រូវបានអនុម័តក្នុងថ្ងៃតែមួយជាមួយនឹងសន្ធិសញ្ញា។ ពិធីសារនេះផ្ដល់ឱ្យភាគីទាំងឡាយដែលបានចុះសន្ធិសញ្ញាជាមួយគ្នា បង្កើតនូវលទ្ធភាពរចនាសម្ព័ន្ធនៃកាតព្វកិច្ចរវាងគ្នា បន្ថែមលើកាតព្វកិច្ចដែលមានក្នុងសន្ធិសញ្ញា, ឧ. ពិធីសារឆ្នាំ១៩៥៣ ស្ដីពីការកែប្រែអនុសញ្ញាទាសភាព ឆ្នាំ១៩២៦។<br>- ពិធីសារធ្វើវិសោធនកម្ម គឺជាឯកសារមួយដែលចែងអំពីបទបញ្ញត្តិទាក់ទងនឹងវិសោធនកម្មលើចំណុចណាមួយ ឬ ចំណុចមួយចំនួន នៃសន្ធិសញ្ញាដើម, ឧ. ពិធីសារជម្រើសនៃទីក្រុងវីយែន ឆ្នាំ១៩៦១ ស្ដីពីទំនាក់ទំនងការទូតដែលផ្ដោតទៅលើការដោះស្រាយជម្លោះដោយបង្ខំ។ |
| ៣៦- **នយោបាយកលិយុគ**<br>អ. chaotic politics<br>បារ. politique chaotique | ស្ថានភាពវឹកវរទាំងឡាយដែលបង្កើតឡើងដោយអ្នកដឹកនាំឬអ្នកនយោបាយ ក្នុងសម័យកាលណាមួយ ក្នុងគោលបំណងដណ្ដើមយកអំណាចឬដោះដូរអំណាច តាមរយៈមហាជន និង តាមមធ្យោបាយផ្សេងៗទៀត។<br>ឧ. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៣ សហរដ្ឋអាមេរិកបានធ្វើសង្គ្រាមបណ្ដេញលោក សាដាំ ហ៊ូសេន ប្រធានាធិបតីប្រទេសអ៊ីរ៉ាក់ ចេញពីអំណាច ដោយចោទប្រកាន់ថា បានផលិតអាវុធនុយក្លេអ៊ែ អាវុធគីមី និង ដឹកនាំប្រទេសផ្ដាច់ការ ។ ផ្ទុយទៅវិញ តាមរយៈរបាយការណ៍អង្កេតជាក់ស្ដែងរបស់ភ្នាក់ងារជំនាញអង្គការសហប្រជាជាតិ ពុំបានរកឃើញភស្តុតាងណាមួយបញ្ជាក់ថា ប្រទេសអ៊ីរ៉ាក់បានផលិតអាវុធ ដូចចោទប្រកាន់នោះទេ។ |
| ៣៧- **នយោបាយទន់ភ្លន់**<br>អ. flexible politics<br>បារ. politique flexible | នយោបាយការទូតដែលប្រើប្រាស់ក្នុងការធ្វើទំនាក់ទំនងដែលមានលក្ខណៈប្រុងប្រយ័ត្ន ដោយធ្វើការសិក្សាស៊ីជម្រៅទៅលើអរិយធម៌របស់ប្រទេស ក្រុម ឬ បុគ្គលនោះ ជាមុនសិន មុននឹងធ្វើទំនាក់ទំនងទៅលើបញ្ហាណាមួយ។ នយោបាយទន់ភ្លន់នេះ ក៏គេអាចប្រើប្រាស់សម្រាប់ធ្វើការដោះស្រាយនយោបាយផ្ទៃក្នុងផងដែរ, ឧទាហរណ៍ :<br>- ការដោះស្រាយជម្លោះបញ្ហានៅមជ្ឈិមបូព៌ា សហរដ្ឋអាមេរិកបានប្រើប្រាស់នយោបាយទន់ភ្លន់ ដើម្បីសិក្សាទៅលើទំនៀមទម្លាប់ប្រពៃណីរបស់មជ្ឈិមបូព៌ា ដោយមិនប្រើច្បាប់អន្តរជាតិ ឬ ការទូតទាំងស្រុងទេ។<br>- ការជាប់គាំងនយោបាយក្រោយពីការបោះឆ្នោតឆ្នាំ២០០៣ អស់រយៈពេល១ឆ្នាំមក |

| | |
|---|---|
| | សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រើប្រាស់នយោបាយទន់ភ្លន់ ដើម្បីចូលចរចាជាមួយដៃគូហ៊ុនស៊ិនប៉ិច ។ |
| ៣៨- **នយោបាយបង្កក**<br>អ. frozen politics<br>បារ. gel politique | នយោបាយដែលផ្តាច់ទំនាក់ទំនងជាមួយប្រទេសណាមួយ ឬ ក្រុមណាមួយ ដែលបានប៉ះ-ពាល់ផលប្រយោជន៍ដល់ប្រទេសឬក្រុមនោះ ។ នយោបាយបង្កក គឺមានន័យថា បញ្ឈប់ទំនាក់ទំនងការបរទេស ការទូត និង ផ្នែកសេដ្ឋកិច្ច ។ នយោបាយនេះកើតឡើងតែនៅក្នុងរយៈពេលណាមួយដែលភាគីទាំងសងខាងមិនទាន់ឯកភាពឬស្រុះស្រួលគ្នា ។<br>ឧ. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ ក្រោយពីមានទំនាស់រវាងសហព័ន្ធរុស្ស៊ីនិងហ្សកហ្ស៊ី (Georgia) បានធ្វើឱ្យសហគមន៍អឺរ៉ុប និង សហរដ្ឋអាមេរិក បង្កកទំនាក់ទំនងជាមួយរុស្ស៊ី ។ ឯរុស្ស៊ីវិញបានឆ្លើយតបនឹងសហគមន៍អឺរ៉ុប ដោយធ្វើនយោបាយបង្កកវិញ តាមរយៈការផ្តាច់ការផ្គត់ផ្គង់ថាមពលឧស្ម័ន ដោយចោទអ៊ុយក្រែន ថាបានបូមយកឧស្ម័ន ប្រាសចាកពីកិច្ចព្រមព្រៀង ដែលធ្វើឱ្យទំនាស់នេះកាន់តែមានសភាពប្រឈមដាក់គ្នាកាន់តែតានតឹងឡើងរវាងរុស្ស៊ីនិងអឺរ៉ុប រហូតដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៩ ទើបមានជំនួបទ្វេភាគីរវាងនាយករដ្ឋមន្ត្រីអ៊ុយក្រែន និង នាយករដ្ឋមន្ត្រីសហព័ន្ធរុស្ស៊ី ដើម្បីធ្វើការដោះស្រាយបញ្ហានេះ ដោយមានការចូលរួមពីប្រទេសបារាំង អ៊ីតាលី អេស្ប៉ាញ អាល្លឺម៉ង់ ផង ។ |
| ៣៩- **បទដ្ឋានសង្គ្រាម**<br>អ. rule of war<br>បារ. droit de la guerre | វិធានទាំងឡាយណាដែលមានចែងនៅក្នុងច្បាប់អន្តរជាតិនិងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងសង្គ្រាម ។ សិទ្ធិនិងកាតព្វកិច្ចដែលភាគីពាក់ព័ន្ធនៅក្នុងសង្គ្រាម ត្រូវគោរពពេលធ្វើសង្គ្រាម មានដូចខាងក្រោម :<br>១- ក្នុងអំឡុងពេលមានសង្គ្រាម ការសម្លាប់ជនស៊ីវិលគ្មានអាវុធដោយចេតនា មិនត្រូវបានអនុញ្ញាតឡើយ ។<br>២- ទាហានម្ខាងមិនអាចសម្លាប់ឬធ្វើឱ្យរបួសដល់ទាហានម្ខាងទៀត ដែលបានចុះចូលហើយនោះទេ ។<br>៣- មន្ទីរពេទ្យមិនត្រូវបានប៉ះពាល់ឬវាយប្រហារទេ ក្នុងពេលមានសង្គ្រាម ។<br>៤- ឈ្លើយសឹកមិនត្រូវបានគេប្រព្រឹត្តដោយអមនុស្សធម៌ឬធ្វើទារុណកម្មទេ ។<br>៥- ការចាប់យកឬសម្លាប់ចំណាប់ខ្មាំងមិនត្រូវអនុញ្ញាតឡើយ ។<br>៦- ទាហានត្រូវពាក់ឯកសណ្ឋានដើម្បីឱ្យគេបានស្គាល់អត្តសញ្ញាណច្បាស់លាស់ ជៀស-វាងការច្រឡំជាមួយជនស៊ីវិល ។<br>៧- សមរភូមិត្រូវធ្វើឱ្យឆ្ងាយពីតំបន់ទីក្រុងដែលមានប្រជាជនរស់នៅ ។<br>៨- នៅពេលត្រូវវាយប្រហារទៅលើទីក្រុង ត្រូវទុកពេលវេលាសម្រាប់ជម្លៀសជនស៊ីវិលចេញ ។<br>៩- ជនស៊ីវិលស្លូតត្រង់ត្រូវទទួលការគាំពារ ។ |
| ៤០- **បទល្មើសសង្គ្រាម**<br>អ. war crime | ការរំលោភខាងយោធាទៅលើបទដ្ឋាននៃការធ្វើសង្គ្រាម រួមមាន សកម្មភាពឃោរឃៅការធ្វើទុក្ខបុកម្នេញ នៅក្នុងពេលធ្វើសង្គ្រាម ។ បទល្មើសសង្គ្រាមរួមមាន : |

| | |
|---|---|
| បារ. | ១- ការប្រើប្រាស់អាវុធដែលហាមឃាត់<br>២- ការមិនយកចិត្តទុកដាក់ដល់អ្នកជំងឺ ឬ អ្នករបួស<br>៣- ការរំលោភបំពានរថយន្តដែលមានទង់ ឬ សញ្ញាកាកបាទក្រហម<br>៤- ការបំពានដោយមិនដោះលែងអ្នកទោស ឬ ដោយបទឈប់បាញ់គ្នា<br>៥- ការសម្លាប់ចំណាប់ខ្មាំង<br>៦- ការសម្លាប់រង្គាលជនមិនមែនស៊ីវិល ឬ បច្ចាមិត្ត ដែលបានចុះចូល<br>៧- ការបំផ្លាញនាវាចម្បាំងដោយមិនបានយកអ្នកដំណើរ ឬ បុគ្គលិកនាវាទៅដាក់កន្លែងមានសុវត្ថិភាព<br>៨- ការទម្លាក់គ្រាប់បែកលើទីកន្លែងដែលគ្មានរបាំងការពារអ្វីទាំងអស់ ឬ អគារនានាដែលមិនមែនជាគោលដៅខាងយោធា ។ |

# បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ មនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| ១- **កសិកម្មចិញ្ចឹមពោះ**<br>អ. agriculture of subsistence<br>បារ. agriculture (f.) de subsistance (f.) | កសិកម្មសម្រាប់ផ្គត់ផ្គង់ស្បៀងក្នុងគ្រួសារ ដើម្បីការរស់រានមានជីវិត ដោយមិនសំដៅទៅលើការលក់ដូរ ឬ ធ្វើពាណិជ្ជកម្មទេ ។<br>ឧ. ជនជាតិដើមភាគតិចនៃប្រទេសកម្ពុជាយើងច្រើនតែប្រកបរបរកសិកម្មចិញ្ចឹមពោះ ។ |
| ២- **បន្សាំអាកាសធាតុ**<br>អ. acclimatization<br>បារ. acclimatation (f.) | ការសម្របខ្លួនទៅនឹងអាកាសធាតុថ្មី ក្រោយពីធាតុអាកាសបានប្រែប្រួល ឬ ក្រោយពីមានការផ្លាស់ប្តូរទីកន្លែងដែលមានអាកាសធាតុប្លែកពីកន្លែងចាស់ ( មិនថា មនុស្ស សត្វ ឬ រុក្ខជាតិឡើយ) ។<br>ឧ. ជនជាតិនៃទ្វីបអាស៊ីបន្សាំខ្លួននឹងអាកាសធាតុ នៅពេលដែលមានបម្លាស់ទីទៅរស់នៅក្នុងទ្វីបផ្សេង ។ |
| ៣- **រំលេចទី**<br>អ. outcrop<br>បារ. affleurement (m.) de terrain (m.) | ទីកន្លែងដែលមានថ្មផុសពីដី ។ ទីលាននៃសិលានៅដីក្រោមលេចឡើងមកផ្ទៃខាងលើបង្កើតបានទីលាននៃសិលានៅលើផ្ទៃដី ។<br>ឧ. នៅប្រទេសកម្ពុជា គេឃើញមានរំលេចទីនៅតាមតំបន់មាត់សមុទ្រ ភ្នំតាម៉ៅ ( ក្នុងខេត្តតាកែវ) ។ ល ។ |
| ៤- **រដ្ឋវាសី/អាទិកាលិកា**<br>អ. aborigine<br>បារ. aborigène (m.) | អ្នកស្រុកដើម ។ បើអ្នកស្រុកដើមជាភេទស្រី ពាក្យនេះត្រូវប្តូរទៅជា "រដ្ឋវាសិនី " វិញ ។ ពាក្យ រដ្ឋវាសី ត្រូវបានបង្កើតឡើង ដើម្បីប្រែពាក្យ aborigine ដែលគេបានបង្កើតនៅឆ្នាំ១៨៤៨ ។ ដំបូងឡើយ គេប្រើពាក្យ aborigine នេះ សម្រាប់សម្គាល់តែជនជាតិដើមដែលមានកំណើតនិងរស់នៅក្នុងប្រទេសអូស្ត្រាលី តាំងពីអំឡុង៥០០០០ឆ្នាំមុនមកម្លេះ ។ ប៉ុន្តែបច្ចុប្បន្ន ពាក្យនេះក៏ត្រូវបានគេប្រើសម្រាប់ហៅចំពោះពួកជនជាតិដើមស្បែកក្រហម |

| | |
|---|---|
| | នៅក្នុងប្រទេសកាណាដា និង ពួកអេស្គីម៉ូ ផងដែរ ។<br>ឱ. Aboriginal Australia, Aborigène d'Australie ។<br>នៅពេលចក្រភពអង់គ្លេសចូលមកដាក់អាណានិគមឆ្នាំ១៧៨៨ លើទ្វីបនេះ គេឃើញជនជាតិ ដើមនេះមានភាសាដើមរបស់ខ្លួនប្រមាណជាង២០០ឯណោះ ។ |
| ៥- **កសិម្ហូបអាហារ**<br>អ. agro alimentary<br>បារ. agro-alimentaire | សាខានៃផលិតកម្មឧស្សាហកម្មដែលមានមូលដ្ឋានលើការកែច្នៃផលិតផលកសិកម្ម រុក្ខជាតិ សត្វ ផលិតផលនេសាទនិងវារីវប្បកម្ម ដើម្បីផលិតចំណីអាហារសម្រាប់មនុស្ស និង សត្វ , ឧទាហរណ៍ :<br>- ដំឡូងមីជាដំណាំកសិកម្មមួយដែលបម្រើឱ្យវិស័យកសិម្ហូបអាហារ ដូចជា សម្រាប់យកទៅផលិតជាម្សៅមីហើយម្សៅមីនេះគេអាចយកទៅផលិតជាអាហារបានច្រើនប្រភេទ,<br>- ផ្សិតជាដំណាំកសិកម្មមួយដែលបម្រើឱ្យវិស័យកសិម្ហូបអាហារ ដូចជា សម្រាប់យកទៅផលិតជាផ្សិតកំប៉ុងឬផ្សិតក្រៀម,<br>- ត្រីកាម៉ុងជាផលនេសាទមួយដែលបម្រើឱ្យវិស័យកសិម្ហូបអាហារដូចជា សម្រាប់យកទៅផលិតជាត្រីខកំប៉ុង,<br>- ការចិញ្ចឹមបង្កង បង្គា ក្តាម គ្រំ សារាយសមុទ្រ ជាដើមក៏បម្រើឱ្យវិស័យកសិម្ហូប-អាហារ ដែរ ។ |
| ៦- **កសិពាណិជ្ជកម្ម**<br>អ. agro business<br>បារ. agrobusiness | ឧស្សាហកម្មមួយដែលទាក់ទងនឹងការផលិតនិងការលក់ផលិតផលកសិកម្ម ជាពិសេសគ្រប់គ្រងដោយក្រុមហ៊ុនធំៗ ។ ជាទូទៅ វាមាននៅក្នុងបណ្តាប្រទេសអភិវឌ្ឍ ដែលផ្ទុយទៅនឹងបែបផែនផលិតកម្មរបស់កសិករ ។<br>ឧ. ដំណាំកៅស៊ូ ដូងប្រេង ។ |
| ៧- **ផ្លូវយក្ស**<br>អ. giant’s causeway<br>បារ. chaussée de géant | លំហូរនៃកម្អែភ្នំភ្លើងបង្កើតបានជាទម្រង់ផ្លូវ (ផ្លូវយក្ស) ដែលនៅលើផ្លូវនេះមានថ្មធម្ម-ជាតិ រាងជាព្រីសស្ទើរជ្រុង សណ្ឋានដូចសសរឆកោណ ។ ទ្រង់ទ្រាយនេះកើតឡើងពីការចុះត្រជាក់នៃកម្អែភ្នំភ្លើង ។<br>ឧ. ផ្លូវយក្សនៅអៀរឡង់ខាងជើង ជាតំបន់ទេសចរណ៍ភ្នំភ្លើង និង ឆ្នេរសមុទ្រ ។ |
| ៨- **ឈីកាណូ**<br>អ. chicano<br>បារ. chicano (m.) | ជនជាតិភាគតិចដែលរស់នៅលើទឹកដីសហរដ្ឋអាមេរិក ។ ជនជាតិនេះមានប្រភពដើមមកពីប្រទេសម៉ិកស៊ិកនិងអាមេរិកឡាទីន ។ ជនជាតិឈីកាណូនៅលើទឹកដីសហរដ្ឋអាមេ-រិក មានកំណើនឆាប់រហ័ស ហើយ ប្រពៃណីទំនៀមទម្លាប់ពួកគេ ងាយធ្វើសមាហរណកម្មក្នុងសង្គមអាមេរិក ។ |
| ៩- **ឆុត**<br>អ. chott<br>បារ. chott (m.) | នៅលើផែនទីនិងនៅក្នុងការហៅទូទៅ "ឆុត" គឺជាបឹងទឹកប្រៃមិនដែលរីង ស្ថិតក្នុងតំបន់ស្ទើរហួតហែង ហើយត្រើយរបស់វាប្រែប្រួលទៅតាមរបបទឹកភ្លៀង ។ ពាក្យនេះជាពាក្យអារ៉ាប់ ដែលគេប្រើប្រាស់នៅអាហ្វ្រិកខាងជើង មានន័យថា "ត្រើយ" ។ អ្នកជំនាញខាង |

| | |
|---|---|
| | ភូមិសណ្ឋានបានកម្រិតដែនរបស់ "ឆុត" គឺជាផ្នែកនៃត្រើយនៅជុំវិញបឹង ហើយមានរុក្ខ-ជាតិដុះខ្លះៗ ដែលជួនកាលលិចទឹក ជួនកាលផុតពីទឹក ។<br>"ឆុត" ទទួលទឹកពីភ្លៀងកម្រមាន ហើយទទួលរងនូវរំហួតដ៏ខ្លាំងក្លា វាបង្កជាតិអំបិលនៅលើផ្ទៃនៃល្បាប់ម៉ត់ មានទ្រង់ទ្រាយជាក្រមរដែលមានកម្រាស់ប្រែប្រួលនិងស្ថិតស្ថេរ ហើយ ដែលជួនកាលគេធ្វើអាជីវកម្មអំបិលនៅទីនោះ . ឧទាហរណ៍ :<br>- សមុទ្រអារ៉ាល់ (Aral Sea) គឺជាឆុតមួយដែរ ក៏ប៉ុន្តែគេបែរជាមិនប្រើពាក្យនេះ សម្រាប់ហៅសមុទ្រនេះទេវិញ ។<br>- ឆុត ដេរីដ (Djerid) នៅពីមុខក្រុងតូស័រ (Tozeur) នៃប្រទេសទុយនីស៊ី ។ |
| ១០- **កុំប៊ីណា**<br>អ. complex<br>បារ. combinat (m.) | អង្គភាពពីរឬច្រើនដែលដំណើរការបំពេញគ្នាទៅវិញទៅមក ហើយ ស្ថិតនៅក្រោមការគ្រប់គ្រងរួម ។<br>ឧ. អណ្តូងរ៉ែនិងរោងចក្រប្រព្រឹត្តិកម្ម ។ ពាក្យនេះត្រូវបានគេប្រើប្រាស់ទូលំទូលាយនៅប្រទេសជប៉ុន សម្រាប់សំណុំឧស្សាហកម្មធុនធ្ងន់ ។ល ។ កុំប៊ីណាដែលល្បីល្បាញជាងគេ គឺ កុំប៊ីណាដែលផ្សារភ្ជាប់រ៉ែដែកនៃជួរភ្នំអ៊ូរ៉ាល់ (Oural) ទៅនឹងរ៉ែធ្យូងថ្មនៃតំបន់ស៊ីបេរីកណ្តាល ។ |
| ១១- **អេគូមែន**<br>អ. oekoumen<br>បារ. écoumène (m.) , ekoumène (m.) | ផ្នែករបស់ផែនដីដែលមនុស្សលោកអាចរស់នៅបាន ។ |
| ១២- **អព្យព / ដ្យាស្ប៉ូរ៉ា**<br>អ. diaspora<br>បារ. diaspora (f.) | ការបែកខ្ញែកគ្នានៃក្រុមមួយឬជាតិសាសន៍មួយ ហើយ ប្រមូលផ្តុំគ្នាទៅរស់នៅទីកន្លែងផ្សេងៗនៃពិភពលោក ។ ឧ. អព្យព / ដ្យាស្ប៉ូរ៉ា ជ្វីហ្វ ។<br>បច្ចុប្បន្ន ពាក្យនេះមានន័យថា ដំណើរបែកខ្ញែកនៃប្រជាជាតិមួយនៅក្នុងពិភពលោក ។<br>ឧ. អព្យព / ដ្យាស្ប៉ូរ៉ា អាមេនី លីបង់ ឥណ្ឌា ចិន ជាដើម ។ |
| ១៣- **ហ្វៀល**<br>អ. fjeld<br>បារ. fjeld (m.) | ខ្ពង់រាបដែលត្រូវបានពង្រាបដោយសារផ្ទាំងទឹកកកនៃស័កទី៤ ដែលនៅទីនោះមានផែនសិលាសណ្ឋានដូចរោមចៀម និង កាករបស់ទន្លេទឹកកក និង ផ្លូវទឹកហូរមួយដែលមិនពេញលេញជាមួយនឹងត្រពាំងនិងអណ្តូងរ៉ែធ្យូងតូប ។<br>ឧ. ហ្វៀលន័រវែស ។ |
| ១៤- **អាតូល / កោះផ្កាថ្ម**<br>អ. atoll<br>បារ. atoll (m.) | ផ្កាថ្មប៉ប្រះទឹក ដែលព័ទ្ធជុំវិញត្រពាំងទឹកប្រៃ ។ វាកកើតឡើងដោយបន្ទះនៃថ្មប៉ប្រះទឹកជាច្រើន ដែលជាទូទៅមានរាងមូល ។<br>ឧ. កោះផ្កាថ្ម Tokelau, Tuamotu, Tuvalu នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ជាដើម ។ |
| ១៥- **កាំជ្រួចទឹកក្តៅ**<br>អ. geyser<br>បារ. geyser (m.) | ខ្សែទឹកក្តៅឬចំហាយទឹកដែលបាញ់ចេញមកពីក្នុងដី ។ ជាទូទៅ វាមានទំនាក់ទំនងជាមួយនឹងសកម្មភាពនៃបន្ទុះភ្នំភ្លើង ហើយ កកើតឡើងដោយការឡើងកម្តៅនៃទឹកក្រោមដីដែលកើតឡើងពីប្រព័ន្ធម៉ាក់ម៉ា ។ |
| ១៦- **ហ្វ្យ៉រ/ដៃសមុទ្រចង្អៀត** | ដៃសមុទ្រដែលលាតសន្ធឹងយ៉ាងវែងឆ្ងាយពីមាត់សមុទ្រទៅលើជ្រលងទឹកកកដោយសារ |

| | |
|---|---|
| អ. fjord / fiord<br>បារ. fjord / fiord (m.) | ជំនន់សមុទ្រក្នុងអំឡុងពេលកំណើនកម្ពស់ទឹកសមុទ្រ នាសម័យទឹកកក ។<br>ឧ. ដៃសមុទ្រចង្អៀត Sogn Fjord នៅប្រទេសន័រវែស ។ |
| ១៧- **ប៉េរីហេលី**<br>អ. perihelion<br>បារ. périhélie (m.) | ចំណុចនៃគន្លងរបស់ភពទាំងឡាយក្នុងប្រព័ន្ធព្រះអាទិត្យ ដែលស្ថិតនៅជិតបំផុតនឹងព្រះអាទិត្យ ។ ឧ. ផែនដីស្ថិតនៅប៉េរីហេលីក្នុងខែកក្កដា ។ |
| ១៨- **អាហ្វេលី**<br>អ. aphelion<br>បារ. aphélie (m.) | ចំណុចនៃគន្លងរបស់ភពទាំងឡាយក្នុងប្រព័ន្ធព្រះអាទិត្យ ដែលស្ថិតនៅឆ្ងាយបំផុតពីព្រះអាទិត្យ ។ ឧ. ផែនដីស្ថិតនៅអាហ្វេលីនៅក្នុងខែមករា ។ |
| ១៩- **បរិវេណ (សាកលវិទ្យាល័យ)**<br>អ. .campus<br>បារ. campus (m.) | នៅក្នុងវប្បធម៌អង់គ្លេស-អាមេរិក ពាក្យនេះ សំដៅដល់អគារទាំងឡាយនៃសាកលវិទ្យា-ល័យ វិទ្យាល័យ និង ទីធ្លានៅជុំវិញ ។ |
| ២០-**ខ្យល់ឆាយនូក**<br>អ. chinook<br>បារ. chinook (m.) | ពាក្យរបស់រដ្ឋវាសីនៃទ្វីបអាមេរិក (ជនជាតិឥណ្ឌាស្បែកក្រហម) ។ ឆាយនូកសំដៅដល់ខ្យល់ក្តៅស្ងួតដែលបក់បោកនៅផ្នែកខាងកើតនៃភ្នំថ្ម (Rocky Mountains) នាចុងសិសិររដូវ នៅសហរដ្ឋអាមេរិក។ វាជាប្រភេទខ្យល់ហ្វឺន (Foehn) ដែលនៅរដូវស្លឹកឈើលាស់ខ្យល់នេះរួមចំណែកយ៉ាងសកម្មធ្វើឱ្យរលាយទឹកកកនៃតំបន់វាល (Prairie) នៅសហរដ្ឋអាមេរិក ហេតុដូច្នេះហើយបានជាធ្វើឱ្យដំណាំស្រូវសាលីលូតលាស់ល្អ ។ |
| ២១-**ទីលានស្មៅកីឡា**<br>អ. bowling green<br>បារ. boulingrin (m.) | ទីលានស្មៅល្អិតខ្លីៗដែលមានព្រំកំណត់សម្រាប់លេងដុំបោះ ។<br>(Le petit Larousse illustré ឆ្នាំ១៩៩១) |
| ២២-**បេកេ**<br>អ. white creole<br>បារ. béké (m.) | ជនស្បែកសកើតនៅលើប្រជុំកោះអង់ទី ។ |
| ២៣-**លម្អដី**<br>អ. enrichment<br>បារ. amendement (m.) | សកម្មភាពកែលម្អគុណភាពដីដាំដុះឱ្យមានជីជាតិ ។<br>ឧ. ដើម្បីទទួលបានទិន្នផលខ្ពស់ កសិករតែងតែធ្វើលម្អដីជារៀងរាល់រដូវដាំដុះ ។ |
| ២៤-**នគរូបនីយកម្ម**<br>អ. urbanisation<br>បារ. urbanisation (f.) | ការអភិវឌ្ឍនិងការកើនឡើងខាងបរិមាណនៃប្រជាជនរស់នៅទីក្រុង ។ |
| ២៥-**ដៃឆ្នេរ**<br>អ. cove<br>បារ. anse (f.) | (ភូមិវិទ្យា) ឆកតូចដែលលយចូលក្នុងច្រាំងសមុទ្រ និង មានជម្រៅល្មម ។ |
| ២៦- **អាប៉ារថេដ**<br>អ. apartheid<br>បារ. apartheid (m.) | អាប៉ារថេដ ជាពាក្យអាហ្វ្រិកខាងត្បូង (afrikaans) ដែលគេបានស្គាល់ជាសកល មានន័យថា "ការខណ្ឌ" ឬ "ការដាក់ឱ្យនៅដោយឡែក" ។ អាប៉ារថេដជាប្រព័ន្ធនៃនយោបាយមួយដែលតាំងឡើងនៅប្រទេសអាហ្វ្រិកខាងត្បូងពីឆ្នាំ១៩៤៨ដល់ទសវត្សឆ្នាំ៩០ ដោយឈរលើការប្រកាន់ពូជសាសន៍និងការសង្កត់សង្កិនទៅលើប្រជាជនស្បែកខ្មៅភាគច្រើនពីសំណាក់ប្រជាជនស្បែកសភាគតិចដែលកាន់អំណាច ដោយមិនឱ្យលាយឡំប្រជាជនស្បែក |

| | |
|---|---|
| | ខ្ទៅជាមួយប្រជាជនស្បែកស ។ |
| ២៧- **វារីវប្បកម្ម**<br>អ. aquaculture<br>បារ. aquaculture (f.) | សំណុំនៃសកម្មភាពអាជីវកម្មនៃរុក្ខជាតិនិងសត្វនៅតាមសមុទ្រ ទន្លេ ព្រែក ស្ទឹង និង ត្រពាំង ។ |
| ២៨- **រុក្ខវប្បកម្ម**<br>អ. arboriculture<br>បារ. arboriculture (f.) | ដំណាំដើមឈើឬកូនឈើដើម្បីរកប្រាក់ចំណូល ។ ដំណាំដើមឈើឬកូនឈើដើម្បីប្រើ-ប្រាស់ឬក៏លម្អ ។ រុក្ខវប្បកម្មសំដែងឡើងដោយសួនឈើ ។<br>ឧ. ប្រជាជនកម្ពុជាភាគច្រើន នៅសម័យបច្ចុប្បន្ន បានបង្កើនប្រាក់ចំណូលរបស់ខ្លួនតាមរយៈវិស័យរុក្ខវប្បកម្មយ៉ាងផុលផុស ។ |

## បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ វប្បធម៌ និង វិចិត្រសិល្បៈ ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| ១- **វប្បធម៌**<br>អ. culture<br>បារ. culture (f.) | ការបណ្ដុះចំណេះវិជ្ជា ប្រាជ្ញាស្មារតី និង របៀបរស់នៅរបស់មនុស្ស ឱ្យបានលូតលាស់ចម្រើនដើម្បីសម្របសម្រួលទៅនឹងបរិស្ថាន និង ការអភិវឌ្ឍសង្គមដោយវិទ្យាសាស្ត្រ ឬ ដោយសិល្បៈផ្សេងៗ ជាដើម ។ |
| ២- **វិចិត្រ**<br>អ. fine<br>បារ. beau (adj.) | ដែលមានគុណវុឌ្ឍិនិងសោភណភាព ប្រកបដោយការរំលេចពណ៌ឬក្បាច់រចនា និង សម្រស់ល្អប្លែក ។ |
| ៣- **សិល្បៈ**<br>អ. art<br>បារ. art (f.) | ការងារជំនាញហត្ថកម្មនិងបញ្ញាពលកម្មដែលជាស្នាដៃគ្រប់បែបយ៉ាងដែលមានសិល្ប៍ ពោលគឺធ្វើឱ្យមនុស្សចាប់ចិត្តចាប់អារម្មណ៍ ចង់មើល ចង់ឃើញ ចង់ស្គាល់ ។ សិល្បៈមានច្រើនប្រភេទណាស់ ដូចជា សិល្បៈរបាំ ចម្រៀង ភ្លេង ល្ខោន គំនូរ សំណង់ សូនរូប ។ ល ។ |
| ៤- **វិចិត្រសិល្បៈ**<br>អ. fine art<br>បារ. beaux arts (m.) | ការងារជំនាញហត្ថកម្មនិងបញ្ញាពលកម្មដែលជាស្នាដៃគ្រប់បែបយ៉ាង កើតចេញពីភាពប៉ិនប្រសប់នៃគំនិតប្រាជ្ញាល្អប្លែករបស់មនុស្សប្រកបដោយ សោភណភាព សិល្ប៍ គំនិតច្នៃ-ប្រឌិត ទាក់ទងទៅនឹងការសម្ដែង ការតែងនិពន្ធ ការប្រគុំ ការរាំ ការច្រៀង ការគូរ ការឆ្លាក់ ដើម្បីឱ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់ទស្សនា ចង់ឃើញ ចង់ស្គាល់ ចង់ស្ដាប់,... ។ |
| ៥- **បុរាណវត្ថុវិទ្យា**<br>អ. archeology<br>បារ. archéologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីវប្បធម៌របស់មនុស្សនៅសម័យបុរាណតាមរយៈវត្ថុសំណល់ផ្សេងៗ ដូចជា វត្ថុសិល្បៈ សំណង់ប្រាសាទ ឆ្អឹងមនុស្សនិងសត្វ ជាដើម ។ |
| ៦- **អ្នកបុរាណវត្ថុវិទ្យា**<br>អ. archeologist<br>បារ. archéologue (m.) | អ្នកដែលបានសិក្សាស្រាវជ្រាវកម្រិតឧត្តមនិងប្រកបអាជីពផ្នែកបុរាណវត្ថុវិទ្យា ។ |
| ៧- **ស្ថានីយ** | ទីកន្លែងនៃសកម្មភាពគ្រប់ប្រភេទរបស់មនុស្សពីសម័យបុរាណ ដូចជា ទីកន្លែងសម្រាប់ |

| | |
|---|---|
| អ. site<br>បារ. site (m.) | សម្នាក់, ទីកន្លែងសម្រាប់ឈប់, ទីកន្លែងសម្រាប់ចត,...។ |
| ៨- **បុរាណវត្ថុវិទូ**<br>អ. archeologist<br>បារ. archéologue (m.) | អ្នកប្រាជ្ញខាងបុរាណវត្ថុវិទ្យា។ |
| ៩- **ស្ថានីយបុរាណវត្ថុវិទ្យា .**<br>អ. archeological site<br>បារ. site (m.) archéologique | ទីកន្លែងនៅលើដី ក្នុងដី ក្រោមទឹក ដែលមានស្នាមឬវត្ថុសំណល់ផ្សេងៗពីសម័យបុរាណ ដូចជា បុរាណវត្ថុសិល្បៈ បុរាណអចលនវត្ថុ បុរាណជីវវត្ថុ បុរាណភូគព្ភវត្ថុនិងរចនាសម្ព័ន្ធសំណង់។<br>ឧ. ស្ថានីយបុរាណវត្ថុវិទ្យាសំរោងសែន ។ |
| ១០- **និម្មាបនកម្ម / ស្ថាបត្យកម្ម**<br>អ. architecture<br>បារ. architecture (f.) | វិទ្យាសាស្ត្រនិងសិល្បៈនៃការគូរប្លង់ក្នុងការសាងឬតាក់តែង ដែលបង្កប់គំនិតបង្កើតថ្មី ស្របតាមមុខងារនិងតួនាទី ដែលមានអត្ថន័យក្នុងវិស័យវប្បធម៌ សេដ្ឋកិច្ច នយោបាយ និងការអប់រំ ជាដើម។<br>រចនាសម្ព័ន្ធ(ភាគផ្សំ) នៃអគារដែលបានសាងសង់ទៅតាមគោលការណ៍ណាមួយ។<br>ឧ. គួរស្ញើចសរសើរនូវនិម្មាបនកម្មឬស្ថាបត្យកម្មនៃប្រាសាទនគរវត្ត។ |
| ១១- **និម្មាបនិក / ស្ថាបត្យករ**<br>អ. architect<br>បារ. architecte (m./f.) | អ្នកមានអាជីពខាងនិម្មាបនកម្ម។ អ្នកកាន់កាប់មុខការខាងសម្របសម្រួលនិងត្រួតពិនិត្យរាល់ទិដ្ឋភាពនៃសំណង់អគារ។ |
| ១២- **និម្មាបនវិទូ / ស្ថាបត្យវិទូ**<br>អ. architect<br>បារ. architecte (m./f.) | អ្នកប្រាជ្ញដែលមានជំនាញឯកទេសខាងនិម្មាបនកម្មឬស្ថាបត្យកម្ម។ |
| ១៣- **ប្លង់**<br>អ. plan<br>បារ. plan (m.) | - គំនូសបំប្រួញពីរវិមាត្រ (2 Dimension or 2D) ដែលមានខ្នាតបញ្ជាក់ដោយបង្ហាញអំពីទីតាំងនិងទំហំឬផ្ទៃកណាមួយ។<br>- ផែនទីលម្អិតដែលបង្ហាញពីអគារ ឬ ទីក្រុង, គំនូរលម្អិតដែលបង្ហាញពីអគារ។<br>- ផែនទីផ្ទៃរាបខ្នាតតូចដែលជាកំណត់ត្រាដោយគំនូស បង្ហាញពីទម្រង់និងលក្ខណៈទីតាំងនៃបុរាណវត្ថុសិល្បៈ បុរាណអចលនវត្ថុ បុរាណសរីរវត្ថុ បុរាណភូគព្ភវត្ថុ និង រចនាសម្ព័ន្ធសំណង់ ដែលអាចមើលឃើញនៅក្នុងស្ថានីយឬរណ្ដៅកំណាយ។ |
| ១៤- **និម្មាបនកម្មទេសភាព / ស្ថាបត្យកម្មទេសភាព**<br>អ. landscape architecture<br>បារ. architecture (f.) paysagiste | វិទ្យាសាស្ត្រនិងសិល្បៈនៃការគូរប្លង់ទេសភាពនិងបង្កើតទេសភាពដោយប្រើប្រាស់ធនធានធម្មជាតិជាធាតុផ្សំ : រុក្ខជាតិ(ដើមផ្កា ស្មៅ ដើមឈើ វល្លិ៍) ថ្មល់ សំណង់ អគារ ថ្មភ្នំ បឹង,..។<br>ឧ. និម្មាបនកម្មទេសភាពឬស្ថាបត្យកម្មទេសភាពខ្មែរមានតាំងពីសតវត្សរ៍ទី៥ម្ល៉េះ គឺទីក្រុងស្រេស្ឋបុរៈ(រាជធានីចេនឡា)នៅស្រុកចម្ប៉ាសាក់ ខេត្តចម្ប៉ាសាក់ ប្រទេសឡាវ។ ទីក្រុងស្រេស្ឋបុរៈមានប្រាសាទមួយគឺប្រាសាទវត្តភូ សាងលើចង្កេះភ្នំលិង្គ ដោយយកផ្ទាំងថ្មធម្មជាតិ ជាឆាកធម្មជាតិនៅពីក្រោយប្រាសាទវត្តភូ និង នៅខាងមុខប្រាសាទមានទន្លេមេគង្គ។ ស្រេស្ឋបុរៈជាទីក្រុងមានប្លង់មុនគេនៅអាស៊ីអាគ្នេយ៍។ ក្រុងស្រេស្ឋបុរៈនិងប្រាសាទវត្តភូជាបេតិកភណ្ឌពិភពលោក។ |

| | |
|---|---|
| ១៥- **និម្មាបនិកទេសភាព / ស្ថាបត្យករទេសភាព**<br>អ. landscape architect<br>បារ. architecte (m.) paysagiste | អ្នកមានអាជីពខាងនិម្មាបនកម្មទេសភាពឬស្ថាបត្យកម្មទេសភាព។ |
| ១៦- **ការតាក់តែងលម្អនិម្មាបនកម្ម** ឬ **ការតាក់តែងលម្អស្ថាបត្យកម្ម**<br>អ. architectural decoration<br>បារ. décoration (f.) architecturale | ការរចនាលើសំណង់អគារ ដើម្បីបង្កើនការទាក់ទាញឱ្យមានការចាប់អារម្មណ៍។ |

# បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកសព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| ១- **អាកទែ / រោហិណី**<br>អ. artery<br>បារ. artère (f.) | សរសៃឈាមឬអាកទែ : សរសៃឈាមដែលនាំឈាមចេញពី បេះដូងទៅសរីរាង្គកាយ។<br>ឧ. សាពាង្គកាយមនុស្សឬសត្វមានបណ្ដាញអាកទែឬរោហិណីជាច្រើនប្រភេទ។ |
| ២- **វក្កំ / តម្រងនោម**<br>អ. kidney<br>បារ. rein (m.) | សរីរាង្គរបស់មនុស្សឬសត្វមានសណ្ឋានស្រដៀងនឹងគ្រាប់សណ្ដែកដែលមានមុខងារច្រោះយកជាតិអាសូតចេញពីឈាម បង្កើតជាទឹកនោម ធ្វើឱ្យមានលំនឹងសារធាតុផ្សេងៗក្នុងឈាម។<br>ឧ. ជំងឺរលាកវក្កំ ឬ ជំងឺរលាកតម្រងនោម។ |
| ៣- **អង់ទីប្យូទិច**<br>អ. antibiotic<br>បារ. antibiotique (m.) | សារធាតុឱសថមានប្រភពពីធម្មជាតិឬពីសារធាតុគីមីឬការធ្វើសំយោគ ដែលមានសកម្មភាពអាចទប់ស្កាត់ការលូតលាស់ឬបំផ្លាញពពួកបាក់តេរីឬផ្សិត។<br>ឧ. គ្រូពេទ្យបានជ្រើសរើសឱសថអង់ទីប្យូទិចមួយប្រភេទមកព្យាបាលជំងឺរលាកបំពង់ក។ |
| ៤- **ជំងឺមហារីក**<br>អ. cancer<br>បារ. cancer (m.) | ជំងឺកើតឡើងជាដុំពក ជាដំបៅមិនប្រក្រតី នៅតាមសរីរាង្គណាមួយរបស់មនុស្សឬសត្វ បង្កឡើងដោយកោសិកាដែលដុះរីកលូតលាស់ខុសធម្មតានិងរាលដាល បង្កជាជំងឺស្រួចស្រាល់ឬរ៉ាំរ៉ៃបណ្ដាលឱ្យស្លាប់ បើមិនមានការព្យាបាលឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត ជំនាញឱ្យទាន់ពេលវេលាទេនោះ។<br>ឧ. អ្នកជំងឺនេះស្លាប់ដោយជំងឺមហារីកថ្លើម។ |
| ៥- **រោគរបេង**<br>អ. tuberculosis<br>បារ. tuberculose (f.) | រោគឆ្លងតាមផ្លូវដង្ហើមបង្កឡើងដោយមេរោគឈ្មោះ បាស៊ីកុក (bacille de Koch BK : Mycobacterium tuberculosis) ដែលកើតឡើងនៅលើសរីរាង្គណាមួយរបស់មនុស្សឬ |

| | |
|---|---|
| | សត្វ ដូចជា សួត ឆ្អឹង ពោះវៀន តម្រងនោម ស្រោមខួរ កូនកណ្ដុរ ។ ល ។<br>ឧ.១- អ្នកជំងឺដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យនេះមានរោគរបេងសួត ។<br>ឧ.២- កុមារនេះមានរោគរបេងកូនកណ្ដុរ ( ប្រជាជនខ្មែរនិយមហៅថាកើតទ្រេញ ) ។ |
| ៦- **រោគគ្រុនពោះវៀន**<br>អ . typhoid fever<br>បារ. fièvre typhoïde (f.) | រោគឆ្លងដោយមេរោគឈ្មោះ សាលម៉ូណេឡាទីហ្វី (Salmonella typhie) ឬ មេរោគឈ្មោះ បាស៊ី អេប៊ែរ (bacille d'Eberth) ។<br>ឧ. អ្នកស្រាវជ្រាវបានចុះទៅពិនិត្យតំបន់ជនបទមួយកន្លែងដែលមានកើតរោគគ្រុនពោះ-វៀន ដោយមូលហេតុប្រើទឹកមិនស្អាត ។ |
| ៧-**រោគគ្រុនឈាម**<br>អ . dengue hemorrhagic fever/ dengue fever<br>បារ. dengue hémorragique/ dengue (f.) | រោគឆ្លងតាមមូសខ្លាឈ្មោះ Aédes oegypti មកមនុស្ស ហើយ ច្រើនកើតនៅតំបន់ត្រូពិក ។ រោគនេះកើតឡើងដោយសារវីរុសឈ្មោះ dengue ដែលស្ថិតនៅក្នុងក្រុម flaviviridae ។<br>ឧ. នៅរដូវភ្លៀង យើងត្រូវកម្ចាត់មូសខ្លា ដើម្បីកុំឱ្យកើតជំងឺគ្រុនឈាម ។ |
| ៨- **ជំងឺពកក**<br>អ . goiter /goitre<br>បារ. goitre (f.) | ជំងឺដែលសម្គាល់ដោយការរីកធំឬមានដុំពកនៃក្រពេញទីរ៉ូអ៊ីត (la glande thyroide) នៅនឹងក ដោយសារក្រពេញនេះផលិតអ័រម៉ូនតិចពេកឬច្រើនពេក ។ ជំងឺពកកធម្មតាច្រើនតែបណ្ដាលមកពីកង្វះជាតិអ៊ីយ៉ូតនៅក្នុងចំណីអាហារ ។ គេសង្កេតឃើញជំងឺពកកមានច្រើនសណ្ឋាន ។<br>ឧ. អ្នកបរិភោគអំបិលមានសារធាតុអ៊ីយ៉ូតអាចការពារមិនឱ្យកើតជំងឺពកកបាន ។ |
| ៩- **ជំងឺប្រគ្រីវ**<br>អ . gout<br>បារ. goutte (f.) | ជំងឺបង្កឱ្យឈឺចុកចាប់ ជាពិសេសនៅពេលយប់ ពេលសម្រាកឬគ្មានសកម្មភាពនៅត្រង់សន្លាក់ម្រាមដៃ ម្រាមជើង និង បណ្ដាសន្លាក់ដទៃទៀត ។ ជម្ងឺនេះច្រើនបណ្ដាលមកពីសារធាតុអាស៊ីតអ៊ុយរិក (Acide urique) មានកម្រិតខ្ពស់ហួសប្រក្រតី ។<br>ឧ. គ្រូពេទ្យបានឱ្យដំបូន្មានដល់អ្នកជំងឺប្រគ្រីវនេះឱ្យតមចំណីអាហារណាដែលបង្កឱ្យកើនសារធាតុអាស៊ីតអ៊ុយរិក ដូចជា សាច់អាំង គ្រឿងសមុទ្រ គ្រឿងក្នុងជ្រូក មាន់ ទា,... ។ |
| ១០- **អាសន្នរោគ**<br>អ . cholera<br>បារ. choléra (m.) | រោគបង្កឡើងដោយមេរោគឈ្មោះ Vibrio cholerae ដែលរកឃើញដោយលោក Robert Koch នៅគ.ស.១៨៨៣ ។ ជំងឺនេះឆ្លងតាមផ្លូវអាហារ ជាពិសេសទឹកមិនស្អាត និងឆ្លងតាមដៃ បណ្ដាលឱ្យមានការចុះរាកយ៉ាងខ្លាំងជាច្រើនដងមិនឈប់ និង មានការក្អួតយ៉ាងខ្លាំងផងដែរ ជាហេតុបណ្ដាលឱ្យខ្វះជាតិទឹកឬខ្សោះជាតិទឹកពីក្នុងខ្លួនអ្នកជំងឺ អាចបណ្ដាលឱ្យស្លាប់ប្រសិនបើមិនបានព្យាបាលទាន់ពេលវេលាតាមក្បួនតាមជំនាញនោះទេ ។<br>ឧ. មណ្ឌលសុខភាពបានអប់រំប្រជាពលរដ្ឋឱ្យ រស់នៅស្អាត ហូបស្អាត ផឹកស្អាត មានអនា-ម័យ ដើម្បីជៀសវាងការកើតជំងឺអាសន្នរោគ ។ |
| ១១- **គ្រុន**<br>អ . fever ague pyrexia<br>បារ. fièvre, pyrexie (f.) | ជំងឺដែលបណ្ដាលឱ្យកម្ដៅក្នុងខ្លួនកើនឡើងហួសប្រក្រតី ។<br>ឧ. ក្មេងដែលម្ដាយនាំទៅមន្ទីរពេទ្យបង្អែកនេះកំពុងមានជំងឺគ្រុនក្ដៅ ។ |

| | |
|---|---|
| ១២- **ជំងឺរាក**<br>អ . diarrhea, diarrhoea<br>បារ. diarrhée (f.) | ជំងឺដែលបណ្ដាលឱ្យមានការបន្ទោបង់លាមកមានសភាពរាវនិងញឹកញាប់ ។<br>ឧ. នៅមន្ទីរពិសោធន៍នេះ គេកំពុងវិភាគលាមករបស់អ្នកជំងឺរាកម្នាក់ ដើម្បីរកមូលហេតុ រកមេរោគដែលបង្កឱ្យរាក ។ |
| ១៣- **ក្អក**<br>អ. cough<br>បារ. toux (f.) | សញ្ញា/អាការបញ្ចេញខ្យល់ដោយបង្ខំរហ័សភ្លាមៗរបៀបជាកន្ទ្រាក់ឬកញ្ជក់ និង មានសូរសំឡេងចេញពីបំពង់ក ដែលជាទូទៅ ជួនកាលកើតឡើងដោយចេតនាឬអចេតនា និងរេផ្លិច ( réflexe ) ។ ជាទូទៅ ក្អកបណ្ដាលមកពីការរលាកផ្លូវដង្ហើមនិងផ្លូវរំលាយអាហារ ។<br>ឧ. ក្មេងដែលមានជំងឺរលាកផ្លូវដង្ហើមបណ្ដាលឱ្យមានអាការក្អកជាញឹកញាប់ ។ |
| ១៤- **ក្អួត**<br>អ. vomiting<br>បារ. vomissement (m.) | អាការដែលក្រពះកន្ទ្រាក់ច្រចាច់បញ្ចេញចំណីអាហារនិងសារធាតុផ្សេងៗមកក្រៅតាមបំពង់អាហារហើយតាមមាត់ ។<br>ឧ. គាត់ក្អួតយ៉ាងខ្លាំង បន្ទាប់ពីពិសាស្រាយ៉ាងច្រើន ។ |
| ១៥- **ទល់លាមក**<br>អ. constipation / costiveness<br>បារ. constipation (f.) | ដំណើរបន្ទោបង់លាមកមិនប្រក្រតី គឺមានការឃើត ការជុះមិនចេញ លាមកមានសភាពរឹងបណ្ដាលមកពីមូលហេតុផ្សេងៗបង្កឡើង ។<br>ឧ. ដើម្បីចៀសវាងទល់លាមក គួរគប្បីបរិភោគបន្លែផ្លែឈើនិងទឹកឱ្យបានច្រើន ។ |
| ១៦- **ជំងឺហឺត**<br>អ. asthma<br>បារ. asthme (m.) | អាការៈជំងឺកើតឡើងនៅផ្លូវដង្ហើមបណ្ដាលឱ្យអ្នកជំងឺមានការលំបាកក្នុងការដកដង្ហើម ហត់ដង្ហក់ ។ ជំងឺនេះបណ្ដាលមកពីមូលហេតុច្រើនយ៉ាង អ្នកជំងឺអាចស្លាប់បើពុំមានការព្យាបាលត្រឹមត្រូវទាន់ពេលវេលានោះទេ ។<br>ឧ. ដើម្បីចៀសវាងជំងឺហឺត គួររស់នៅក្នុងបរិយាកាសល្អ អនាម័យល្អ និង ចៀសវាងការប្រើថ្នាំដោយគ្មានវេជ្ជបញ្ជា ។ |
| ១៧- **រោគប្រមេះ**<br>អ. blennorrhagia<br>blennorrhea, blennorrhoea,gonorrhea gonorrhoea<br>បារ. blennorragie (f.),<br>blennorrhée gonorrhée | កាមរោគម្យ៉ាងដែលបង្កឡើងដោយមេរោគឈ្មោះ gonocoque de Neisser ច្រើនកើតនៅលើប្រដាប់បន្តពូជមនុស្ស សត្វ ។ ជំងឺនេះបណ្ដាលឱ្យមានខ្ទុះហូរចេញពីប្រដាប់បន្តពូជ ហើយ អាចឆ្លងទៅដល់ទារកដែលទើបនិងកើតផងដែរ ។<br>ឧ. ការប្រើប្រាស់ស្រោមអនាម័យអាចបង្ការរោគប្រមេះបាន ។ |
| ១៨- **រោគស្វាយ**<br>អ. syphilis<br>បារ. syphilis (f.) | កាមរោគម្យ៉ាងដែលបង្កឡើងដោយមេរោគឈ្មោះ Spirochète treponema pallidum de schaudinn ជំងឺនេះឆ្លងតាមការរួមភេទ និង ពីម្ដាយទៅទារកក្នុងផ្ទៃ ដែលមានរោគសញ្ញាច្រើនបែប ។ ជំងឺនេះអាចវិវត្តពីស្រាលទៅធ្ងន់តាមបីដំណាក់កាល ។<br>បើគ្មានការព្យាបាលត្រឹមត្រូវនិងទាន់ពេល វេលានោះទេវាអាចបណ្ដាលឱ្យខូចដល់សរីរាង្គផ្សេងៗជាច្រើន និង អាចឱ្យស្លាប់បាន ។<br>ឧ. ដោយសារការប្រើប្រាស់ស្រោមអនាម័យ ធ្វើឱ្យអត្រានៃការឆ្លងរោគស្វាយមានការថយចុះ ។ |

| | |
|---|---|
| **១៩- ឈឺក្បាល**<br>អ. cephalalgia, cephalgia cephalodynia, headache<br>បារ. céphalalgie (f.) céphalée , mal de tête | អាការដែលឈឺចាប់ក្នុងក្បាល បណ្តាលមកពីមូលហេតុច្រើនយ៉ាង ពេលខ្លះមិនអាចរកមូលហេតុឃើញឡើយ ។<br>ឧ. ការសម្រាកគ្រប់គ្រាន់ និង ទៀងទាត់ពេលវេលាអាចជួយបន្ថយអាការៈឈឺក្បាល ។ |
| **២០- វិលមុខ**<br>អ. dizziness verrigo<br>បារ. vertige (m.) | អាការងងឹតមុខស្លុប ងេងងោង ធេងធោង ដែលអ្នកជំងឺមានអារម្មណ៍ថា ខ្លួនឯងកំពុងតែវិលឬមើលឃើញវត្ថុជុំវិញខ្លួនកំពុងវិលឬយោលចុះយោលឡើង ។ |
| **២១- កញ្ជ្រឹល**<br>អ. measles, morbilli, rubeola<br>បារ. rougeole (f.) | រោគឆ្លងម្យ៉ាង ច្រើនកើតលើកុមារបណ្តាលមកពីវីរុស Morbilli បង្កឱ្យស្បែកមានកន្ទួលតូចៗ ពណ៌ក្រហម ក្អក ហៀរសំបោរ គ្រុនក្តៅ ឈឺបំពង់ក ។ល។<br>ឧ. កុមារនេះបានចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹលរួចហើយ ។ |
| **២២- កន្ទាលត្រអាក**<br>អ. hives or urticaria<br>បារ. urticaire (f.) | អាការនៃជំងឺម្យ៉ាង កើតនៅលើស្បែក ឡើងកន្ទួលជាបន្ទះដុំៗរាងឃ្មឹល និង បង្កឱ្យរមាស់ភាគច្រើនបណ្តាលមកពីសារធាតុ Histamine ។<br>ឧ. ការបរិភោគចំណីអាហារមួយចំនួន ដែលមិនសមស្របនឹងរបបអាហារអាចបណ្តាលឱ្យកើតកន្ទាលត្រអាក ។ |
| **២៣- ព្រូនចង្កឹះ**<br>អ. ascarid<br>បារ. ascaris/ascaride (m.) | បរាសិតណេម៉ាតូដ (Nématodes) ដែលមានរាងបំពង់វែង (cylindre) ពណ៌ប្រផេះ ឬ ពណ៌ក្រហម មានប្រវែងពី២០ទៅ៤០សង់ទីម៉ែត្រ ជាបរាសិតរស់នៅក្នុងសពាង្គកាយមនុស្ស ឬ សត្វ ។<br>ឧ. ក្មេងហូបចុកគ្មានអនាម័យនាំឱ្យកើតព្រូនចង្កឹះ ។ |
| **២៤- អៀន**<br>អ. pinworm<br>បារ. oxyure (m.) | បរាសិតណេម៉ាតូដ (nématodes) មានប្រវែងពី៤-៩មីល្លីម៉ែត្រ ជាបរាសិតនៅក្នុងពោះវៀន ជាពិសេស វាស្ថិតនៅចុងពោះវៀន និង ទ្វារធំ បង្កឱ្យរមាស់ ។<br>ឧ. ក្មេងកើតអៀនច្រើនរមាស់ទ្វារធំនៅពេលយប់ ។ |
| **២៥-ព្រូនតម្កក់**<br>អ. hookworm / ankglo stomastoma duodenale<br>បារ. ankylostome (m.), necator americanus | បរាសិតណេម៉ាតូដ (nématodes) មានប្រវែងពី៨-១៥មីល្លីម៉ែត្រ ។ បរាសិតនេះរស់នៅនិងជញ្ជក់ឈាមនៅត្រង់គល់ពោះវៀន (duodénum) បណ្តាលឱ្យមានជំងឺខ្វះគោលិកាក្រហម ។ ជាទូទៅ វាឆ្លងតាមមាត់ឬស្បែក ។<br>ឧ. ក្មេងកើតព្រូនតម្កក់មានអាការៈស្លេកស្លាំង ។ |
| **២៦-ព្រូនអន្ទង់**<br>អ. eelworm<br>បារ. anguilule (f.) | បរាសិតណេម៉ាតូដ (nématodes) មានប្រវែង២មីល្លីម៉ែត្រ ឆ្លងតាមស្បែក បង្កឱ្យកើតជាកន្ទាលត្រអាក រមាស់ ។ នៅពេលដែលបរាសិតនេះចូលទៅដល់សួត វាបង្កឱ្យមានជំងឺសួត ឱ្យមានជំងឺ ក្អក ចុកទ្រូង ជាដើម ។ បន្ទាប់មក វាអាចបង្កឱ្យមានជំងឺផ្លូវរំលាយអាហារ ដូចជា ការឈឺចុកចាប់ក្នុងពោះ ទល់លាមក ។ បន្ទាប់មកទៀត វាបណ្តាលឱ្យរាគ និងបង្កឱ្យខ្វះគោលិកាក្រហម ។<br>ឧ. ក្មេងកើតព្រូនអន្ទង់ដោយមូលហេតុដើរជើងទទេឬលេងដីនៅទីកន្លែងគ្មានអនាម័យ ។ |

| | |
|---|---|
| ២៧-**ព្រូនសំប៉ែត / ព្រូនវែង (តេនញ៉ា)**<br>អ. tapeworm<br>បារ. taenia (m.) | បរាសិតសេស្តូដ (Cestodes) មានច្រើនប្រភេទ រស់នៅក្នុងពោះវៀនមនុស្សនិងសត្វមានឆ្អឹងកង ។ បរាសិតនេះគឺជាប្រភេទព្រូនមានរាងសំប៉ែត ដែលមានប្រវែងពី១៣មីល្លីម៉ែត្ររហូតដល់៩ម៉ែត្រ មានសណ្ឋានជាកង់ៗ ហើយមានឈ្នាប់នៅនឹងក្បាលសម្រាប់ថ្តក់ជាប់ទៅនឹងស្រទាប់ខាងក្នុងនៃពោះវៀន ។<br>ឧ. ការបរិភោគសាច់សត្វនិងបន្លែដែលមានពងព្រូនសំប៉ែត បើចម្អិនមិនបានឆ្អិនល្អ បណ្តាលឱ្យកើតព្រូនសំប៉ែត ។ |
| ២៨- **ដង្កែ**<br>អ. flea<br>បារ. tique (f.) | សត្វល្អិតអារ៉ាក្នីដ (Arachnides) មានជើង៨ ។ វាជាបរាសិតជញ្ជក់ឈាមនៅលើស្បែកថនិកសត្វ ។<br>ឧ. ដង្កែជញ្ជក់ឈាមគោនិងឆ្កែ ។ |
| ២៩-**ចៃលោត**<br>អ. flee / louse<br>បារ. puce (f.) | សត្វល្អិតសម្បុរត្នោត រាងសំប៉ែត ចេះរត់ឬលោតបាន ។ វាជាបរាសិតរស់នៅលើមនុស្ស និង ថនិកសត្វមួយចំនួន ។ សត្វល្អិតនេះរស់នៅលើស្បែក ហើយពូកែជញ្ជក់ឈាម ។<br>ឧ. ការមិនសម្អាតខ្លួនឱ្យឆ្កែនិងឆ្មានាំឱ្យកើតចៃលោត ។ |
| ៣០-**ចៃ**<br>អ. louse<br>បារ. pou (m.) | សត្វល្អិតជាបរាសិតជញ្ជក់ឈាម រស់នៅលើមនុស្សនិងថនិកសត្វមួយចំនួន ។<br>ឧ. មនុស្សត្រូវធ្វើអនាម័យក្បាលឱ្យបានស្អាត ដើម្បីកុំឱ្យកើតចៃ ។ |
| ៣១-**មេល័ក្ខ / មេល័ខ**<br>អ. lac insect<br>បារ. cochenille (f.) | សត្វល្អិតរស់នៅលើរុក្ខជាតិ ដែលសម្បុករបស់វាមានសារធាតុជ័រខាប់ពណ៌ក្រហម សម្រាប់ប្រើជាពណ៌ជ្រលក់សូត្រឬអំបោះ ។<br>ឧ. ជំនាន់មុន ប្រជាជនខ្មែរនិយមចិញ្ចឹមមេល័ខ ដើម្បីយកពណ៌ជ្រលក់សូត្រឬអំបោះ ។ |
| ៣២-**សង្កើច**<br>អ. bedbug, housebug<br>បារ. punaise (f.) | សត្វល្អិតជាបរាសិតជញ្ជក់ឈាមរស់នៅក្បែរខ្លួនមនុស្ស ដូចជា តាមកន្ទេល ខ្នើយ គ្រែ រនាបផ្ទះ ជាដើម ។<br>ឧ. គេនិយមយកសំបកទុរេនដាក់ក្រោមគ្រែ ដើម្បីដេញសង្កើច ។ |
| ៣៣- **ស្រមើល**<br>អ. tiny bug<br>បារ. ... | សត្វល្អិតតូចក្រៃលែងស្ទើរមើលពុំឃើញ ច្រើនកើតនៅកន្លែងឬលើវត្ថុស្មោកគ្រោក ដូចជា ទ្រុងមាន់ ទ្រុងទា សម្បុកសត្វ សំបកស៊ុត ជាដើម ។<br>ឧ. ស្រមើលរោមរសីបរសាវនាំឱ្យដេកមិនលក់ ។ |
| ៣៤-**អង្គែ**<br>អ. dandruff<br>បារ. pellicule (f.) | រោគសើស្បែកម្យ៉ាងដែលមានសណ្ឋានរបកជាស្រទាប់ស្តើងៗ បណ្តាលឱ្យស្បែកឡើងគគ្រាត សម្បុរស ហើយរមាស់ ។ វាច្រើនកើតនៅកន្លែងដុះសក់ឬរោម ។<br>ឧ. ក្បាលកើតអង្គែ, ឆ្កែអង្គែស៊ី ។ |
| ៣៥-**ជំងឺអុតក្តាម** (កសិកម្ម)<br>អ. foot & mouth disease<br>បារ. fièvre (f.) aphteuse | ជំងឺឆ្លងម្យ៉ាងដែលច្រើនកើតនៅលើសត្វមានចង្កែកជើង ធ្វើឱ្យមានដំបៅរលួយចង្កែកជើង ក្រចកជើង មាត់ និង កន្ទោបមដោះ ។ វាធ្វើឱ្យសត្វឈឺពិបាកដើរនិងពិបាកស៊ីចំណី ។ ជួនកាលជំងឺនេះឆ្លងទៅមនុស្សផងដែរ ។ |

| | |
|---|---|
| | ឧ. បសុពេទ្យបើកយុទ្ធនាការចាក់ថ្នាំបង្ការជំងឺអុតក្តាមដល់ គោ ក្របី នៅមុនរដូវភ្លៀង ។ |
| ៣៦-**ជំងឺឈាមខ្មៅ** (កសិកម្ម)<br>អ. anthrax<br>បារ. anthrax (m.), charbon (m.) bactéridien | ជំងឺបង្កឡើងដោយបាក់តេរី បាក់ស៊ីលីស អង់ត្រាក់ស៊ីស (Bacillus Anthracis) បណ្តាលឱ្យសត្វងាប់មានអត្រាខ្ពស់ ដោយអាការៈហើមពោះ មិនស៊ីស្មៅដូចប្រក្រតី និង មានចេញឈាមតាមមាត់ ច្រមុះ និង គូទ ក្រោយពេលវាងាប់ ។ ជំងឺនេះអាចឆ្លងទៅមនុស្សបាន ។<br>ឧ. ហាមបរិភោគសាច់សត្វដែលស្លាប់ដោយជំងឺឈាមខ្មៅ ព្រោះវាអាចឆ្លងមកមនុស្ស ។ |
| ៣៧- **ជំងឺសាទឹក** (កសិកម្ម)<br>អ. pasteurellosis<br>បារ. pasteurellose (f.) | ជំងឺម៉្យាងបង្កឡើងដោយបាក់តេរី ប៉ាស្ទ័រេឡា (Pasteurella) ច្រើនកើតនៅលើសត្វបម្រើ ។ ជំងឺនេះអាចឆ្លងពីសត្វឈឺទៅសត្វជា តាមរយៈទឹកមាត់ ចំណីអាហារ និង ការរស់នៅជិតគ្នា ។ ពេលសត្វឈឺមានសីតុណ្ហភាពពី៤១ទៅ៤២អង្សាសេ វានឹងងាប់ទាន់ហន់ក្នុងរយៈពេល២៤ម៉ោង ។<br>ឧ. ជំងឺសាទឹកអាចទប់ស្កាត់បាន ប្រសិនបើយើងចាក់ថ្នាំការពារឱ្យបានពីរឬបីដងក្នុង មួយឆ្នាំ ។ |
| ៣៨-**ជំងឺប៉េស្ត** (កសិកម្ម)<br>អ. pest<br>បារ. peste (f.) | ជំងឺឆ្លងម៉្យាងដែលច្រើនកើតនៅលើសត្វបម្រើ និង ឆ្លងរាលដាលយ៉ាងឆាប់រហ័សតាមផ្លូវដង្ហើមនិងតាមផ្លូវរំលាយអាហារ ហើយក៏អាចឆ្លងជាប្រយោលទៅដល់មនុស្សនិងសត្វដទៃទៀតផងដែរ ។<br>ឧ. ជំងឺប៉េស្តគ្មានថ្នាំព្យាបាលទេ ប៉ុន្តែ មានវ៉ាក់សាំងការពារ ។ |
| ៣៩-**ជំងឺបួសខ្យល់**<br>អ. blackleg<br>បារ. charbon (m.) symptomatique | ជំងឺម៉្យាងដែលបង្កឡើងដោយបាក់តេរី Clostridium Chauvoei ។ ជំងឺនេះច្រើនកើតនៅលើ គោ ក្របី ចៀម ពពែ និង អាចកើតនៅលើជ្រូក ផងដែរ ។ ជំងឺនេះមានរោគសញ្ញា ដូចជា មានដុំខ្យល់ពកនៅត្រង់ក ទ្រូង ស្មា និង ត្រគាក បណ្តាលឱ្យសត្វឈឺពិបាកធ្វើចលនា ។<br>ឧ. ជំងឺបួសខ្យល់មិនឆ្លងដល់មនុស្សដូចជំងឺឈាមខ្មៅទេ ។ |
| ៤០-**ជំងឺចុងអង្ករ** (កសិកម្ម)<br>អ. measles, pork<br>បារ. ladrerie (f.) | ជំងឺម៉្យាងដែលកើតនៅលើសត្វជ្រូក ដែលបង្កឱ្យកើតនៅក្នុងសាច់ជ្រូកនូវ សណ្ឋានដូចគ្រាប់អង្ករតូចៗហៅថា Cysticercus cellulosae ។ ជ្រូកកើតជំងឺចុងអង្ករពីព្រោះវាស៊ីលាមកមនុស្សដែលមានផ្ទុកពងព្រូនសំប៉ែត ។<br>ឧ. ការយកសាច់ជ្រូកដែលមានជំងឺចុងអង្ករមកបរិភោគ ដោយមិនបានចម្អិនឱ្យបានត្រឹមត្រូវនោះ អាចឆ្លងព្រូនសំប៉ែតមកមនុស្សបាន ។ |
| ៤១-**ជំងឺអំបៅអំបែក**<br>អ. otitis<br>បារ. otite (f.) | ជំងឺម៉្យាងដែលកើតក្នុងរន្ធត្រចៀក បង្កឡើងដោយពពួកមីក្រុប ឬ ផ្សិត ។ រោគសញ្ញាមានដូចជា ក្តៅខ្លួន ឈឺក្នុងរន្ធត្រចៀក ហៀរទឹករងៃ ឬ ខ្ទុះ ដែលមានក្លិនស្អុយ ។<br>ឧ. មាតាត្រូវតែសម្អាតរន្ធត្រចៀកកូនឱ្យបានស្អាត ក្រោយពេលងូតទឹក ដើម្បីជៀសវាង ជំងឺអំបៅអំបែក ។ |

| | |
|---|---|
| ៤២- **ជំងឺដង្កូវថ្លើម/ជំងឺព្រូនថ្លើម**<br>អ. fascioliasis<br>បារ. fasciolosis (m.) | ជំងឺដែលបង្កឡើងដោយពពួកបរាសិតឈ្មោះ ហ្វាស្យូឡា ស៊ីហ្គង់ទីកា/ហ្វាស្យូឡា អេប៉ាទីកា (Fasciola gigantica/Fasciola hepatica) ដែលកើតឡើងនៅក្នុងថ្លើម ក្នុងថង់ប្រមាត់ និង នៅក្នុងបំពង់ទឹកប្រមាត់ របស់គោ ក្របី ។<br>ឧ. គោ ក្របី ស៊ីស្មៅនៅតាមមាត់ត្រពាំងឬបឹងបួរ អាចស៊ីដោយខ្យងហៀនទឹកតូចៗឈ្មោះ លីមណេ (Limnée/Limnea) ដែលជាភ្នាក់ងារចម្លង បណ្ដាលឱ្យឆ្លងជំងឺដង្កូវថ្លើម ។ |
| ៤៣-**ការបាក់ឆ្អឹង/បំណាក់ឆ្អឹង**<br>អ. fracture<br>បារ. fracture (f.) | ការបាក់ដាច់ឬបែកបាក់ ដោយអន្លើឬដោយផ្នែកទាំងអស់ របស់ឆ្អឹង ។<br>ឧ. ក្រោយពីអស់រដូវ ស្ត្រីដែលពុំបានទទួលសារធាតុកាល់ស្យូម និង ផូស្វ័រឱ្យបានគ្រប់គ្រាន់ ងាយទទួលរងការបាក់ឆ្អឹង ។ |
| ៤៤-**ការភ្លាត់ឆ្អឹង**<br>អ. luxation<br>បារ. luxation (f.) | ដំណើរឃ្លាតឬភ្លាត់ ឬ ក៏របូតក្បាលឆ្អឹងពីទីតាំងដើមបណ្ដាលមកពីការដួលឬការប៉ះទង្គិច ។<br>ឧ. កីឡាបាល់ទាត់ច្រើនរងគ្រោះថ្នាក់ភ្លាត់ឆ្អឹង ។ |
| ៤៥- **ការថ្លោះគ្រេច**<br>អ. sprain<br>បារ. entorse (f.) | ដំណើររហើមឬដាច់សរសៃចំណងសន្លាក់ឆ្អឹង ។<br>ឧ. លំហាត់ប្រាណជាប្រចាំអាចជួយបន្ថយការថ្លោះគ្រេច ។ |
| ៤៦- **ការបង្កកំណើត**<br>អ. fertilization<br>បារ. fécondation (f.) | ជំនួបរវាងស្ពែម៉ាតូសូអ៊ីតនិងអូវុលសម្រាប់មនុស្សឬសត្វ, រវាងអង់តេរ៉ូសូអ៊ីតនិងអូស្វ៊ែចំពោះរុក្ខជាតិ បង្កើតបានជាកោសិកាថ្មីមួយហៅថា ស៊ីកូត (zygote) ។<br>ឧ. ការបង្កកំណើតអាចប្រព្រឹត្តទៅបានលុះត្រាតែមានការជួបគ្នារវាងកាម៉ែតឈ្មោលនិងកាម៉ែតញី ។ |
| ៤៧- **គភ៌**<br>អ. gestation, prgnancy<br>បារ. gestation / grossesse (f.) | កូនក្នុងផ្ទៃដែលវិវត្តពីស៊ីកូតរហូតដល់គ្រប់ខែកើត ។<br>ឧ. ស្ត្រីរូបនេះមានគភ៌ចំនួន៥ខែមកហើយ ។ |
| ៤៨- **ការបង្កាត់ពូជដោយសិប្បនិម្មិត** (កសិកម្ម)<br>អ. artificial insemination<br>បារ. insémination (f.) artificielle | ការបញ្ចូលទឹកកាមដែលគេរៀបចំតាមបច្ចេកទេសទៅក្នុងប្រដាប់បន្តពូជញី តាមរយៈឧបករណ៍មេកានិកឬអេឡិកត្រូនិកផ្សេងៗ ក្នុងគោលបំណងធ្វើឱ្យមានការបង្កកំណើត ។<br>ឧ. បច្ចុប្បន្ននេះ កសិដ្ឋានចិញ្ចឹមសត្វនានានិយមការបង្កាត់ពូជដោយសិប្បនិម្មិត ។ |
| ៤៩-**ការបង្កាត់ពូជតាមធម្មជាតិ**<br>អ. natural insemination<br>បារ. saillie (f.) naturelle | ការបង្កាត់ពូជតាមរយៈបានិងមេផ្ទាល់ ។<br>ឧ. ក្នុងចំណោមប្រជាកសិករខ្មែរ គេនៅតែអនុវត្តការបង្កាត់ពូជតាមធម្មជាតិចំពោះ គោ ក្របី ជ្រូក មាន់ ទា នៅឡើយ ។ |

# បច្ចេកសព្ទរបស់គណៈកម្មការ ភាសាវិទ្យា និង អក្សរសិល្ប៍ ដែល គ.ជ.ភ.ខ. បានអនុម័ត

| | |
|---|---|
| ១- **វចនលេខន៍**<br>អ. lexicography<br>បារ. lexicographie (f.) | ការសរសេរនិងការរៀបរៀង ចងក្រង វចនានុក្រម ដោយផ្អែកលើចំណេះដឹងខាងវចនវិទ្យា។ |
| ២- **វចនវិទ្យា**<br>អ. lexicology<br>បារ. lexicologie (f.) | ផ្នែកមួយនៃភាសាវិទ្យា ដែលសិក្សាអំពីវាក្យសព្ទ ក្នុងនោះមានការបង្កើតពាក្យ, ការប្រើពាក្យជាដើម, ឧទាហរណ៍ :<br>- គាប + [-ន-] > ឃ្នាប,<br>- ប្រមោយ + ដំរី > ប្រមោយដំរី,...។ |
| ៣-**ឯកតា**<br>អ. unit<br>បារ. unité (f.) | ភាគនៃខ្សែសម្ដីក្នុងភាសាដែលគេអាចវិភាគចេញពីគ្នា ដូចជា សទ្ទតា[១៦], ពាក្យទោល[១៧] ឬ ល្បះទោល[១៨]។ សទ្ទតា, ពាក្យទោល ឬ ល្បះទោល ជាឯកតាភាសា[១៩]។ |
| ៤- **មូលតា**<br>អ. morpheme<br>បារ. monème (m.) | មូលតា ជាការបកប្រែពាក្យ "monème" ដែលលោក André Martinet បានកំណត់ន័យថា ជាឯកតាអប្បបរមាដែលមានន័យ[២០] ដូច :<br>- <u>ក្នុងភាសាបារាំង</u> :<br>• voilà ton père មានមូលតាចំនួនបី : voilà, ton, père,<br>• embarquons មានមូលតាចំនួនបី : em- , -barqu-, -ons ។<br>- <u>ក្នុងភាសាខ្មែរ</u> :<br>• ពាក្យ *ឆ្នាំ* មានមូលតាចំនួនពីរ : *ចាំ* និង អន្តែបទ/ផ្នត់ដែក [-ម-]។<br>• ពាក្យ *ឃ្នាប* មានមូលតាចំនួនពីរ : *គាប* និង អន្តែបទ/ផ្នត់ដែក [-ន-]។<br>មូលតាអាចជា វចនតា ឬ រូបតា។ |
| ៥- **វចនតា**<br>អ. lexical morpheme<br>បារ. lexème[21] (m.) | មូលតាមួយបែបដែលជាពាក្យទោល ឬ ជាឫស/ជាធាតុនៃពាក្យក្នុងភាសាឥណ្ឌូអឺរ៉ុប, ឧទាហរណ៍ :<br>- វចនតាជាពាក្យទោល, ឧ. *គាប, ធំ, កូន, crayon, jardin, chaise,...*<br>- វចនតាជាឫស ក្នុងភាសាបារាំង, ឧ. *all* (*ទៅ*) ក្នុងពាក្យ *aller,...*។<br>- វចនតាជាធាតុ ក្នុងភាសាបាលី, ឧ. *ទា* (*ឱ្យ*) ក្នុងពាក្យ *ទេតិ, ទាន, ...*។<br>កាលណាគេយកពាក្យទោលទៅធ្វើមូលដ្ឋានក្នុងការបង្កើតពាក្យ ពាក្យទោលនោះ |

[១៦] - សូមមើលនិយមន័យសម្រាប់ *សទ្ទតា* ។
[១៧] - សូមមើលនិយមន័យសម្រាប់ *ពាក្យទោល* ។
[១៨] - សូមមើលនិយមន័យសម្រាប់ *ល្បះទោល* ។
[១៩] - យកលំនាំតាម Dictionnaire de linguistique របស់លោក Jean Dubois & alii, Librairie Larousse, 1973, p.502 ។
[២០] - André Martinet, Eléments de Linguistique générale, Armand Colin 1970, p.103
និង Georges Mounin, Clefs pour la Linguistique, Seghers 1971, p. 54 ។
[២១] - André Martinet, Ibid, p.119

| | |
|---|---|
| | ត្រូវគេហៅថា ពាក្យឫស ។ |
| ៦- **ឫស**<br>អ. root<br>បារ. racine (f.) | វចនតាមួយបែប ដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសា ដែលជាធាតុរួមនៃពាក្យមួយចំនួនក្នុងសន្តានជាមួយគ្នា។ តាមវចនានុក្រមភាសាវិទ្យារបស់លោក Jean Dubois & alii (Larousse), racine（ឫស）អាចមាន radical ច្រើន, ឧទាហរណ៍ : ក្នុងភាសាបារាំង ឫស[vən]（មក）មាន radical ពីរ : [vən-] (ven-) ដូចមានក្នុងពាក្យ [vənir] (venir), [vən□□□□(venons), ... និង [vjɛn-] (vienne) ដូចមានក្នុងពាក្យ [vjɛn] (vienne/viennent), ... ។<br>ការពន្យល់អំពី *ឫស* បានបង្ហាញឱ្យឃើញថា racine ខ្លះ អាចមាន radical ច្រើន ហើយ យើងបានប្រែពាក្យ *racine* ថា *ឫស* ។ ដោយផ្អែកលើប្រព័ន្ធ សូរ-កាឡាសូរ , រូបតា-កាឡារូប យើងអាចប្រែ radical ដែលជារូបផ្សេងៗនៃ racine ថា *កាឡាឫស* ។ |
| ៧- **រូបតា**<br>អ. grammatical morpheme<br>បារ. morphème[22] (m.) | មូលតាមួយបែបដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសា（លោក អៀវ កើស ហៅថា "កន្ទេចពាក្យ"[២៣]）សម្រាប់ភ្ជាប់ជាមួយពាក្យឫស ឬ ជាមួយឫស ដើម្បី :<br><br>- បង្កើតពាក្យ, ឧទាហរណ៍ :<br>•• ក្នុងភាសាខ្មែរ :<br>• ពាក្យឫស *ដួញ* + *[-ម-]* > *ឈ្មួញ* ,<br>• ពាក្យឫស *គាប* + *[-ន-]* > *ឃ្នាប* ,... ។<br>•• ក្នុងភាសាបារាំង :<br>• ពាក្យឫស *jardin* + *ier* > *jardinier,*<br>• ឫស *all* + *er* > *aller,…*<br><br>- បំបែកពាក្យ, ឧទាហរណ៍ :<br>•• ក្នុងភាសាបារាំង :<br>• ឫស *all* + *ons* > *allons* (បុ.១, ពហុ.),<br>• ឫស *all* + *ez* > *allez* (បុ.២, ពហុ.), ...<br>•• ក្នុងភាសាឡាតាំង :<br>• *ros**a*** (nominatif, sg),<br>• *ros**am*** (accusatif, sg), ... ។<br>•• ក្នុងភាសាបាលី :<br>• *បុរិសោ* (បឋមាវិភត្តិ, ឯក.),<br>• *បុរិសំ* (ទុតិយាវិភត្តិ, ឯក.) ,... ។ |
| ៨- **កាឡារូប**<br>អ. allomorph<br>បារ. allomorphe (m.) | រូបផ្សេងៗរបស់រូបតាណាមួយដែលអាចប្ដូររូបទៅតាមបរិបទ ដូច :<br>រូបតា /-s / នៃពហុវចនៈរបស់នាមសព្ទអង់គ្លេស ដែលអាចមានកាឡារូប : |

[២២] - André Martinet, Ibid, p.119.

[២៣] - អៀវ កើស , ***ភាសាខ្មែរ*** , បណ្ណាគារ មិត្តសើរី , ភ្នំពេញ ១៩៦៧ , ទំព័រ ១៦៨ ។

| | |
|---|---|
| | [-s ] ក្នុងពាក្យ book**s** ,<br>[-z ] ក្នុងពាក្យ dog**s** ,<br>[-iz ] ក្នុងពាក្យ box**es** ។ |
| ៩- **សូរសព្ទភាសា**<br>អ. linguistic sign<br>បារ. signe (m.) linguistique | នៅក្នុងសៀវភៅ *Cours de linguistique générale* របស់គាត់ ភាសាវិទូឈ្មោះ Ferdinand de Saussure បានប្រើបច្ចេកសព្ទ "signe linguistique" ជំនួស "mot" ពីព្រោះនៅពេលនោះ គេយល់ថា "mot" ជាសំណេរ ឬ ជាផ្លាក (plaque /étiquette) មួយសម្រាប់ដាក់លើវត្ថុ (objet) មួយ។ តាមគាត់ ការយល់បែបនេះជាការភាន់ច្រឡំទាំងស្រុង ពីព្រោះ "ពាក្យ" មិនមែនជាផ្លាកមួយសម្រាប់ដាក់លើវត្ថុមួយឬជាសហកម្ម (union) រវាងឈ្មោះមួយនិងវត្ថុមួយនោះទេ ប៉ុន្តែ ជាសហកម្មមិនអាចបំបែកបានរវាង "image acoustique" និង "concept" ។<br>ក្រោយមក លោក Saussure ហាក់ដូចជាបារម្ភក្រែង "image acoustique" នាំគេឱ្យគិតទៅដល់គ្រឿងដែលទាក់ទាញភ្នែក ផ្ទុយពីអ្វីដែលគាត់ចង់ឱ្យគេយល់តាមគាត់ (ទោះមានពាក្យ "acoustique" អមផងក៏ដោយ)[២៤] ។ តាមគាត់ "image acoustique" ជាសូរសុទ្ធសាធ ជាទម្រង់សូរដែលយើងស្ដាប់ឮ កាលណា "signe linguistique" ត្រូវបានគេបន្លឺឡើង[២៥] ។<br>ដោយគាត់បារម្ភអំពីន័យមិនច្បាស់លាស់របស់ "image acoustique" នេះផង និង ដោយ "concept" ជាពាក្យធម្មតាដែលខ្វះ "បច្ចេកភាព" ផង ភាសាវិទូរូបនេះបានជំនួសពាក្យទាំងនេះ ជាលំដាប់លំដោយ ដោយ "signifiant" និង "signifié" ។<br>បើយើងប្រែចំៗ ពាក្យមួយសងពាក្យមួយ យើងអាចប្រែ "signe linguistique" ថា "សញ្ញាភាសា" ប៉ុន្តែ ដោយក្នុងភាសាខ្មែរ "សញ្ញា" ច្រើនសម្គាល់គំនូស យើងសូមប្រែ "signe linguistique" ថា "**សូរសព្ទភាសា**" វិញ ដើម្បីឱ្យឃ្លាតឆ្ងាយពីគំនិតខុសដែលយល់ថា "ពាក្យ" ជាសំណេរនោះឯង។<br>ដូច្នេះ **សូរសព្ទភាសា** ជាសហកម្មមិនអាចបំបែកបានរវាង "signifiant" និង "signifié"* ។ លោក Saussure តាងសូរសព្ទភាសា ដូចតទៅ :<br><br><u>សេចក្ដីបញ្ជាក់</u> : សញ្ញា**ព្រួញ**សម្គាល់សហកម្មដ៏ស្អិតរមួតរវាង "signifiant" និង "signifié" : បើគេគិតទៅ "signifiant" គេនឹងគិតភ្លាមជាស្វ័យប្រវត្តិទៅ "signifié" ផងដែរ។<br>លោក Saussure អាចរក្សាទុកនូវពាក្យ "mot" ហើយ គ្រាន់តែប្រកាសបញ្ជាក់ថា "mot" មិនមែនជាសំណេរទេ (សំណេរគ្រាន់តែជាការកត់ត្រា "mot" ដោយអក្សរ |

[២៤] - ជាពិសេស ចំពោះជនជាតិខ្មែរដែលអាចគិតទៅដល់ "រូបភាព"(image) ដែលជាគ្រឿងទាក់ទាញភ្នែកជាពិតប្រាកដ។

[២៥] - លោក Saussure បានបញ្ជាក់ថា " La langue est phonique et non graphique " (ភាសាជាសូរ គឺមិនមែនជាសំណេរទេ) ។

| | |
|---|---|
| | ប៉ុណ្ណេះ) ប៉ុន្តែ បើគាត់ធ្វើបែបនេះ គាត់មិនអាចកម្ចាត់គំនិតខុសបានឡើយ ពីព្រោះ ឱ្យតែឮ "mot" ភ្លាម គេគិតទៅដល់សំណេរភ្លាម។ ដោយសារការប្រើ ពាក្យ "signe linguistique" គាត់បានកម្ចាត់ការភាន់ច្រឡំថា "mot" ជាសំណេរ បានដោយជោគជ័យ។<br><br>*<u>កំណត់សម្គាល់</u> : យើងប្រែ"signifiant" ថា "ន័យករ" និង "signifié" ថា "ន័យបញ្ញត្តិ" ជាលំដាប់លំដោយ ដូចខាងក្រោម។ |
| ១០- **ន័យករ**<br>អ. signifier<br>បារ. signifiant (m.) | ពាក្យនេះត្រូវបានពន្យល់ខាងលើត្រួសៗមកហើយ គឺជាទម្រង់សូរដែលយើងស្តាប់ឮកាលណាសូរសព្ទភាសាត្រូវបានបន្លឺឡើង ប៉ុន្តែ គប្បីយើងបញ្ជាក់បន្ថែមថា តាមលោក Saussure *ន័យករ* មិនមែនជាសូរនិច្ចល[26] (inerte) ដូចសូរធម្មតាទេ : *ន័យករ* ហាក់ដូចជាមានចរន្តអ្វីមួយមកដាស់សតិអារម្មណ៍យើងកាលណាយើងរៀបប្រើ ឬ កាលណា-យើងស្តាប់ឮសូរសព្ទភាសាណាមួយ ពីព្រោះ *ន័យករ* នៃសូរសព្ទភាសានីមួយៗ តែងតែជិតដោយអនុស្សាវរីយ៍និង connotation ជានិច្ច។<br>ដំបូងឡើយ ទំនាក់ទំនងរវាង*ន័យករ*និង*ន័យបញ្ញត្តិ* ជាជម្រើសសេរី : គេអាចយក *ន័យករ* ណាមួយទៅសម្គាល់*ន័យបញ្ញត្តិ* ណាមួយក៏បានដែរ (លើកលែងតែចំពោះ *ន័យ-បញ្ញត្តិ* នៃសូរសព្ទភាសាណាដែលជាប់ផៅសន្តានជាមួយនឹងសូរសព្ទភាសាឯទៀតរួចទៅហើយ)។ |
| ១១- **ន័យបញ្ញត្តិ**<br>អ. signified<br>បារ. signifié (m.) | ដូច *ន័យករ* ដែរ *ន័យបញ្ញត្តិ* នេះត្រូវបានពន្យល់ខាងលើត្រួសៗមកហើយ គឺជាសញ្ញាណ/បញ្ញត្តិ ដែលមាន *ន័យករ* ជាទម្រង់សូរឮមកក្រៅ កាលណាសូរសព្ទភាសាត្រូវបានគេបន្លឺឡើង។ ដូចយើងបានឃើញស្រាប់ *ន័យបញ្ញត្តិ* អាចចាត់ទុកជាទំព័រម្ខាងនៃសូរសព្ទភាសាដែលអាចប្រៀបបាននឹងក្រដាស១សន្លឹក ហើយ *ន័យបញ្ញត្តិ* នេះមិនអាចបំបែកចេញបានពី *ន័យករ* ដែលជាទំព័រម្ខាងទៀតនោះឡើយ។ |
| ១២- **ពាក្យ**<br>អ. word<br>បារ. mot (m.) | សព្វថ្ងៃ ក្នុងមជ្ឈដ្ឋានអ្នកចេះដឹង វចនតា "mot" នៃភាសាបារាំង (ដែលត្រូវនឹង វចនតា "ពាក្យ"[27] នៃភាសាខ្មែរ) ឈប់មានន័យថាជាផ្លាកឬសំណេរទៀតហើយ ដូច្នេះ គេចូលចិត្តយក "mot" មកប្រើវិញ ពីព្រោះ វាមិនមែនជាកន្សោមពាក្យ ដូច "signe linguistique" ដែលជាខ្សែសម្តីវែងអន្លាយ។ ប៉ុន្តែ គេមានបញ្ហាក្នុងការកំណត់ព្រំដែនពី "mot" មួយទៅ "mot" មួយ ក្នុងខ្សែសម្តី : គេមិនអាចដឹងដោយងាយក្នុងខ្សែសម្តីថាតើ "mot" ណាចាប់ផ្តើមពីត្រង់ណា ហើយ ត្រូវចប់នៅត្រង់ណាទេ។ វេយ្យាករណ៍បារាំងបានចែកពាក្យបារាំងជា៩ប្រភេទ គឺ articles, noms, pronoms, adjectifs, verbes, adverbes, prépositions, conjonctions & interjections ។ គេថា "les" ជាពាក្យមួយម៉ាត់ គឺជា "article" តែ "les pommes de terre" ក៏ជាពាក្យ |

[26] - ពាក្យ *និច្ចល* (និច-ចល់) ត្រូវនឹងពាក្យបារាំង *inerte* ខ្ចីពីវចនានុក្រមបារាំង-ខ្មែររបស់ លោក តិប យក់ & ថាវ គន្ធ បណ្ណាគារ ប៊ុត នាង ភ្នំពេញ ឆ្នាំ១៩៦២។

[27] - ក្នុងស្មារតីខ្មែរភាគច្រើន វចនតា " ពាក្យ" នៃភាសាខ្មែរ ធ្វើឱ្យគេនឹកដល់ផ្លាកនៅឡើយ ជាពិសេស នឹកដល់ពាក្យសរសេរ ផ្ទុយពីសូរស័ព្ទភាសា។

| | |
|---|---|
| | មួយម៉ាត់ដែរ (ពាក្យសមាស)។ ដូច្នេះ ឃើញថា យើងពិបាកសម្គាល់ព្រំដែនពាក្យបារាំងណាស់[២៨] ។ ដោយ "signe linguistique" របស់លោក Saussure បានដោះ-ស្រាយត្រឹមតែមិនឱ្យយល់ច្រឡំថា "mots" ជាសំណេរ និង ដោយបញ្ហាសម្គាល់ព្រំដែននៃពាក្យនៅចោទដដែលលោក ប៊ែរណា ប៉ូជេ (Bernard Pottier) បានស្នើឱ្យប្រើ " lexie " វិញម្តង។ |
| ១៣- **បូរណសព្ទ**<br>អ. lexis<br>បារ. lexie (f.) | មូលតា (វចនតា និង រូបតា) ជាកំណាត់ក្នុងខ្សែសម្ដីដែលងាយសម្គាល់តាមរយៈន័យអប្បបរមារបស់វា ប៉ុន្តែ អ្នកប្រើប្រាស់ភាសាឥតមានលទ្ធភាពផ្គុំវាដោយសេរីជាទូទៅទេ។ តំណរវាងមូលតាខ្លះ ត្រូវភាសាបង្ខំឱ្យអ្នកប្រើប្រាស់ទទួលយកតែម្តង។ តំណដែលភាសាបង្ខំឱ្យអ្នកប្រើប្រាស់ទទួលយកនេះ ត្រូវបាន បែរណា ប៉ូជេ (Bernard Pottier) ហៅថា *lexie* ដែល យើងប្រែថា *បូរណសព្ទ* ។<br>តាមគាត់ *បូរណសព្ទ* ជាកំណាត់ទោល ដូច *cheval* ឬ ជាកំណាត់ល្បាយ ដូច *cheval-vapeur* ឬ *cheval marin* ដែលមានឯកភាពមិនអាចកាត់តបែបណាទៀតបានទេ ហើយ ដែលយើងត្រូវប្រើទាំងស្រុង។ *បូរណសព្ទ* មាន ពាក្យទោល (mots irréductible) ពាក្យកម្លាយ (mots dérivés) ពាក្យសមាស (mots composés) វាចាវិលាស[២៩] (locutions) ពាក្យកាត់ (sigle) ។ល។<br><br>យើងតែងតែពិបាកសម្គាល់បន្លែករវាង *បូរណសព្ទ* និង *កន្សោមសេរី* កើតពីការផ្គុំពាក្យតាមសេចក្ដីត្រូវការដើម្បីបញ្ចេញមតិ។ ដើម្បីដោះស្រាយបញ្ហានេះ ភាសាវិទូមួយក្រុម[៣០] បានបង្កើតតេស្ត (test) បួនបែបផ្អែកលើលក្ខណវិនិច្ឆ័យរូបនិយម (critères formels) ដែលអាចឱ្យគេសម្គាល់បន្លែករវាង *បូរណសព្ទ* និង *កន្សោមសេរី* នេះបាន[៣១] ។ |
| ១៤- **អព្ភាសបទ/ផ្នត់**<br>អ. affix<br>បារ. affixe (m.) | បញ្ញត្តិនេះត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នា :<br>- បទភ្ជាប់ ( អៀវ កើស , ***ភាសាខ្មែរ*** , បណ្ណាគារ មិត្តសេរី , ១៩៦៧[៣២] , ទំព័រ ១៦៨)<br>- អព្ភាសបទ ( កេង វ៉ាន់សាក់ , ***មូលភាពនៃការបង្កើតពាក្យថ្មី*** , រោងពុម្ពទេព , បណ្ណាគាររស្មីកម្ពុជា , ១៩៦៣ ,ទំព័រ ១៤៣)<br>- ផ្នត់ ( ក្រសួងអប់រំ , ***វេយ្យាករណ៍ថ្នាក់ទី៦*** , មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិង |

[២៨] - ក្នុងការសម្គាល់ព្រំដែន ពាក្យខ្មែរក៏មានបញ្ហាដែរ ហើយ មានតែលើសពីពាក្យបារាំងទៀតផង។

[២៩] - វាក្យសព្ទខ្ចីពីវចនានុក្រមបារាំង-ខ្មែរ របស់លោក តិប យក់ &ថាវ គន្ធ, បណ្ណាគារ ប៊ុត នាង ភ្នំពេញ ឆ្នាំ១៩២៦។

[៣០] - សូមអាន Jean-louis CHISS et alli, Initiation à la linguistique structurale, tome 1, p. 154, Hachette 1981.

[៣១] - ដើម្បីយល់ច្បាស់អំពីការប្រើប្រាស់តេស្តទាំងនោះ សូមអាន *មូលដ្ឋាននៃន័យកម្មវិទ្យា* ដោយ ព្រុំ ម៉ល់ ផ្សព្វផ្សាយដោយអ្នកនិពន្ធ ទំព័រ១៦-២០, ភ្នំពេញ ឆ្នាំ២០០៣។ ជាគោលៗ យើងសូមរាប់ឈ្មោះតេស្តទាំងនោះ ដូចតទៅ : តេស្តជែក (test d'insertion), តេស្តកំណាត់ (test de répétition partielle), តេស្តដាក់កត្តារួម (test de mise en facteur commun) និង តេស្តតំណូរ (test de commutation) ។

[៣២] - សៀវភៅនេះត្រូវបានបោះពុម្ពច្រើនឆ្នាំក្រោយពីអ្នកនិពន្ធបានទទួលមរណភាព : ដូច្នេះ ពាក្យ *បទភ្ជាប់* ប្រើក្នុងសៀវភៅនេះ ទំនងជាបានបង្កើតឡើងមុនពាក្យ *អព្ភាសបទ* របស់លោក កេង វ៉ាន់សាក់។ អ្នកនិពន្ធ អៀវ កើស បានដាក់ពាក្យបារាំង affixes ជាប់និងពាក្យ *បទភ្ជាប់* ប៉ុន្តែ *បទភ្ជាប់* ដែលគាត់បានស្រង់នោះ មានលក្ខណៈដូច affixes នៃភាសាបារាំងផង និង ដូច racines primaires របស់លោក Joseph Guesdon ផង។

| | |
|---|---|
| | សៀវភៅសិក្សា , ១៩៨២ , ទំព័រ ១)<br>គណៈកម្មការបច្ចេកសព្ទភាសាវិទ្យានិងអក្សរសិល្ប៍ សម្រេចជ្រើសរើសយក *អព្ភាសបទ/ផ្នត់* និង កំណត់និយមន័យដូចតទៅ :<br>រូបតាសម្រាប់ប្រើដើម្បីបង្កើតពាក្យកម្លាយ/កម្លាយលើកម្លាយ សម្រាប់ភ្ជាប់នឹង :<br>- ពាក្យឫស , ឧ. *ដឹង* + អព្ភាសបទ [ប៉-] > *ប្ដឹង* ,<br>- ពាក្យកម្លាយម្ដងហើយ , ឧ. *ប្ដឹង* + អព្ភាសបទ [-អ´ណ-] > *បណ្ដឹង* ,<br>- ឫស ក្នុងភាសាបារាំង , ឧទាហរណ៍ :<br>• all + អព្ភាសបទ *er* > aller ;<br>• form + អព្ភាសបទ [-sj□□] (-tion) > [f□rm<u>a</u>sj□□][៣៣] (form<u>a</u>tions),.. ។<br>លោក កេង វ៉ាន់សាក់ ចែកអព្ភាសបទជា បុព្វបទ អន្តរាបទ និង បច្ឆិមបទ ។ ក្រុមអ្នកនិពន្ធនៃវេយ្យាករណ៍ក្រសួងអប់រំ ចែកផ្នត់ជា ផ្នត់ដើម ផ្នត់ជែក និង ផ្នត់ចុង ។ |
| ១៥- **បុព្វបទ / ផ្នត់ដើម**<br>អ. prefix<br>បារ. préfixe (m.) | អព្ភាសបទឬផ្នត់មួយបែប ដែលគេដាក់នៅខាងដើមពាក្យ ដើម្បីបង្កើតពាក្យកម្លាយ , ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>• បុព្វបទ/ផ្នត់ដើម [ប´ញ-] + ចូល > បញ្ចូល,<br>• បុព្វបទ/ផ្នត់ដើម លំ + នៅ > លំនៅ,...<br>- <u>ក្នុងភាសាបារាំង</u> :<br>• បុព្វបទ/ផ្នត់ដើម in + correct > incorrect,<br>• បុព្វបទ/ផ្នត់ដើម dé + former > déformer,... |
| ១៦- **អន្តេបទ/ផ្នត់ជែក**<br>អ. infix<br>បារ. infixe (m.) | អព្ភាសបទ/ផ្នត់មួយបែបដែលគេដាក់ជ្រៀតចូលក្នុងពាក្យ ដើម្បីបង្កើតពាក្យកម្លាយ , ឧទាហរណ៍ :<br>- ចាំ + [-ម-] > ឆ្មាំ,<br>- គាប + [-ន-] > ឃ្នាប, ... ។<br><u>បញ្ជាក់</u> : លោកគ្រូ នៅ ស៊ុន បានផ្ដល់យោបល់ថា "អន្តរ/អន្តរា" មានន័យដូច "inter" នៃភាសាបារាំង, ឧ. អន្តរជាតិ = international, អន្តរក្រសួង = inter-service ,... ដូច្នេះ វាក្យសព្ទ "អន្តរាបទ" របស់លោក កេង វ៉ាន់សាក់ ត្រូវគ្នានឹង "interfixe" ដែលមានក្នុងភាសារុស្ស៊ី គឺមិនមែន "infixe" ទេ គប្បីយើងប្រែពាក្យ "infixe"ថា "អន្តេបទ" វិញ។ |
| ១៧- **បច្ឆិមបទ/ផ្នត់ចុង**<br>អ. suffix<br>បារ. suffixe (m.) | អព្ភាសបទ/ផ្នត់មួយបែបដែលគេដាក់នៅខាងចុងនៃពាក្យ ដើម្បីបង្កើតពាក្យកម្លាយ ។<br>- ក្នុងភាសាអង់គ្លេស បច្ឆិមបទ/ផ្នត់ចុង *ly* ភ្ជាប់នឹងគុណនាម *slow* បង្កើតបានជាកិរិយាវិសេសន៍ *slowly* ។ |

[៣៣] - សូរ [a] ក្នុងពាក្យ [f□rm<u>a</u>sj□□] បានកើតឡើងដើម្បីសម្រួលអំណាន ។

| | |
|---|---|
| | - ក្នុងភាសាបារាំង បច្ឆិមបទ/ផ្នត់ចុង *ment* ភ្ជាប់នឹងគុណនាម *lent* បង្កើតបាន ជាកិរិយាវិសេសន៍ *lentement* ។<br>- តាមមតិទូទៅ ភាសាខ្មែរសុទ្ធគ្មានបច្ឆិមបទ/ផ្នត់ចុង ទេ។ ប៉ុន្តែ ពាក្យខ្មែរដែលកើតពីធាតុបាលី-សំស្ក្រឹតមានប្រើបច្ឆិមបទ/ផ្នត់ចុង ដូចជា :<br>- ពល + ករ > ពលករ,<br>- នគរ + ឧបនីយកម្ម > នគរូបនីយកម្ម ។ |
| ១៨- **អាគម**<br>អ. epenthesis<br>បារ. épenthèse (f.) | សទ្ទតាដែល ឥតទាក់ទងនឹងជាតិសព្ទ កើតឡើងក្នុងពាក្យឬកន្ទោមពាក្យខ្លះ ដើម្បីជាវិសាលសូរ ឬ ដើម្បីសម្រួលអំណាន , ឧទាហរណ៍ :<br>- ភាសាបរទេស :<br>• lat. camera > frs chам**b**re (b ជា អាគម),<br>• lat. hibernum > it./port. i**n**verno (n ជា អាគម) ។<br>- ភាសាខ្មែរ :<br>• ជង់ > ជ្នង់ > **ជ្រ**នង់ [c□ɔnɔŋ] ([□ɔ] ជាអាគម,<br>• ចតុ + អង្គ > ចតុ**រ**ង្គ (រ ជាអាគម),<br>• ឆ + អភិញ្ញា > ឆ**ឡ**ភិញ្ញា (ឡ ជាអាគម តាមឯកឧត្តម ឈន អៀម) ។ |
| ១៩- **ពាក្យទោល/អមិស្សសព្ទ**<br>អ. irreducible word<br>បារ. mot (m.) irréductible | ពាក្យតូចបំផុត (ឯកព្យាង្គឬពហុព្យាង្គ) ដែលនៅមានន័យ (បើគេបំបែកតទៅទៀត ន័យត្រូវបាត់បង់) គឺជាវចនតាដែលមិនមែនជាឫស, ឧទាហរណ៍ :<br>- ក្នុងភាសាបារាំង : jardin, crayon, chaise, ...<br>- ក្នុងភាសាខ្មែរ : គាប, បារី, ក្រហម,... ។ |
| ២០- **ពាក្យឫស**<br>អ. root word<br>បារ. mot (m.) racine | ពាក្យទោលដែលអាចទទួលវិធីកម្លាយ, ឧទាហរណ៍ :<br>- ក្នុងភាសាខ្មែរ :<br>• បុព្វបទ/ផ្នត់ដើម [ប៉-] + ពាក្យឫស *ដឹង* > ប៉្ដឹង,<br>• ពាក្យឫស *គាប* + អន្តេបទ/ផ្នត់ដែក [-ន-] > ឃ្នាប ។<br>- ក្នុងភាសាបារាំង :<br>• ពាក្យឫស jardin + បច្ឆិមបទ/ផ្នត់ចុង -ier > jardinier,<br>• បុព្វបទ/ផ្នត់ដើម im- + ពាក្យឫស poli > impoli. |
| ២១- **ពាក្យគោល/ពាក្យស្នូល**<br>អ. basic word<br>បារ. lexème (m.) de base | ពាក្យទោលដែលប្រើជាបង្អែកសម្រាប់បង្កើតពាក្យកម្លាយឬពាក្យផ្សំ/ពាក្យសមាស ។<br>(១) - ឧទាហរណ៍សម្រាប់ពាក្យកម្លាយ : ដូចមានក្នុងការពន្យល់អំពី *ពាក្យឫស* ។<br>(២) - ឧទាហរណ៍សម្រាប់ពាក្យផ្សំ/ពាក្យសមាស :<br>- ក្នុងភាសាខ្មែរ :<br>• ប្រមាត់ + ដី > ប្រមាត់ដី,<br>• ទឹក + ខ្មៅ > ទឹកខ្មៅ,... ។<br>- ក្នុងភាសាបារាំង : |

| | |
|---|---|
| | • brise + glace > brise-glace,<br>• porte + feuille > portefeuille ; |
| ២២- **វិធីកម្លាយ**<br>អ. derivation<br>បារ. dérivation (f.) | វិធីមួយនៃការបង្កើតពាក្យចេញពីពាក្យឬស/ឬស តាមរយៈផ្នត់/អក្ខាសបទ.<br>ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>• [ប□□ង-] + កប់ > បង្កប់,<br>• ជួញ + [-ម-] > ឈ្មួញ,...<br>- <u>ក្នុងភាសាបារាំង</u> :<br>• im- + poli > impoli,<br>• jardin + -ier > jardinier,<br>• all + -er > aller ; |
| ២៣- **ពាក្យកម្លាយ**<br>អ. derived word<br>បារ. mot (m.) dérivé | ពាក្យដែលកើតចេញពីវិធីកម្លាយ ដូចមានឧទាហរណ៍ខាងលើ ។ |
| ២៤- **ពាក្យក្លាយ**<br>អ.transformed word<br>បារ. mot (m.) transformé | ពាក្យដែលបានផ្លាស់ប្តូរ**រូបសព្ទ** ខុសប្លែកពីពាក្យដើម ដោយបានឆ្លងកាត់មួយរយៈពេលនៃការប្រើប្រាស់. ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>• français > បារាំងសែស > បារាំង .<br>• ភ្នំដូនពេញ > ភ្នំពេញ,... ។<br>- <u>ក្នុងភាសាបារាំង</u> :<br>• *amir al-bahr* (mot arabe = " prince de la mer ") > frs *amiral,*<br>• lat. *ego* > frs *je,*<br>• lat. *pro* > frs moyen *por* > frs actuel *pur* (orth. pour). |
| ២៥- **ពាក្យសមាស/ផ្សំ**<br>អ. compound word<br>បារ. mot (m.) composé | ពាក្យដែលកើតឡើងពីការផ្សំចូលគ្នារវាងពាក្យនិងពាក្យ ចាប់ពីពីរពាក្យឡើងទៅ ហើយ សំគាល់ន័យឬបញ្ញត្តិមួយច្បាស់លាស់ ។ ពាក្យផ្សំ/ពាក្យសមាសជាកន្សោម ស្អិត ដែលមានតម្លៃដូចពាក្យទោលមួយដែរ( ពាក្យទោលឯកព្យាង្គឬពាក្យទោលពហុព្យាង្គ),<br>ឧទាហរណ៍ :<br>- ក្នុងភាសាខ្មែរ : ដីស, ទឹកខ្មៅ,... ។<br>- ក្នុងភាសាបារាំង : porte-monnaie, portefeuille, bon sens, pomme de terre,... ។ |
| ២៦- **រូបសព្ទ**<br>អ. morphology<br>បារ. morphologie (f.) | ទម្រង់របស់ពាក្យ ហើយ ដោយភាសាជាសូរ ទម្រង់នេះជាសូរដែលស្តាប់ឮ ប៉ុន្តែ វាក៏អាចជារូបដែលគេមើលឃើញតាមរយៈសំណេរផងដែរ ។<br>ក្នុងពាក្យកម្លាយឬពាក្យសមាស គេអាចវិភាគរូបសព្ទជាចំណែកៗ . ឧទាហរណ៍ : |

| | |
|---|---|
| | - បញ្ចូល < [ ប□□ញ-] + ចូល<br>- ពលកម្ម < ពល + កម្ម |
| ២៧- **នាម**<br>អ. noun<br>បារ. nom (m.) | ពាក្យសម្រាប់សំគាល់ឈ្មោះ មនុស្ស, សត្វ, រុក្ខជាតិ, ទីកន្លែង, វត្ថុ, ស្ថានភាព, សកម្មភាព ឬ គំនិតអ្វីមួយ និង អាចបំពេញមុខងារជាប្រធាន ឬ កម្ម នៅក្នុងល្បះ។ នាមជាធាតុចាំបាច់នៃកន្សោមនាម ។<br>ពាក្យ : ពូសុខ តុ គោ ដំណើរ ឈ្មួញ រដ្ឋាភិបាល ... ជានាម ។ |
| ២៨- **សព្វនាម**<br>អ. pronoun<br>បារ. pronom (m.) | ពាក្យដែលគេប្រើសម្រាប់ជំនួស នាម កន្សោមនាម និង ល្បះ ដើម្បីចៀសការប្រើពាក្យច្រំដែល។ ក្នុងសម្ព័ន្ធ សព្វនាមបំពេញមុខងារដូចនាមនិងកន្សោមនាមដែរ : សព្វនាមអាចជាប្រធានក្នុងល្បះ អាចជាកម្មក្នុងល្បះ, ឧទាហរណ៍ :<br>- *គាត់ភ្ជួរស្រែ,* **គាត់** មានមុខងារជាប្រធាន,<br>- *អ្នកស្រុកស្គាល់វាច្បាស់ណាស់,* **វា** មានមុខងារជាកម្មបទផ្ទាល់ ( កម្មបទផ្ទាល់ = complément d’objet direct ) ។<br>- *ពូសុខតែងតែខឹងច្រឡោត បើគាត់មិនខំកែខ្លួនទេ វានឹងនាំមកដល់គាត់នូវសត្រូវជុំទិស* ។<br>នៅក្នុងភាសាខ្មែរ គេចែកសព្វនាម ជា : សព្វនាមបុរិសៈ, សព្វនាមឈ្នាប់, សព្វនាមចង្អុល, សព្វនាមសំណួរ, សព្វនាមមិនច្បាស់ ។ |
| ២៩- **សព្វនាមបុរិសៈ**<br>អ. personal pronoun<br>បារ. pronom personnel | សព្វនាមដែលតំណាងបុរិសទាំងបី ។<br>ក្នុងភាសាខ្មែរ សព្វនាមបុរិសៈមាន :<br>- បុរិសៈទី១ : *ខ្ញុំ អញ យើង* ... ។<br>- បុរិសៈទី២ : *ឯង អ្នក* ... ។<br>- បុរិសៈទី៣ : *វា គាត់ នាង* ... ។ |
| ៣០- **សព្វនាមឈ្នាប់**<br>អ. relative pronoun<br>បារ. pronom (m.) relatif | សព្វនាមសម្រាប់ជំនួសនាមឬកន្សោមនាមដើម្បីបង្កើតល្បះរណប ។<br>នៅក្នុងភាសាខ្មែរ សព្វនាមឈ្នាប់មានតែមួយ គឺ *ដែល* , ឧទាហរណ៍ :<br>- *ខ្ញុំបានជួបកុមារម្នាក់ដែលរៀនពូកែជាងគេក្នុងសាលារៀននេះ* ។<br>- *តុដែលគេដាក់ថូផ្កានៅលើនោះ ជារបស់គាត់* ។ |
| ៣១- **សព្វនាមចង្អុល**<br>អ. demonstrative pronoun<br>បារ. pronom (m.) démonstratif | សព្វនាមដែលប្រើសម្រាប់ចង្អុលបង្ហាញមនុស្ស សត្វ ឬ វត្ថុ ឱ្យឃើញច្បាស់លាស់ ថានៅទីជិត ឬ ទីឆ្ងាយ ពីអ្នកនិយាយ ។ ពាក្យ *នេះ នោះ* ,... ជាសព្វនាមចង្អុល, ឧទាហរណ៍ : *នេះជាសៀវភៅរបស់ខ្ញុំ នោះជាសៀវភៅរបស់ឯង* ។ |
| ៣២- **សព្វនាមសំណួរ**<br>អ. interrogative pronoun<br>បារ. pronom (m.) interrogatif | សព្វនាមប្រើសម្រាប់សួររកប្រធាន ឬ សួររកកម្មរង/កម្មបទ របស់កិរិយាសព្ទ។ សព្វនាមសំណួរ មានដូចជា : នរណា អ្វី នរណាមួយ អ្វីមួយ ... , ឧទាហរណ៍ :<br>- *នរណាដើរកាត់ទីនេះ?* ( សួររកប្រធាន)<br>- *ឯងនិយាយអំពីអ្វី?* ( សួររកកម្មបទមិនផ្ទាល់; កម្មបទមិនផ្ទាល់ = complé- |

| | |
|---|---|
| | ment d'objet indirect),<br>- *គាត់ទិញអ្វី?* (សួររកកម្មបទផ្ទាល់)។ |
| ៣៣- **សព្វនាមមិនច្បាស់**<br>អ. indefinite pronoun<br>បារ. pronom (m.) indéfini | សព្វនាមដែលគេប្រើជំនួសនាមឬកន្សោមនាម ដែលស្ថិតក្នុងលក្ខណៈទូទៅ ដោយមិនបញ្ជាក់ច្បាស់ចំពោះនាម ឬ កន្សោមនាមណាមួយឡើយ។ ពាក្យ *នរណាម្នាក់ អ្នករាល់គ្នា នរណាមួយ ...* ជាសព្វនាមមិនច្បាស់, ឧទាហរណ៍ :<br>- *អ្នករាល់គ្នាត្រូវទៅឡើងឡាននៅម៉ោង៦ព្រឹក។*<br>- *នរណាម្នាក់ស្ម័គ្រចិត្តចូលរួមសន្និសីទអាស៊ាន។* |
| ៣៤- **គុណនាម**<br>អ. adjective<br>បារ. adjectif (m.) | ពាក្យអាស្រ័យនឹងនាម ហើយ ជាធាតុនៃកន្សោមនាម។ គេចែកគុណនាមជាពីរក្រុម :<br>- គុណនាមប្រក្រតី,<br>- គុណនាមកំណត់។<br>គុណនាមប្រក្រតីមានតែមួយប្រភេទទេ ប៉ុន្តែ គុណនាមកំណត់មានច្រើនប្រភេទ គឺ :<br>- គុណនាមចង្អុល,<br>- គុណនាមចំនួន (សំខ្យាសព្ទ),<br>- គុណនាមមិនច្បាស់,...។<br>ពាក្យ *ខ្ពស់, ធំ, នេះ, នោះ, ពីរ, បី, ទាំងឡាយ, នានា* ... ជាគុណនាម។ |
| ៣៥- **គុណនាមប្រក្រតី**<br>អ. qualificative adjective<br>បារ. adjectif (m.) qualificatif | គុណនាមប្រក្រតីជាពាក្យមួយប្រភេទ ដែលអាស្រ័យនឹងនាម បញ្ជាក់លក្ខណៈឱ្យនាម ដូចកម្មរបស់នាមដែរ។ កម្មរបស់នាមអាចជានាមឬជាកិរិយាសព្ទ ប៉ុន្តែ គុណនាមប្រក្រតីមានលក្ខណៈប្លែកពីកម្មរបស់នាម ដូចមានឧទាហរណ៍ខាងក្រោម :<br>១- ការបញ្ជាក់លក្ខណៈឱ្យនាម (ដូចកម្មរបស់នាមដែរ), ឧទាហរណ៍ :<br>១.១- ផ្ទះល្អ (*ល្អ* គុណនាមដែលមានមុខងារជាគុណបទ (épithète) របស់ *ផ្ទះ*),<br>១.២- ផ្ទះថ្ម (*ថ្ម* នាមដែលមានមុខងារជាកម្មរបស់ *ផ្ទះ*)<br>១.៣- ផ្ទះជួល (*ជួល* កិរិយាសព្ទដែលមានមុខងារជាកម្មរបស់ *ផ្ទះ*)<br>គេអាចថា : *ផ្ទះដ៏ល្អ* ប៉ុន្តែ គេមិនអាចថា : * *ផ្ទះដ៏ថ្ម* ឬ * *ផ្ទះដ៏ជួល* បានឡើយ។<br>២- គេអាចដាក់គុណនាមប្រក្រតី *ល្អ* ឱ្យទៅជាវិសេសគុណនាម ឬ ជាអតិវិសេសគុណនាម ប៉ុន្តែ កម្មរបស់នាម ដែលជានាមឬជាកិរិយាសព្ទនោះ គេមិនអាចដាក់វាឱ្យទៅជាវិសេសគុណនាម ឬ អតិវិសេសគុណនាម បានទេ, ឧទាហរណ៍ :<br>២.១- *ផ្ទះល្អ* អាចដាក់ទៅជាវិសេសគុណនាម : *ផ្ទះនេះល្អជាងផ្ទះនោះ*<br>២.២- *ផ្ទះល្អ* អាចដាក់ទៅជាអតិវិសេសគុណនាម : *ផ្ទះនេះល្អណាស់/ល្អពេក,...*<br>រីឯ *ផ្ទះថ្ម, ផ្ទះជួល* វិញ គេមិនអាចដាក់វាឱ្យទៅជាវិសេសគុណនាម ឬ អតិវិសេសគុណនាម ទេ, ឧទាហរណ៍ :<br>២.៣- * *ផ្ទះនេះថ្មជាងផ្ទះនោះ*, * *ផ្ទះនេះជួលជាងផ្ទះនោះ,...*<br>២.៤- * *ផ្ទះនេះថ្មណាស់*, * *ផ្ទះនេះជួលណាស់,...* |

| | |
|---|---|
| | ៣- គុណនាមប្រក្រតី អាចមានទម្រង់បដិសេធ (ដូចកិរិយាសព្ទដែរ ផ្ទុយពីនាមដែលជាកម្មរបស់នាមគ្នាឯង), ឧទាហរណ៍ :<br>៣.១- គុណនាមប្រក្រតី : ផ្ទះល្អ > ផ្ទះមិនល្អ<br>៣.២- នាមដែលជាកម្មរបស់នាម : ផ្ទះថ្ម > * ផ្ទះមិនថ្ម ។ |
| ៣៦- **គុណនាមចង្អុល**<br>អ.demonstrative adjective<br>បារ. adjectif (m.) démonstrative | គុណនាមប្រើសម្រាប់ចង្អុលបង្ហាញមនុស្ស សត្វ វត្ថុ ឬ រុក្ខជាតិ ឱ្យឃើញច្បាស់លាស់ថា នៅទីជិតឬទីឆ្ងាយពីអ្នកនិយាយ, ឧទាហរណ៍ :<br>*សៀវភៅ<u>នេះ</u>ជារបស់ខ្ញុំ សៀវភៅ<u>នោះ</u>ជារបស់ឯង* ។<br>ពាក្យ *នេះ, នោះ, ទាំងនេះ, ទាំងនោះ,...* ជាគុណនាមចង្អុល ។ |
| ៣៧- **គុណនាមចំនួន/សំខ្យាសព្ទ**<br>អ. numeral adjective<br>បារ. adjectif (m.) numéral | គុណនាមចំនួន ឬ សំខ្យាសព្ទជាពាក្យដែលប្រើសម្រាប់បញ្ជាក់ចំនួនឬលំដាប់ ។<br>គុណនាមចំនួន មានគុណនាមចំនួនសម្រាប់រាប់ និង គុណនាមសម្រាប់សម្គាល់លំដាប់, ឧទាហរណ៍ :<br>- គុណនាមចំនួនសម្រាប់រាប់ (បកតិសំខ្យា) : តុមួយ, ស្លាបព្រាមួយ ,...<br>- គុណនាមចំនួនសម្គាល់លំដាប់ (បូរណសំខ្យា) : តុទី១, ស្លាបព្រាទី១ ...<br><u>សង្កេត</u> : ចំពោះគុណនាមចំនួនសម្រាប់រាប់ បើគេដាក់គុណនាមនេះនៅមុខនាម វាមានន័យមួយយ៉ាង ហើយ បើគេដាក់វានៅក្រោយនាម វាមានន័យមួយយ៉ាងទៀត, ឧទាហរណ៍ :<br>- *ផ្ទះមួយ* សម្គាល់ចំនួនផ្ទះ,<br>- *មួយផ្ទះ* សម្គាល់ចំនួនមនុស្សដែលរស់នៅក្នុងផ្ទះណាមួយ ។ |
| ៣៨- **គុណនាមមិនច្បាស់**<br>អ. indefinite adjective<br>បារ. adjectif (m.) indéfini | គុណនាមប្រើសម្រាប់បង្ហាញមនុស្ស សត្វ ឬ វត្ថុ ដោយមិនបញ្ជាក់ច្បាស់លាស់, ឧទាហរណ៍ :<br>- *និស្សិត**<u>ណា</u>**ដែលមិនបានប្រឡងថ្ងៃនេះ ត្រូវមកប្រឡងនៅពេលក្រោយ* ។<br>- *សមាជិក**<u>ទាំងអស់</u>**ត្រូវមកជួបជុំគ្នានៅពេលរសៀល* ។<br>ពាក្យ *ណា, ណាមួយ, ណាម្នាក់, ទាំងឡាយ, ទាំងពួង, ទាំងអស់,...* ជាគុណនាមមិនច្បាស់ ។ |
| ៣៩- **កិរិយាសព្ទ**<br>អ. verb<br>បារ. verbe (m.) | ពាក្យដែលមានមុខងារសំខាន់ជាប្រណាប់ប្រធាន[៣៤] /បម្រាប់ប្រធាន ហើយ ដែលគេអាចដាក់ឱ្យទៅជាទម្រង់បដិសេធបាន, ឧទាហរណ៍ : ពាក្យ *ដើរ, ហូប, អាន, ទៅ, ដឹក, ហៅ,...* ជាកិរិយាសព្ទ ។ |
| ៤០- **កិរិយាវិសេសន៍ / គុណកិរិយា**<br>អ. adverb<br>បារ. adverbe (m.) | ពាក្យប្រើសម្រាប់សម្ដែងលក្ខណៈឱ្យ កិរិយាសព្ទ គុណនាម ឬ កិរិយាវិសេសន៍គ្នាឯង, ឧទាហរណ៍ :<br>- *ទឹកភ្នែកនាងហូរ**<u>សស្រាក់</u>*** ។ |

[៣៤] - ពាក្យ *ប្រណាប់* មកពីពាក្យ *ប្រាប់* ( *ប្រាប់ > ប្រណាប់* ) ត្រូវបានបង្កើតឡើងតាមគំរូ *ទ្រាប់ > ទ្រនាប់* ។

| | |
|---|---|
| | - *ទីនេះងងឹត**ណាស់***។<br>- *ឯងកុំដើរលឿន**ពេក!*** |
| ៤១- **ធ្នាក់**<br>អ. preposition<br>បារ. préposition (f.) | បញ្ញត្តិនេះត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នា :<br>- អាយតនិបាត[៣៥]<br>- និបាតសព្ទ[៣៦]<br>- ធ្នាក់[៣៧]<br>- ស្នៀត[៣៨]<br>គណៈកម្មការភាសាវិទ្យានិងអក្សរសិល្ប៍បានសម្រេច ជ្រើសរើសយកពាក្យ *ធ្នាក់* និងកំណត់ន័យ ដូចតទៅ :<br>ធ្នាក់ជាពាក្យប្រើជាមួយនឹង នាម កន្សោមនាម ឬ កន្សោមកិរិយា ដើម្បីបង្កើតកន្សោមធ្នាក់ (កន្សោមមានធ្នាក់) , ឧទាហរណ៍ :<br>- វិទ្យាស្ថានភាសាជាតិ **នៃ**រាជបណ្ឌិតសភាកម្ពុជា<br>- **ក្នុង**ផ្ទះ , **ក្រៅ**ផ្ទះ ។<br>ពាក្យ *នៃ លើ ក្នុង ក្រៅ ជាមួយ ពី អំពី ដល់ ដោយ*... ជាធ្នាក់។ |
| ៤២- **ឈ្នាប់**<br>អ. conjunction<br>បារ. conjonction (f.) | បញ្ញត្តិនេះក៏ត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នាដែរ :<br>- និបាតសព្ទ[៣៩]<br>- សន្ធានសព្ទ[៤០]<br>- ឈ្នាប់[៤១]<br>- ចំណង[៤២]<br>គណៈកម្មការភាសាវិទ្យានិងអក្សរសិល្ប៍ បានសម្រេចជ្រើសរើសយកពាក្យ *ឈ្នាប់* ហើយ កំណត់ន័យ ដូចតទៅ :<br>ឈ្នាប់ជាពាក្យដែលគេប្រើសម្រាប់ភ្ជាប់ពាក្យទៅនឹងពាក្យ កន្សោមពាក្យទៅនឹងកន្សោមពាក្យ ឬ ល្បះទៅនឹងល្បះ។<br>ពាក្យ *និង, ឬ, ប៉ុន្តែ, ពីព្រោះ, ព្រោះ, បើ,*.... ជាឈ្នាប់។<br>គេចែកឈ្នាប់ជាពីរបែប : ឈ្នាប់ចង និង ឈ្នាប់ឃ្លា។ |

[៣៥] - វចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៨, ទំព័រ១៧៤៤ និង ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ , បណ្ណាគារ គីម សេង , ភ្នំពេញ , ១៩៥៨។

[៣៦] - កេង វ៉ាន់សាក់ , មូលភាពនៃការបង្កើតពាក្យថ្មី , មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ភ្នំពេញ ឆ្នាំ១៩៦៤ ទំព័រ៣៨៣។

[៣៧] - វេយ្យាករណ៍ថ្នាក់ទី៦, ក្រសួងអប់រំ, ឆ្នាំ១៩៨២ , ទំព័រ៤១។

[៣៨] - ឃីន សុខ , វេយ្យាករណ៍ភាសាខ្មែរ , រាជបណ្ឌិតសភាកម្ពុជា , ឆ្នាំ២០០៧ , ទំព័រ៣៥៧។

[៣៩] - វចនានុក្រមខ្មែរ , ពុទ្ធសាសនបណ្ឌិត្យ , ឆ្នាំ១៩៦៨ , ទំព័រ៥១១។

[៤០] - តិប យក់ & ថាវ គន្ធ, វចនានុក្រមបារាំង-ខ្មែរសង្ខេប , បណ្ណាគារភ្នំពេញ, ឆ្នាំ១៩៦៧ , ទំព័រ២៣៤។

[៤១] - វេយ្យាករណ៍ថ្នាក់ទី៦, ក្រសួងអប់រំ , ឆ្នាំ១៩៨២ , ទំព័រ៤២។

[៤២] - ឃីន សុខ , វេយ្យាករណ៍ភាសាខ្មែរ , រាជបណ្ឌិត្យសភាកម្ពុជា , ឆ្នាំ២០០៧ , ទំព័រ៣៨៧។

**៤៣- ឈ្នាប់ចង**

អ.coordinating conjunction

បារ. conjonction (f.) de coordination

ឈ្នាប់ប្រើសម្រាប់ភ្ជាប់ធាតុពីរដែលមានមុខងារដូចគ្នាក្នុងល្បះ ល្បះពីរដែលមានប្រភេទដូចគ្នា , ឧទាហរណ៍ :

- ខ្លានិងស្វា បបួលគ្នាទៅជួបនឹងទន្សាយ[៤៣]។
- ក្នុងគ្រានេះ, ខ្ញុំលៃពេលម៉ោង (...), បានដកស្រង់យកកាព្យ (...), សុភាសិតនិងភាសិតបុរាណខ្លះ និង កាព្យរបស់ខ្ញុំខ្លះ[៤៤] (...), (វចនានុក្រមពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧, និទាន, ទំព័រ ង)។
- ឯងត្រូវការទឹកឬកាហ្វេ ?
- គាត់ធ្វើការនៅរាជបណ្ឌិត្យសភាកម្ពុជា ឯ ប្រពន្ធគាត់ធ្វើការនៅក្រសួងអប់រំ។
- ប្រជាជនយើងរស់នៅទីកន្លែងផ្សេងៗគ្នា។ អ្នកខ្លះរស់នៅស្រុកទន្លេ ខ្លះរស់នៅស្រុកភ្នំ ខ្លះរស់នៅស្រុកស្រែ និង ខ្លះទៀតរស់នៅទីក្រុង។

**៤៤- ឈ្នាប់ឃ្នា**

អ. subordinating conjunction

បារ. conjonction (f.) de subordination

ឈ្នាប់ប្រើសម្រាប់ភ្ជាប់ល្បះរណបទៅនឹងល្បះច្បង, ឧទាហរណ៍ :

- ខ្ញុំលើកទ័ព ពីព្រោះខ្ញុំព្រួយព្រួយស្គាល់[៤៥]។
- គាត់នឹងបង្ហើយកិច្ចការនេះ បើគាត់ត្រឡប់មកវិញ។

**៤៥- វិភត្តិ**

អ. inflection

បារ. flexion (f.)

"ចំណែកប្រាប់ដំណើរបំបែកនាមសព្ទនិងកិរិយាសព្ទក្នុងវេយ្យាករណ៍ខាងតន្តិភាសាមានភាសាសំស្រ្កឹតនិងបាលីជាដើម ឱ្យមានលំនាំផ្សេងៗគ្នា" (ជួន ណាត , វចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧-៦៨)។

**៤៦- ការបំបែកនាម**

អ. declension

បារ. déclinaison (f.)

ដំណើរបំបែកនាមដោយប្រើភាគខាងចុងផ្សេងៗគ្នាទៅតាមមុខងារនៃនាមក្នុងល្បះ។

**នៅក្នុងវេយ្យាករណ៍បាលី វិភត្តិនាមមាន៨ គឺ :**

| | **ឯកវចនៈ** | **ពហុវចនៈ** |
|---|---|---|
| បឋមាវិភត្តិ | *បុរិសោ* | *បុរិសា* |
| ទុតិយាវិភត្តិ | *បុរិសំ* | *បុរិសេ* |
| តតិយាវិភត្តិ | *បុរិសេន* | *បុរិសេហិ , បុរិសេភិ* |
| ចតុត្ថីវិភត្តិ | *បុរិសស្ស , បុរិសាយ , បុរិសត្ថំ* | *បុរិសានំ* |
| បញ្ចមីវិភត្តិ | *បុរិសស្មា , បុរិសម្ហា , បុរិសា* | *បុរិសេហិ , បុរិសេភិ* |
| ឆដ្ឋីវិភត្តិ | *បុរិសស្ស* | *បុរិសានំ* |

[៤៣] - ប្រជុំរឿងព្រេងខ្មែរ ភាគទី១ ទំព័រ៣៥។

[៤៤] - ចំពោះការដកឃ្លា (ដំណកឃ្លា) សូមអានអត្ថបទ *ពិនិត្យពិចារណាលើការប្រើប្រាស់សញ្ញាប្រយោគមួយចំនួន ក្នុងភាសាខ្មែរបច្ចុប្បន្ន* ដោយ ព្រុំ ម៉ល់ , បទអន្តរាគមន៍ក្នុងសន្និសីទជាតិលើកទី២ រៀបចំដោយ វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៥ និង ចុះជាឧបសម្ពន្ធ័ក្នុង *វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប* ភាគ២ ឆ្នាំ២០០៦, ទំព័រ៦៣-៧៦។

[៤៥] - ប្រជុំរឿងព្រេងខ្មែរ ភាគទី១ ទំព័រ២៣។

| | | |
|---|---|---|
| សត្តមីវិភត្តិ | *បុរិសស្មឹ . បុរិសម្ហិ . បុរិសេ* | *បុរិសេសុ* |
| អាលបនៈ | *បុរិស* | *បុរិសា* |

**<u>កំណត់សម្គាល់</u>** :

- វិភត្តិសព្វនាម និង វិភត្តិគុណនាម មានលំនាំដូចគ្នានឹងវិភត្តិនាមដែរ។
- ក្នុងតារាងខាងលើ គេបង្ហាញវិភត្តិរបស់ពាក្យមួយដែលមានការប្រែប្រួលខាងចុងទៅតាមមុខងាររបស់វាក្នុងល្បះ។
- ខាងក្រោម ជាឧទាហរណ៍ជាក់ស្តែងនៃការប្រើប្រាស់វិភត្តិទៅតាមមុខងាររបស់ពាក្យក្នុងល្បះ ប៉ុន្តែ គេបានប្រើពាក្យផ្សេងៗគ្នាឱ្យស្របតាមបរិបទ។

១-បឋមាវិភត្តិ (ត្រូវនឹងវិភត្តិឡាតាំង ហៅតាមបារាំងថា : nominatif) សម្រាប់មុខងារជាប្រធាន , ឧទាហរណ៍ :

***កសិករោ*** *ខេត្តំ កសតិ (**កសិករ**ភ្ជួររស្រែ) ។*

២-ទុតិយាវិភត្តិ (ត្រូវនឹងវិភត្តិឡាតាំង ហៅតាមបារាំងថា : accusatif) សម្រាប់មុខងារជាកម្មបទផ្ទាល់ (complément d'objet direct) , ឧទាហរណ៍ :

*សិស្សោ **អក្ខរំ** ឧគ្គណ្ហាតិ (សិស្សរៀន**អក្សរ**) ។*

៣-តតិយាវិភត្តិ (ablatif d'agent et ablatif d'instrument) សម្រាប់មុខងារជា :

- កម្មភ្នាក់ងារ , ឧ. *អយំ គេហោ មម **មាតុលេន** និម្មិយតេ (ផ្ទះនេះសង់**ដោយពូ**ខ្ញុំ) ។*
- កម្មមធ្យោបាយ , ឧ. *កសិករោ **នង្គលេន** ខេត្តំ កសតិ (កសិករភ្ជួររស្រែ**នឹងនង្គ័ល**) ។*

៤- ចតុត្ថីវិភត្តិ (ត្រូវនឹងវិភត្តិឡាតាំង ហៅតាមបារាំងថា : datif) សម្រាប់មុខងារជាកម្មសម្បទាន ប្រាប់សេចក្តីទទួល (complément d'attribution) , ឧទាហរណ៍ :

*ពុទ្ធោ លោកេ **មនុស្សានំ** ធម្មំ ទេសេតិ (ព្រះពុទ្ធសម្តែងធម៌**ដល់មនុស្ស**ក្នុងលោក) ។*

៥- បញ្ចមីវិភត្តិ សម្រាប់មុខងារជាកម្មអបាទាន ប្រាប់សេចក្តីឃ្លាតចាក (ablatif de séparation)[៤៦] , ឧទាហរណ៍ :

*មយំ **វាណិជស្មា** មញ្ចំ កិណាម (យើងទិញគ្រែ**ពីឈ្មួញ**) ។*

៦- ឆដ្ឋីវិភត្តិ (ត្រូវនឹងវិភត្តិឡាតាំង ហៅតាមបារាំងថា : génitif) សម្រាប់មុខងារជាកម្មរបស់នាម , ឧទាហរណ៍ :

*លោកេ មនុស្សា **សុរិយស្ស** រំសី បស្សន្តិ (មនុស្សទាំងឡាយ ក្នុងលោក*

---

[៤៦] - វិភត្តិឡាតាំង ablatif តែមួយ មានមុខងារជាកម្ម(បទ)ទេសកាលច្រើនយ៉ាង ដូចមានការបញ្ជាក់ក្នុងវិភត្តិនាមឡាតាំងស្រាប់ ។

| | |
|---|---|
| | *ឃើញពន្លឺ**ព្រះអាទិត្យ*** ។<br>៧- សត្តមីវិភត្តិ (locatif)[៤៧] សម្រាប់មុខងារជាកម្មទេសកាលសម្គាល់ទីកន្លែង ,<br>ឧទាហរណ៍ :<br>*មច្ឆា **ជលេ** វសន្តិ ( ត្រីទាំងឡាយរស់នៅ**ក្នុងទឹក**)* ។<br>៨- អាលបនៈ (ត្រូវនឹងវិភត្តិឡាតាំង ហៅតាមបារាំងថា : vocatif) សម្រាប់ហៅ ,<br>ឧទាហរណ៍ :<br>***បុត្ត** សាលំ គច្ឆាហិ ( **ម្នាលកូន** ចូរឯងទៅសាលា)* ។<br><br>**វិភត្តិនាមឡាតាំងមាន៦បែប គឺ :**<br>១- Nominatif : មានមុខងារជាប្រធាន ,<br>២- Accusatif : មានមុខងារជាកម្មបទផ្ទាល់ ,<br>៣- Génitif.... : មានមុខងារជាកម្មសម្រាប់នាមដូចគ្នា ,<br>៤- Datif........ : មានមុខងារជាកម្មសម្បទាន (complément d'attribution),<br>ឧទាហរណ៍ : donner quelque chose *à quelqu'un,*<br>(*à quelqu'un* ជាកម្មសម្បទាន ) ,<br>៥- Ablatif..... : មានមុខងារជាកម្មទេសកាលសម្គាល់ បែប, ប្រភព,<br>មធ្យោបាយ, ទីកន្លែង ,<br>៦- Vocatif.... : សម្រាប់ហៅ ។ |
| ៤៧- **ការបំបែកកិរិយាសព្ទ**<br>អ. conjugation<br>បារ. conjugaison (f.) | ដំណើរបំបែកកិរិយាសព្ទដោយប្រើភាគខាងចុងប្លែកៗគ្នាទៅតាមបទមាលា (mode) តាមកាល (temps) និង តាមបុរិសៈ/បុរស (personne),<br>ឧទាហរណ៍ : កិរិយាសព្ទបារាំង *marcher* ក្នុង mode indicatif, temps présent ត្រូវគេបំបែក ដូចតទៅ :<br><table><tr><th></th><th>ឯកវចនៈ</th><th>ពហុវចនៈ</th></tr><tr><td>បុរសទី១</td><td>Je marche</td><td>nous marchons</td></tr><tr><td>បុរសទី២</td><td>Tu marches</td><td>vous marchez</td></tr><tr><td>បុរសទី៣</td><td>il/elle marche</td><td>ils/elles marchent</td></tr></table> |
| ៤៨- **កម្ម**<br>អ. complement | បញ្ញត្តិនេះត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នា តាមអ្នកវេយ្យាករណ៍ គឺ<br>- កម្មរង[៥៨]<br>- កម្មបទ[៤៩] |

[៤៧] - ភាសាឡាតាំងគ្មាន locatif ទេ ប៉ុន្តែ ភាសាអឺរ៉ុបបុរាណខ្លះមាន locatif នេះ ។
[៤៨] - ពូវ អ៊ុម , *វេយ្យាករណ៍ខ្មែរ* បណ្ណាគារ គីម សេង ភ្នំពេញ ឆ្នាំ១៩៥៥ ទំព័រ៣២ ។

| | |
|---|---|
| បារ. complément (m.) | - បទកម្ម[50]<br>- កម្ម[51]<br><br>*គណៈកម្មការភាសាវិទ្យានិងអក្សរសិល្ប៍* បានសម្រេចជ្រើសរើសយកពាក្យ *កម្ម* និងកំណត់ន័យដូចតទៅ : កម្មជាពាក្យរណបសម្រាប់បង្គ្រប់សេចក្ដីឱ្យពាក្យដែលខ្លួនជារណប ។ តាមធម្មតា កម្មជាពាក្យឬកន្សោមពាក្យចាំបាច់សម្រាប់កិរិយាសព្ទ ដែលប្រើជាប្រណាប់ប្រធាន/បម្រាប់ប្រធាន ដើម្បីធ្វើឱ្យឃ្លះមានវេយ្យាករណភាព ( មានលក្ខណៈស្របនឹងក្បួនវេយ្យាករណ៍ ), ឧទាហរណ៍ :<br>- គោស៊ី*ស្មៅ.*<br>- ខ្ញុំបានឱ្យ*សៀវភៅមួយក្បាលទៅកូនប្រុសខ្ញុំ.*<br>- រឿង "កុលាបប៉ៃលិន" ត្រូវបាននិពន្ធ*ដោយលោក ញ៉ុក ថែម.*<br>គេចែកកម្មជា កម្មបទ (complément d'objet), កម្មទេសកាល (complément circonstanciel), កម្មភ្នាក់ងារ (complément d'agent),... ។ |
| ៤៩- **កម្មបទ**<br>អ. object (complement)<br>បារ. complément (m.) d'objet | កម្មប្រើជាមួយកិរិយាសកម្ម ដើម្បីឱ្យឃ្លះមានវេយ្យាករណភាព ។ គេចែកកម្មបទជាពីរក្រុម :<br>- កម្មបទផ្ទាល់<br>- កម្មបទមិនផ្ទាល់<br>ឧទាហរណ៍ :<br>- គោស៊ីស្មៅ ( *ស្មៅ* ជាកម្មបទផ្ទាល់ )<br>- ខ្ញុំបានឱ្យសៀវភៅមួយទៅកូនប្រុសខ្ញុំ ( *ទៅកូនប្រុសខ្ញុំ* ជាកម្មបទមិនផ្ទាល់ ) ។ |
| ៥០- **កម្មទេសកាល**<br>អ. circumstantial complement<br>បារ. complément (m.) circonstanciel | កម្មប្រើសម្រាប់សំគាល់ ពេលវេលា , ទីកន្លែង , ... ឧទាហរណ៍ :<br>- ម្សិលមិញ ខ្ញុំបានទិញត្រីរស់មួយគីឡូ ( *ម្សិលមិញ* ជាកម្មទេសកាលសំគាល់ពេលវេលា ) ។<br>- គាត់ធ្វើការ នៅក្រសួងអប់រំ ( *នៅក្រសួងអប់រំ* ជាកម្មទេសកាលសំគាល់ទីកន្លែង ) ។ |

[49] - កេង វ៉ាន់សាក់ , ដ.ឯ.ម., ទំព័រ ៣៨១ ។
[50] - អ៊ុយ ជួន , *វេយ្យាករណ៍ពិសេស* រោងពុម្ព គឹម គី បណ្ណាគារលេខ៨៤ វិថីតេជោដំឌិន ភ្នំពេញ ឆ្នាំ១៩៥៨ ទំព័រ ២៤៣ និង ថូ ធន, *វេយ្យាករណ៍អក្ខរាវិរុទ្ធ* បណ្ណាគារ ឃុន ថៃស៊ាង ក្រចេះ ឆ្នាំ១៩៧១ ទំព័រ ១១៧ ។
[51] - ក្រសួងអប់រំ , *វេយ្យាករណ៍ ថ្នាក់ទី៥* រោងពុម្ពរណសិរ្ស ភ្នំពេញ ឆ្នាំ១៩៨៣ ទំព័រ ១១៨ ។

# បញ្ជីរាយនាមសប្បុរសជន

ដើម្បីជាសាក្ខីកម្មនៃកតញ្ញូតាធម៌ចំពោះសប្បុរសជនដែលបានធ្វើអំណោយដល់ គ.ជ.ភ.ខ. ដើម្បីឱ្យគណៈកម្មាធិការនេះ ទុកប្រើប្រាស់ក្នុងស្ថានភាពពិសេសឬបន្ទាន់ដែលខ្លួនសុំថវិការដ្ឋមិនបានឬមិនទាន់ យើងខ្ញុំសូមចុះផ្សាយឈ្មោះសប្បុរសជនទាំងនោះ ដូចខាងក្រោម :

- លោកអគ្គបណ្ឌិត ប៊ុត សាវង្ស ឧបត្ថម្ភថវិកាចំនួន ១៣ ៦៥០ ០០០៛ ,
- ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប ឧបត្ថម្ភថវិកាចំនួន ១ ៥០០$ ,
- លោកសាស្ត្រាចារ្យ មាស តាំ ឧបត្ថម្ភថវិកាចំនួន ៣ ៣២៥ ០០០៛ ,
- លោក Douc cooper ឧបត្ថម្ភថវិកាចំនួន ៧៥០$ ,

**សរុបទឹកប្រាក់ទទួលបានត្រឹមថ្ងៃ២៣ ខែមីនា ឆ្នាំ២០១០ : <u>១៦ ៩៧៥ ០០០៛</u> និង <u>២ ២៥០$</u>** ។

ចំពោះទឹកប្រាក់ដែលទទួលបាននោះ គ.ជ.ភ.ខ. បានទិញទូដាក់សៀវភៅចំនួន ០២, ទិញម៉ាស៊ីនត្រជាក់ថែម ០១ គ្រឿង, ទិញ LCD ០១គ្រឿង, បោះពុម្ពព្រឹត្តិបត្រលេខ០២បន្ថែមចំនួន ១ ០០០ក្បាល, ទិញវចនានុក្រម សទ្ទានុក្រម សៀវភៅនានា និង តម្រូវការផ្សេងៗទៀតនៃ គ.ជ.ភ.ខ.។

**បច្ចុប្បន្ន គ.ជ.ភ.ខ. នៅសល់ទឹកប្រាក់ចំនួន ..................... <u>៥ ៩៦២ ៥៤០៛</u>** ។

ប្រាក់ចំណូលនិងប្រាក់ចំណាយខាងលើ ត្រូវបានការិយាល័យហិរញ្ញវត្ថុធ្វើសមតុល្យជូនសប្បុរសជន និង សមាជិក គ.ជ.ភ.ខ. ដើម្បីឱ្យមានតម្លាភាព។

# សេចក្ដីសម្រេចមូលដ្ឋានមួយចំនួន
# ចុះក្នុងព្រឹត្តិបត្រលេខមួយ និង មតិសាធារណជន

## ១. សេចក្ដីសម្រេចមូលដ្ឋានមួយចំនួនចុះក្នុងព្រឹត្តិបត្រលេខមួយ :

គួររំលឹកថា គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ដើម្បីឱ្យស្វែងរកឯកភាពជូនភាសាជាតិ ដែលបានទទួលផលប៉ះពាល់ដោយសារសង្គ្រាមស៊ីវិលនិងការផ្លាស់ប្ដូររបបគ្រប់គ្រងរដ្ឋជាបន្តបន្ទាប់។ គ.ជ.ភ.ខ.ប្រជុំប្រចាំសប្ដាហ៍រៀងរាល់ថ្ងៃពុធ ដើម្បីពិនិត្យនិងអនុម័តសំណើផ្សេងៗស្នើចេញពីគណៈកម្មការបច្ចេកទេសរបស់ខ្លួន :

១-នៅថ្ងៃពុធ ២០-០២-០៨ គ.ជ.ភ.ខ.បានអនុម័តជាឯកច្ឆន្ទ ដោយមានសម្បទានពីសមាជិកមួយចំនួន យកអក្ខរាវិរុទ្ធជាផ្លូវការតាមវចនានុក្រមសម្ដេច ជួន ណាត បោះពុម្ពឆ្នាំ១៩៦៧ (ភាគទី១) និង ១៩៦៨ (ភាគទី២) ។

២-នៅថ្ងៃពុធ ០៥-០៣-០៨ គ.ជ.ភ.ខ.បានអនុម័តយល់ព្រមបង្កើតឱ្យមានអង់តែនមួយ សម្រាប់ឱ្យមហាជនដែលគ្មានវចនានុក្រម សួរអំពីអក្ខរាវិរុទ្ធដែលគេមិនចេះសរសេរ។ លោក ជួរ គារី លេខាធិការនៃ គ.ជ.ភ.ខ. ត្រូវបានចាត់ឱ្យទទួលខុសត្រូវ ឆ្លើយឆ្លងជាមួយអ្នកសួរ។ មហាជនអាចទាក់ទងនឹងអ្នកទទួលខុសត្រូវនេះ តាមទូរស័ព្ទលេខ ០១២ ២៩២ ៤៧៣ ឬ តាម E-mail : nckl_secretariat@yahoo.com ។

៣-នៅថ្ងៃពុធ ២១-០៥-០៨ គ.ជ.ភ.ខ.បានពិគ្រោះពិភាក្សា លើធាតុ /*-កម្ម*/ លើបណ្ដុំធាតុ /*-ឧបនីយកម្ម*/ និង /*-នីយកម្ម*/ ដែលគេប្រើនៅចុងពាក្យ ដូចក្នុង *ផលិតកម្ម, ជាតូបនីយកម្ម, សុខដុមនីយកម្ម*...។ ដោយផ្អែកលើគណៈកម្មការវប្បធម៌ (គណៈកម្មការនៃការបង្កើតពាក្យ) សម័យសម្ដេច ជួន ណាត ផង និង លើមតិនៃសមាជិក

ខ្លួនខ្លះផង គ.ជ.ភ.ខ.បានសម្រេចថា ៖

៣.១- ធាតុ / *-កម្ម* / អាចប្រើដូចបច្ឆិមបទ សម្រាប់បង្កើតនាមសព្ទសម្គាល់អំពើ/សកម្មភាព/ការ ដូចក្នុង *កសិកម្ម* (សកម្មភាពនៃការដាំដុះ/នៃការភ្ជួររាស់), *ផលិតកម្ម* (ការផលិត) ... ;

៣.២- ឱ្យអាទិភាពតាមមតិភាគច្រើនទៅបណ្ដុំធាតុ / *-នីយកម្ម* / ដែលមិនវែងពេកប្រៀបនឹង / *-ឧបនីយកម្ម* / ក្នុងការប្រើប្រាស់សម្រាប់បង្កើតនាមសព្ទ ដូច *ខ្មែរនីយកម្ម* ជាដើម ដែលមានន័យថា "ធ្វើឱ្យមានលក្ខណៈជាខ្មែរ" ទោះបីបណ្ដុំធាតុទាំងពីរនេះត្រូវបានគេប្រើជំនួសគ្នាបាន ដូចក្នុង <u>*ខ្មែរនីយកម្ម*</u> ឬ <u>*ខ្មែរូបនីយកម្ម*</u> ក៏ដោយ ;

៣.៣-"*ភាវូបនីយកម្ម*" មិនមែនជាបណ្ដុំធាតុមួយដុលដែលមាននៅសម័យសម្ដេច ជួន ណាត ទេ ពីព្រោះ "***ភាវូប***" ជាលទ្ធផលនៃការតភ្ជាប់រវាងព្យាង្គ "***ភាព***" ខាងចុងនៃពាក្យដើមខ្លះ ដូចពាក្យ *ឯក**ភាព***, *សេរី**ភាព*** , ... ទៅនឹងព្យាង្គខាងដើមនៃបណ្ដុំធាតុ / *-**ឧប**នីយកម្ម* / ៖ ក្រោយពីមានការបូកបញ្ចូល *ឯក**ភាព*** ជាមួយ / *-**ឧប**នីយកម្ម* / គេបាន "*ឯក**ភាពុប**នីយកម្ម* " ហើយ ព្យាង្គ "***ភាព***" ក៏ក្លាយទៅជា "***ភាវ***" រីឯស្រៈ -ុ- ក៏ត្រូវសម្រួលទៅជាស្រៈ -ូ- វិញ ដូចក្នុង *ឯក**ភាវូប**នីយកម្ម* (ក៏ដូចជាក្នុង *សេរី**ភាវូប**នីយកម្ម*, *សន្តិ**ភាវូប**នីយកម្ម*, ... ផងដែរ)។

៤-នៅថ្ងៃពុធ ២៨-០៥-០៨ គ.ជ.ភ.ខ.បានដោះស្រាយបញ្ហាទាក់ទងនឹងការសរសេរជាអក្សរខ្មែរនូវសូរបរទេសមួយចំនួន ដែលយើងតែងប្រទះតាមរយៈពាក្យកម្ចី ដោយអនុម័តយកសំណើរបស់ឯកឧត្ដម បណ្ឌិត ច័ន្ទ សំណព្វ ដែលបានធ្វើការស្រាវជ្រាវ ដោយផ្អែកលើវចនានុក្រមសម្ដេច ជួន ណាត និង លើឯកសារឯទៀត។ សូរទាំងនោះមាន ៖

- [g]ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្គ"
- [f] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្វ"
- [□]ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ"ហ្ស"
- [□]ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ស្ហ"
- [s] / [z]ដែលយើងត្រូវប្រើព្យញ្ជនៈ "ស "។

ជ.ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ
អនុប្រធានអចិន្ត្រៃយ៍

**២. <u>មតិសាធារណជន</u> ៖**

សាធារណជនមួយចំនួនបានលើកឡើងថា ភាសាខ្មែរមានមូលភាព [អ] និង [អ៊] ។ បើយើងមានតែ "ហ្វ ", "ហ្ស", "ស្ហ" និង "ស " យើងមិនអាចកត់ត្រាសូរឱ្យបានសព្វគ្រប់ឡើយ, ឧ. **ហ្ស៊ី**ប្រាល់តា (**Gi**bralta), **ហ្វ៊ូ**ណា**ហ្វ៊ូ**ទី (**Fu**na**fu**ti), អា**ស៊ែ**បៃហ្សង់ (Aze**r**baïdjan) ដែលបង្ហាញឱ្យឃើញថា យើងត្រូវមាន ៖ "ហ្វ/ហ្វ៊", "ហ្ស/ហ្ស៊", "ស/ស៊" និង "ស្ហ/ស្ហ៊" ។

( ទំព័រទំនេរ មិនឱ្យចេញលេខទំព័រ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ
លេខាធិការដ្ឋានអចិន្ត្រៃយ៍ : វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា

Comité National de la Langue Khmère
Secrétariat permanent : Institut de la Langue Nationale de l'Académie Royale du Cambodge

ទូរស័ព្ទ : ០៩២ ៨៩ ២៣ ៤៣, ០១៦ ៩៤ ៧៤ ២១ , ទូរសារ : ០២៣ ៩៨ ៣៨ ៧១ , E-mail: nckl_secretariat@yahoo.com

លេខ : ០៦៣ /០៩.គជភខ/រ

ភ្នំពេញ, ថ្ងៃសុក្រ ទី១១ ខែធ្នូ ឆ្នាំ២០០៩

សូមគោរពជូន

លោកជំទាវ ខ្លូត ធីតា
ប្រធានរាជបណ្ឌិតសភាកម្ពុជា

**កម្មវត្ថុ :** សំណើសុំឱ្យ សាស្ត្រាចារ្យដឹកនាំនិក្ខេបបទនិងបេក្ខជនថ្នាក់បណ្ឌិតនៃរាជបណ្ឌិតសភាកម្ពុជា សរសេរពាក្យតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត**

ខ្ញុំមានកិត្តិយសស្នើមកលោកជំទាវ សូមលោកជំទាវមេត្តាពិនិត្យកាលានុវត្តភាពសម្រេចថា តើលោកជំទាវអាចសុំឱ្យ សាស្ត្រាចារ្យដឹកនាំនិក្ខេបបទនិងបេក្ខជនថ្នាក់បណ្ឌិតនៃរាជបណ្ឌិតសភាកម្ពុជា សរសេរពាក្យតាមអក្ខរាវិរុទ្ធនៃវចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានឬទេ។ បើលោកជំទាវយល់ថា លោកជំទាវអាចធ្វើបាន សូមលោកជំទាវមេត្តាចាត់ការតាមការគួរ ដោយសេចក្ដីអនុគ្រោះ ដើម្បីជាជំនួយដ៏សំខាន់មួយចំពោះឯកភាពក្នុងការសរសេរពាក្យដែលគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) បាននិងកំពុងស្វែងរកជូនភាសា។

ខ្ញុំសូមរំឭកលោកជំទាវថា គ.ជ.ភ.ខ.យើងបានសម្រេចឱ្យសរសេរពាក្យតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** កាលពីថ្ងៃពុធ ទី២០ ខែកុម្ភៈ ឆ្នាំ២០០៨។

ដោយអរគុណលោកជំទាវទុកជាមុន ខ្ញុំសូមលោកជំទាវមេត្តាទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ជ.ប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ
អនុប្រធានអចិន្ត្រៃយ៍

បណ្ឌិត ព្រុំ ម៉ល់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

27/8/2010
11
011/10

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**រាជបណ្ឌិត្យសភាកម្ពុជា**

**Royal Academy of Cambodia**
**Académie Royale du Cambodge**

លេខៈ ៣៧៧/១០ បេសក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០

# សេចក្ដីជូនដំណឹង

យោងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** (បណ្ឌិតសភាចារ្យ) នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្ដីពី ការឯកភាពក្នុងការប្រើប្រាស់ភាសា និងការប្រគល់ភារកិច្ចនេះជូនគណៈកម្មាធិការជាតិភាសាខ្មែរ ដែលបានថ្លែងកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ក្នុងពិធីបិទសន្និបាតការងារអប់រំ យុវជន និងកីឡា ឆ្នាំ២០០៩ និងទិសដៅឆ្នាំ២០១០ និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីអាណាព្យាបាលរាជបណ្ឌិត្យសភាកម្ពុជា ដែលបានណែនាំជាបន្តបន្ទាប់ ស្ដីពី ការឯកភាពក្នុងការប្រើប្រាស់ភាសានោះ

រាជបណ្ឌិត្យសភាកម្ពុជា សូមជូនដំណឹងដល់គ្រប់វិទ្យាស្ថាន អង្គភាព ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់ជ្រាបថា រាល់ឯកសារបោះពុម្ពផ្សាយទាំងអស់ដែលពាក់ព័ន្ធនឹងក្បួនខ្នាតអក្សរ ភាសា និងវេយ្យាករណ៍ខ្មែរ ដោយយកឈ្មោះរាជបណ្ឌិត្យសភាកម្ពុជា និងក្នុងក្របខណ្ឌរាជបណ្ឌិត្យសភាកម្ពុជា ត្រូវអនុវត្តតាមវចនានុក្រមខ្មែរដែលរៀបរៀងដោយសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ដែលបានបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ឆ្នាំ១៩៦៧ រួមទាំងអក្ខរាវិរុទ្ធដែលមានការឯកភាពពីគណៈកម្មាធិការជាតិភាសាខ្មែរ។

អាស្រ័យហេតុនេះ សូមថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់នៅរាជបណ្ឌិត្យសភាកម្ពុជាត្រូវអនុវត្តតាមសេចក្ដីជូនដំណឹងខាងលើនេះ ឱ្យមានប្រសិទ្ធភាព និងទទួលខុសត្រូវខ្ពស់។

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិត ខ្លូត ធីតា**

**<u>ចម្លងជូនៈ</u>**

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្ដមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី
" *ដើម្បីជូនជ្រាប* "
-គណៈកម្មាធិការជាតិភាសាខ្មែរ
" *ដើម្បីសហការអនុវត្ត* "
-ឯកសារ-កាលប្បវត្តិ

អាសយដ្ឋានៈ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Web Site: www.rac-academy.edu.kh, Email: arc_academy@yahoo.com, P.O Box 531, Phnom Penh, Cambodia.

# បទបង្ហាញរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ អនុប្រធានអចិន្ត្រៃយ៍[1] នៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ក្នុងជំនួបជាមួយតំណាងប្រព័ន្ធផ្សព្វផ្សាយ នៅថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០១០

(នៅសាលប្រជុំ គ.ជ.ភ.ខ.)

## បុព្វយោគ

ភាសាខ្មែរបានរីកចម្រើនខ្លាំងជាបន្តបន្ទាប់ ចាប់ពីពេលដែលវចនានុក្រមខ្មែរត្រូវបានបោះពុម្ពផ្សាយជាលើកដំបូងនៅឆ្នាំ១៩៣៨ បន្ទាប់ពីក្រុមជំនុំមួយ ដែលកើតនៅឆ្នាំ១៩១៥ បានខំតាក់តែងតៗគ្នាជាច្រើនជំនាន់ តាំងពីសម្ដេចព្រះសង្ឃរាជ **ជួន ណាត** នៅជាអាចារ្យសាលាបាលីនិងមានមុខងារជាស្មៀន រហូតដល់ព្រះអង្គបានឡើងជាព្រះសង្ឃរាជនិងមានមុខងារជាព្រះប្រធាន។ នៅឆ្នាំ១៩៣៤ ក្រុមជំនុំមួយទៀតត្រូវបានបង្កើតឡើង ដើម្បីបង្កើតពាក្យចាំបាច់សម្រាប់ភាសាខ្មែរដែលកំពុងត្រៀមខ្លួនដើរតួជាភាសាផ្លូវការ។ ក្រុមជំនុំនោះ គេស្គាល់ថាជា "គណៈកម្មការវប្បធម៌" ហើយ ពាក្យដែលកើតចេញពីគណៈ-កម្មការនោះត្រូវគេហៅថា "ពាក្យវប្បធម៌" ដូចជាពាក្យ រដ្ឋាភិបាល ធនាគារ ជាដើម។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទី៣ក្នុងការរីកចម្រើននៃភាសាខ្មែរ គឺការបង្កើតគណៈកម្មាធិការជាតិខេមរយានកម្ម នៅឆ្នាំ១៩៦៧។ នៅដំណាក់កាលទី១ (១៩៦៧-១៩៦៩) គណៈកម្មាធិការនេះ ត្រូវយកបច្ចេកសព្ទទៅសុំការឯកភាពពីសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជាមុនសិនមុននឹងយកទៅប្រើប្រាស់ក្នុងការបង្រៀន។ នៅពេលនោះ អក្ខរាវិរុទ្ធនិងឃ្លាឃ្លោងមិនទាន់មានការប្រែប្រួលដូចនៅដំណាក់-កាលទី២នៅឡើយ[2]។ នៅដំណាក់កាលទី២ (ក្រោយពីសម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានសោយទិវង្គតដល់ការដួលរលំនៃរបបសាធារណរដ្ឋ) ព្យាង្គរាយដែលគ្មានក្នុងវចនានុក្រម ត្រូវបានគេប្រើជំនួសព្យាង្គតម្រួតជាទូទៅ ហើយ អក្ខរាវិរុទ្ធនិងឃ្លាឃ្លោងចាប់មានការប្រែប្រួលគួរឱ្យកត់សម្គាល់ (សូមអានសទ្ទានុក្រមលេខ១ និង លេខ២ នៃខេមរយានកម្ម)។

## ១- មូលហេតុនៃការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.)

ដោយមានសង្គ្រាមស៊ីវិល និង ដោយប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយរបបខ្មែរក្រហម គណៈកម្មាធិការជាតិខេមរយានកម្មត្រូវបានរលត់រលាយទៅ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ សាលារៀនត្រូវបានបើកឡើងវិញ ប៉ុន្តែក្រសួងអប់រំបានបន្តគំនិតនៃដំណាក់កាលទី២នៃខេមរយានកម្មដែលឈប់យកវចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជាមូលដ្ឋាន ហើយ កង្វះឯកភាពក្នុងភាសាខ្មែរកាន់តែមានច្រើនឡើង។ សព្វថ្ងៃនេះ ខ្មែរណាក៏ដឹងដែរថា ភាសាខ្មែរយើងខ្វះឯកភាព ទាំងក្នុងការសរសេរពាក្យ ទាំងក្នុងការអានពាក្យ ទាំងក្នុងការបង្កើតនិងការប្រើពាក្យ និង ទាំងក្នុងការខ្ចីពាក្យពីភាសាបរទេស។

---

[1] : អត្ថបទនេះបានចែកជូនតំណាងប្រព័ន្ធផ្សព្វផ្សាយដែលបានអញ្ជើញចូលរួមក្នុងជំនួបមួយ រៀបចំដោយ គ.ជ.ភ.ខ. កាលពីថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០១០ នៅសាលប្រជុំ គ.ជ.ភ.ខ.។ អត្ថបទនេះត្រូវបានបង្គ្រប់បន្ថែមនិងកែសម្រួលខ្លឹមសារមួយចំនួន ដើម្បីឱ្យកាន់តែប្រសើរនិងសព្វគ្រប់ មុននឹងចុះក្នុងព្រឹត្តិបត្រលេខ៣, ឧ. ចំណងជើងដើម "សេចក្ដីថ្លែងការណ៍" ត្រូវបានកែសម្រួលជា "បទបង្ហាញ" ជាដើម។

[2] : សម្ដេចព្រះសង្ឃរាជ ជួន ណាត បានសោយទិវង្គតនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៦៩។ ក្រោយពីសាធារណរដ្ឋត្រូវបានបង្កើតឡើង គណៈកម្មាធិការជាតិខេមរយានកម្មឈប់ដើរតួសំខាន់ ពីព្រោះលោក ហង្ស ធុនហាក់ ដែលជាប្រធាន និង សមាជិកមួយចំនួន បានចូលធ្វើជារដ្ឋមន្ត្រីឬចូលប្រឡូកក្នុងនយោបាយ។ មុខងារនៃការអនុម័តពាក្យត្រូវធ្លាក់ទៅគណៈកម្មការមួយ ហៅថា "គណៈកម្មការអនុម័តពាក្យ" ដែលមានលោក ឡុច ផ្លែង សិស្សរបស់លោក កេង វ៉ាន់សាក់ ជាប្រធាន។ បច្ចេកសព្ទនៅតែត្រូវការការឯកភាពពីសម្ដេចព្រះសង្ឃរាជ ជាមុនសិនមុននឹងយកទៅប្រើប្រាស់ក្នុងការបង្រៀន ប៉ុន្តែ ព្រះសង្ឃរាជមិនមែនសម្ដេច **ជួន ណាត** ទេ ហើយ របប-នយោបាយ ក៏មិនមែនជាព្រះរាជាណាចក្រដែរ គឺជារបបសាធារណរដ្ឋ ដែលផ្ដល់ឱកាសឱ្យអតីតនិស្សិតរបស់លោក កេង វ៉ាន់សាក់ ជាច្រើន ទទួលតំណែងសំខាន់ៗ ក្នុងកិច្ចការខេមរយានកម្ម។

ដោយមើលឃើញកង្វះឯកភាពបែបនេះ វិទ្យាស្ថានភាសាជាតិបានរៀបចំសន្និសីទជាតិជាច្រើនលើក នៅឆ្នាំ២០០០ ឆ្នាំ២០០៥ ឆ្នាំ២០០៦។ល។ ក្នុងសន្និសីទមួយលើកៗ សមាជិកបានលើកជាអនុសាសន៍សំខាន់ៗមួយចំនួនធំ ហើយ ក្នុងនោះតែងតែមានការសុំឱ្យបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ។ នៅក្នុងពិធីបិទសន្និសីទនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍ថា "ខ្ញុំសូមគាំទ្រដល់ការបង្កើតគណៈកម្មាធិការជាតិផ្នែកភាសាខ្មែរ ដើម្បីឈានទៅរកឯកភាពនិងអភិវឌ្ឍន៍ភាសាខ្មែរឱ្យបានគ្រប់គ្រាន់"។

គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ក៏បានបង្កើតឡើង តាមអនុក្រឹត្យលេខ១៨ អនក្របក ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០០៧។ គ.ជ.ភ.ខ.នេះមានភារកិច្ចរកឯកភាពជូនភាសាខ្មែរ ក្នុងការសរសេរពាក្យ ក្នុងការអានពាក្យ ក្នុងការបង្កើតនិងការប្រើពាក្យ និង ក្នុងការខ្ចីពាក្យពីភាសាបរទេស។

## ២- ដំណាក់កាលនិងសេចក្តីសម្រេចសំខាន់ៗរបស់គ.ជ.ភ.ខ.

### ២.១. សម័យប្រជុំឱឡារិកលើកដំបូងនៃ គ.ជ.ភ.ខ.

ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធាន គ.ជ.ភ.ខ. បានកោះប្រជុំលើកទី១ជាឱឡារិក នៅថ្ងៃអង្គារ ទី១៨ ខែកញ្ញា ឆ្នាំ២០០៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបើកផ្លូវឱ្យ គ.ជ.ភ.ខ. ដំណើរការរៀងរាល់ថ្ងៃពុធរហូតមកដល់បច្ចុប្បន្ន។ នៅពេលនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានប្រគល់ភារកិច្ចជូនអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ភ.ខ. ឱ្យបំពេញការងារជូន គ.ជ.ភ.ខ. ជំនួសឯកឧត្តមរហូតមក។

### ២.២. ការអនុម័តយកវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជាមូលដ្ឋាន

កាលពីថ្ងៃពុធ ទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ គ.ជ.ភ.ខ.បានអនុម័តជាឯកច្ឆន្ទយកវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាមូលដ្ឋាន ប៉ុន្តែ ការផ្សព្វផ្សាយតាមរយៈព្រឹត្តិបត្រមិនបានជ្រួតជ្រាបដល់គ្រប់ស្រទាប់នៃសាធារណជននៅឡើយ។ ចំពោះបច្ចេកសព្ទវិញ គ.ជ.ភ.ខ.ក៏បានផ្សព្វផ្សាយតែតាមរយៈព្រឹត្តិបត្រដូចគ្នាដែរ។

គួរបញ្ជាក់ជូនសាធារណជនថា ទោះការអនុម័តយកវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជជាមូលដ្ឋានក្តី ទោះការអនុម័តលើបច្ចេកសព្ទនៃមុខជំនាញនានាក្តី គឺសុទ្ធតែយកការស្វែងរកឯកភាពជូនភាសាខ្មែរជាត្រីវិស័យ, ឧទាហរណ៍ ៖ ក្នុងចំណោមពាក្យជាច្រើនសម្រាប់បញ្ញត្តិតែមួយ ដូច *កម្មរង កម្មបទ បទកម្ម* និង *កម្ម* ជាដើម គ.ជ.ភ.ខ.បានអនុម័តរក្សាទុកតែពាក្យ *កម្ម* មួយទេ និង ក្នុងចំណោមអក្ខរាវិរុទ្ធពីរបីបែបដែលគេធ្លាប់ប្រើផ្សេងៗគ្នា ដូច *សំឡេង សំលេង* និង *សម្លេង* ជាដើម គ.ជ.ភ.ខ.ត្រូវរក្សាទុកតែអក្ខរាវិរុទ្ធ *សំឡេង* ទេដែលត្រឹមត្រូវតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត**។ ឧទាហរណ៍ទាំងពីរបែបនេះ ឆ្លុះបញ្ចាំងកង្វល់របស់ គ.ជ.ភ.ខ. ក្នុងការស្វែងរកឯកភាពជូនភាសាខ្មែរ។

### ២.៣. ការផ្សព្វផ្សាយតាមអ៊ីនធឺណិត

ដោយការផ្សព្វផ្សាយសេចក្តីសម្រេចរបស់ខ្លួនតាមរយៈព្រឹត្តិបត្របានជ្រួតជ្រាបត្រឹមតែរង្វង់តូច គ.ជ.ភ.ខ.បានស្នើសុំផ្សព្វផ្សាយតាមអ៊ីនធឺណិតផងដែរ គឺតាមអ៊ីនធឺណិត របស់ទីស្តីការគណៈរដ្ឋមន្ត្រី របស់រាជបណ្ឌិត្យសភាកម្ពុជា និង របស់វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនិងការទូត។ គ.ជ.ភ.ខ.បានយល់ច្បាស់ថា អ៊ីនធឺណិតអាចផ្សព្វផ្សាយបានឆ្ងាយ ប៉ុន្តែ មធ្យោបាយនេះផ្សព្វផ្សាយដល់តែសាធារណជនធូរធារធនធានមួយក្រុម ៖ គ.ជ.ភ.ខ.ត្រូវរកមធ្យោបាយផ្សេងៗទៀត។

### ២.៩. ការអំពាវនាវរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក

ឯកឧត្តម **ឃួន វិចិត្រ** តំណាងក្រសួងព័ត៌មាន ដែលតែងតែយកចិត្តទុកដាក់នឹងកិច្ចការ គ.ជ.ភ.ខ. បានផ្តល់យោបល់ប្រកបដោយសុភនិច្ឆ័យថា មានតែប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកទេ ទើបអាចបញ្ជូនសេចក្តីសម្រេចរបស់ គ.ជ.ភ.ខ. ឱ្យដល់គ្រប់ស្រទាប់នៃសាធារណជន។ អាស្រ័យហេតុនេះ គ.ជ.ភ.ខ.បានអញ្ជើញតំណាងប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ មកចូលរួមក្នុងជំនួបដ៏ជាទីសង្ឃឹមនាថ្ងៃនេះ។

គ.ជ.ភ.ខ.សូមគោរពស្វាគមន៍ដល់អស់លោកតំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានវត្តមាននៅពេលនេះ ដោយសេចក្តីសោមនស្សរីករាយជាអនេកប្បការ។ សូមលោកមេត្តាជំរាបទៅថ្នាក់ដឹកនាំរបស់លោក សូមឱ្យមានការជួយផ្សព្វផ្សាយឯកសារដែល គ.ជ.ភ.ខ.ទើបបានជូនទៅលោកអំបាញ់មិញនេះ ឱ្យបានទូលំទូលាយឱ្យយើងខ្ញុំផង : យើងខ្ញុំសូមអរគុណទុកជាមុន។

## ៣- គម្រោងសម្រាប់អនាគត

ការស្វែងរកឯកភាពជូនភាសាខ្មែរជាភារកិច្ចដ៏ធ្ងន់ធ្ងរនឹងដ៏លំបាក ពីព្រោះកង្វះឯកភាពបានជ្រួតជ្រាបដល់គ្រប់ស្រទាប់នៃសង្គមខ្មែរ។ កង្វះឯកភាពមិនទាក់ទងតែនឹងអក្ខរាវិរុទ្ធទេ ការប្រើពាក្យមិនដូចគ្នាសម្រាប់បញ្ញត្តិតែមួយ ឬ ការខ្ចីពាក្យមិនដូចគ្នាពីភាសាបរទេស,... ក៏ជាបញ្ហាធំធេងណាស់ដែរ។ ការអនុម័តពាក្យតាមជំនាញ ដើម្បីឱ្យគេប្រើពាក្យឱ្យត្រូវគ្នា ជាភារកិច្ចដែលត្រូវប្រើពេលយូរ រហូតដល់ចេញជាសទ្ទានុក្រមតាមជំនាញ។

ដើម្បីឱ្យការស្វែងរកឯកភាពជូនភាសាខ្មែរកាន់តែមានប្រសិទ្ធិភាព បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានស្នើសេចក្តីព្រាងច្បាប់មួយ កែប្រែគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ឱ្យទៅជាក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) ដោយបានស្នើសុំសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីលោកធ្វើជាប្រធានកិត្តិយស ហើយ ឥស្សរជនជាន់ខ្ពស់មួយចំនួន មានឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាដើម ក៏ត្រូវបានសុំឱ្យធ្វើជាទីប្រឹក្សាផងដែរ។

## សរុបនិទ្ទេសនិងសេចក្តីសន្និដ្ឋាន

ទម្លាប់ជាធម្មជាតិទី២របស់មនុស្ស ដូច្នេះ អ្នកដែលធ្លាប់សរសេរឬប្រើពាក្យបែបនេះ តែងតែមានអារម្មណ៍មិនល្អ កាលណាគេឃើញអ្នកឯទៀតសរសេរឬប្រើពាក្យបែបនោះទៅវិញ។ ដោយអ្នកខ្លះសរសេរឬប្រើពាក្យបែបនេះ អ្នកខ្លះសរសេរឬប្រើពាក្យបែបនោះ យ៉ាងដូច្នេះហើយ បានជាភាសាខ្មែរយើងខ្វះឯកភាព។ ដើម្បីឱ្យភាសានេះមានឯកភាពឡើងវិញ (ដូចអរិយភាសាក្នុងលោក) គប្បីខ្មែរម្នាក់ៗខំអត់សង្កត់ចិត្ត កែទម្លាប់ណាដែលមិនស្របនឹងសេចក្តីសម្រេចរបស់ គ.ជ.ភ.ខ.។ សូមញ្ជាក់ជូនថា គ.ជ.ភ.ខ.មានតំណាងពីគ្រប់មជ្ឈដ្ឋានសំខាន់ៗ ហើយ ធ្វើការដោយផ្អែកលើបញ្ញាញាណ និង ប្រកាន់យកស្មារតីសម្រុះសម្រួលជាតិ។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់តំណាងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងជំនួបថ្ងៃនេះ និង សូមជូនពរដល់លោក សូមលោកប្រកបនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ
**លេខាធិការដ្ឋានអចិន្ត្រៃយ៍ : វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា**

Comité National de la Langue Khmère
Secrétariat permanent : Institut de la Langue Nationale de l'Académie Royale du Cambodge

ទូរស័ព្ទ : ០៩២ ៨៩ ២៣ ៤៣, ០១៦ ៩៤ ៧៤ ២១ , ទូរសារ : ០២៣ ៩៨ ៣៨ ៧១ , E-mail: nckl_secretariat@yahoo.com


---

លេខ : ០៦៣ /០៩.គជភខ/រ

ភ្នំពេញ, ថ្ងៃសុក្រ ទី១១ ខែធ្នូ ឆ្នាំ២០០៩

<u>សូមគោរពជូន</u>

លោកជំទាវ ខ្លូត ធីតា
ប្រធានរាជបណ្ឌិតសភាកម្ពុជា

**កម្មវត្ថុ :** សំណើសុំឱ្យ សាស្ត្រាចារ្យដឹកនាំនិក្ខេបបទនិងបេក្ខជនថ្នាក់បណ្ឌិតនៃរាជបណ្ឌិតសភាកម្ពុជា សរសេរពាក្យតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត**

ខ្ញុំមានកិត្តិយសស្នើមកលោកជំទាវ សូមលោកជំទាវមេត្តាពិនិត្យកាលានុវត្តភាពសម្រេចថា តើលោកជំទាវអាចសុំឱ្យ សាស្ត្រាចារ្យដឹកនាំនិក្ខេបបទនិងបេក្ខជនថ្នាក់បណ្ឌិតនៃរាជបណ្ឌិតសភាកម្ពុជា សរសេរពាក្យតាមអក្ខរាវិរុទ្ធនៃវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** បានឬទេ។ បើលោកជំទាវយល់ថា លោកជំទាវអាចធ្វើបាន សូមលោកជំទាវមេត្តាចាត់ការតាមការគួរ ដោយសេចក្តីអនុគ្រោះ ដើម្បីជាជំនួយដ៏សំខាន់មួយចំពោះឯកភាពក្នុងការសរសេរពាក្យដែលគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) បាននិងកំពុងស្វែងរកជូនភាសា។

ខ្ញុំសូមរំឭកលោកជំទាវថា គ.ជ.ភ.ខ.យើងបានសម្រេចឱ្យសរសេរពាក្យតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** កាលពីថ្ងៃពុធ ទី២០ ខែកុម្ភៈ ឆ្នាំ២០០៨។

ដោយអរគុណលោកជំទាវទុកជាមុន ខ្ញុំសូមលោកជំទាវមេត្តាទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ជ.ប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ
អនុប្រធានអចិន្ត្រៃយ៍

**បណ្ឌិត ព្រុំ ម៉ល់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

27/8/2010
11
011/10

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**រាជបណ្ឌិត្យសភាកម្ពុជា**

**Royal Academy of Cambodia**
**Académie Royale du Cambodge**

លេខៈ ៣៧៧/១០ របសក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០

# សេចក្តីជូនដំណឹង

យោងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** (បណ្ឌិតសភាចារ្យ) នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី ការឯកភាពក្នុងការប្រើប្រាស់ភាសា និងការប្រគល់ភារកិច្ចនេះជូនគណៈកម្មាធិការជាតិភាសាខ្មែរ ដែលបានថ្លែងកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ក្នុងពិធីបិទសន្និបាតការងារអប់រំ យុវជន និងកីឡា ឆ្នាំ២០០៩ និងទិសដៅឆ្នាំ២០១០ និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីអាណាព្យាបាលរាជបណ្ឌិត្យសភាកម្ពុជា ដែលបានណែនាំជាបន្តបន្ទាប់ ស្តីពី ការឯកភាពក្នុងការប្រើប្រាស់ភាសានោះ

រាជបណ្ឌិត្យសភាកម្ពុជា សូមជូនដំណឹងដល់គ្រប់វិទ្យាស្ថាន អង្គភាព ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់ជ្រាបថា រាល់ឯកសារបោះពុម្ពផ្សាយទាំងអស់ដែលពាក់ព័ន្ធនឹងក្បួនខ្នាតអក្សរ ភាសា និងវេយ្យាករណ៍ខ្មែរ ដោយយកឈ្មោះរាជបណ្ឌិត្យសភាកម្ពុជា និងក្នុងក្របខណ្ឌរាជបណ្ឌិត្យសភាកម្ពុជា ត្រូវអនុវត្តតាមវចនានុក្រមខ្មែរដែលរៀបរៀងដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត** ដែលបានបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ឆ្នាំ១៩៦៧ រួមទាំងអក្ខរាវិរុទ្ធដែលមានការឯកភាពពីគណៈកម្មាធិការជាតិភាសាខ្មែរ។

អាស្រ័យហេតុនេះ សូមថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់នៅរាជបណ្ឌិត្យសភាកម្ពុជាត្រូវអនុវត្តតាមសេចក្តីជូនដំណឹងខាងលើនេះ ឱ្យមានប្រសិទ្ធភាព និងទទួលខុសត្រូវខ្ពស់។

**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិត ខ្លូត ធីតា**

**ចម្លងជូន:**
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី
" *ដើម្បីជូនជ្រាប* "
-គណៈកម្មាធិការជាតិភាសាខ្មែរ
" *ដើម្បីសហការអនុវត្ត* "
-ឯកសារ-កាលប្បវត្តិ

អាសយដ្ឋានៈ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Web Site: www.rac-academy.edu.kh, Email: arc_academy@yahoo.com, P.O Box 531, Phnom Penh, Cambodia.

## បទបង្ហាញរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ អនុប្រធានអចិន្ត្រៃយ៍[1]
## នៃគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.)
## ក្នុងជំនួបជាមួយតំណាងប្រព័ន្ធផ្សព្វផ្សាយ
## នៅថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០១០

(នៅសាលប្រជុំ គ.ជ.ភ.ខ.)

### បុព្វយោគ

ភាសាខ្មែរបានរីកចម្រើនខ្លាំងជាបន្តបន្ទាប់ ចាប់ពីពេលដែលវចនានុក្រមខ្មែរត្រូវបានបោះពុម្ពផ្សាយជាលើកដំបូងនៅឆ្នាំ១៩៣៨ បន្ទាប់ពីក្រុមជំនុំមួយ ដែលកើតនៅឆ្នាំ១៩១៥ បានខំតាក់តែងគ្នាជាច្រើនជំនាន់ តាំងពីសម្តេចព្រះសង្ឃរាជ **ជួន ណាត** នៅជាអាចារ្យសាលាបាលីនិងមានមុខងារជាស្មៀន រហូតដល់ព្រះអង្គបានឡើងជាព្រះសង្ឃរាជនិងមានមុខងារជាព្រះប្រធាន។ នៅឆ្នាំ១៩៣៤ ក្រុមជំនុំមួយទៀតត្រូវបានបង្កើតឡើង ដើម្បីបង្កើតពាក្យចាំបាច់សម្រាប់ភាសាខ្មែរដែលកំពុងត្រៀមខ្លួនដើរតួជាភាសាផ្លូវការ។ ក្រុមជំនុំនោះ គេស្គាល់ថាជា "គណៈកម្មការវប្បធម៌" ហើយ ពាក្យដែលកើតចេញពីគណៈកម្មការនោះត្រូវគេហៅថា "ពាក្យវប្បធម៌" ដូចជាពាក្យ រដ្ឋាភិបាល ធនាគារ ជាដើម។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទី៣ក្នុងការរីកចម្រើននៃភាសាខ្មែរ គឺការបង្កើតគណៈកម្មាធិការជាតិខេមរយានកម្ម នៅឆ្នាំ១៩៦៧។ នៅដំណាក់កាលទី១ (១៩៦៧-១៩៦៩) គណៈកម្មាធិការនេះ ត្រូវយកបច្ចេកសព្ទទៅសុំការឯកភាពពីសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាមុនសិនមុននឹងយកទៅប្រើប្រាស់ក្នុងការបង្រៀន។ នៅពេលនោះ អក្ខរាវិរុទ្ធនិងឃ្លាឃ្លោងមិនទាន់មានការប្រែប្រួលដូចនៅដំណាក់កាលទី២នៅឡើយ[2]។ នៅដំណាក់កាលទី២ (ក្រោយពីសម្តេចព្រះសង្ឃរាជ **ជួន ណាត** បានសោយទិវង្គតដល់ការដួលរលំនៃរបបសាធារណរដ្ឋ) ព្យាង្គរាយដែលគ្មានក្នុងវចនានុក្រម ត្រូវបានគេប្រើជំនួសព្យាង្គតម្រួតជាទូទៅ ហើយ អក្ខរាវិរុទ្ធនិងឃ្លាឃ្លោងចាប់មានការប្រែប្រួលគួរឱ្យកត់សម្គាល់ (សូមអានសទ្ទានុក្រមលេខ១ និង លេខ២ នៃខេមរយានកម្ម)។

### ១- មូលហេតុនៃការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.)

ដោយមានសង្គ្រាមស៊ីវិល និង ដោយប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយរបបខ្មែរក្រហម គណៈកម្មាធិការជាតិខេមរយានកម្មត្រូវបានរលត់រលាយទៅ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ សាលារៀនត្រូវបានបើកឡើងវិញ ប៉ុន្តែក្រសួងអប់រំបានបន្តគំនិតនៃដំណាក់កាលទី២នៃខេមរយានកម្មដែលឈប់យកវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាមូលដ្ឋាន ហើយ កង្វះឯកភាពក្នុងភាសាខ្មែរកាន់តែមានច្រើនឡើង។ សព្វថ្ងៃនេះ ខ្មែរណាក៏ដឹងដែរថា ភាសាខ្មែរយើងខ្វះឯកភាព ទាំងក្នុងការសរសេរពាក្យ ទាំងក្នុងការអានពាក្យ ទាំងក្នុងការបង្កើតនិងការប្រើពាក្យ និង ទាំងក្នុងការខ្ចីពាក្យពីភាសាបរទេស។

---

[1] : អត្ថបទនេះបានចែកជូនតំណាងប្រព័ន្ធផ្សព្វផ្សាយដែលបានអញ្ជើញចូលរួមក្នុងជំនួបមួយ រៀបចំដោយ គ.ជ.ភ.ខ. កាលពីថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០១០ នៅសាលប្រជុំ គ.ជ.ភ.ខ.។ អត្ថបទនេះត្រូវបានបង្រួបបន្ថែមនិងកែសម្រួលខ្លឹមសារមួយចំនួន ដើម្បីឱ្យកាន់តែប្រសើរនិងសព្វគ្រប់ មុននឹងចុះក្នុងព្រឹត្តិបត្រលេខ៣, ឧ. ចំណងជើងដើម "សេចក្តីថ្លែងការណ៍" ត្រូវបានកែសម្រួលជា "បទបង្ហាញ" ជាដើម។

[2] : សម្តេចព្រះសង្ឃរាជ ជួន ណាត បានសោយទិវង្គតនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៦៩។ ក្រោយពីសាធារណរដ្ឋត្រូវបានបង្កើតឡើង គណៈកម្មាធិការជាតិខេមរយានកម្មឈប់ដើរតួសំខាន់ ពីព្រោះលោក ហង្ស ធុនហាក់ ដែលជាប្រធាន និង សមាជិកមួយចំនួន បានចូលធ្វើជារដ្ឋមន្ត្រីឬចូលប្រឡូកក្នុងនយោបាយ។ មុខងារនៃការអនុម័តពាក្យត្រូវធ្លាក់ទៅគណៈកម្មការមួយ ហៅថា "គណៈកម្មការអនុម័តពាក្យ" ដែលមានលោក ឡុច ផ្លែង សិស្សរបស់លោក កេង វ៉ាន់សាក់ ជាប្រធាន។ បច្ចេកសព្ទនៅតែត្រូវការការឯកភាពពីសម្តេចព្រះសង្ឃរាជ ជាមុនសិនមុននឹងយកទៅប្រើប្រាស់ក្នុងការបង្រៀន ប៉ុន្តែ ព្រះសង្ឃរាជមិនមែនសម្តេច **ជួន ណាត** ទេ ហើយ របបនយោបាយ ក៏មិនមែនជាព្រះរាជាណាចក្រដែរ គឺជារបបសាធារណរដ្ឋ ដែលផ្តល់ឱកាសឱ្យអតីតនិស្សិតរបស់លោក កេង វ៉ាន់សាក់ ជាច្រើន ទទួលតំណែងសំខាន់ៗ ក្នុងកិច្ចការខេមរយានកម្ម។

ដោយមើលឃើញកង្វះឯកភាពបែបនេះ វិទ្យាស្ថានភាសាជាតិបានរៀបចំសន្និសីទជាតិជាច្រើនលើក នៅឆ្នាំ២០០០ ឆ្នាំ២០០៥ ឆ្នាំ២០០៦។ល។ ក្នុងសន្និសីទមួយលើកៗ សមាជិកបានលើកជាអនុសាសន៍សំខាន់ៗមួយចំនួនធំ ហើយ ក្នុងនោះតែងតែមានការសុំឱ្យបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ។ នៅក្នុងពិធីបិទសន្និសីទនាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍ថា "ខ្ញុំសូមគាំទ្រដល់ការបង្កើតគណៈកម្មាធិការជាតិផ្នែកភាសាខ្មែរ ដើម្បីឈានទៅរកឯកភាពនិងអភិវឌ្ឍន៍ភាសាខ្មែរឱ្យបានគ្រប់គ្រាន់"។

គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ក៏បានបង្កើតឡើង តាមអនុក្រឹត្យលេខ១៨ អនក្របក ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០០៧។ គ.ជ.ភ.ខ.នេះមានភារកិច្ចរកឯកភាពជូនភាសាខ្មែរ ក្នុងការសរសេរពាក្យ ក្នុងការអានពាក្យ ក្នុងការបង្កើតនិងការប្រើពាក្យ និង ក្នុងការខ្ចីពាក្យពីភាសាបរទេស។

## ២- __ដំណាក់កាលនិងសេចក្តីសម្រេចសំខាន់ៗរបស់គ.ជ.ភ.ខ.__

### ២.១. សម័យប្រជុំឱឡារិកលើកដំបូងនៃ គ.ជ.ភ.ខ.

ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធាន គ.ជ.ភ.ខ. បានកោះប្រជុំលើកទី១ជាឱឡារិក នៅថ្ងៃអង្គារ ទី១៨ ខែកញ្ញា ឆ្នាំ២០០៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបើកផ្លូវឱ្យ គ.ជ.ភ.ខ. ដំណើរការរៀងរាល់ថ្ងៃពុធរហូតមកដល់បច្ចុប្បន្ន។ នៅពេលនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានប្រគល់ភារកិច្ចជូនអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ភ.ខ. ឱ្យបំពេញការងារជូន គ.ជ.ភ.ខ. ជំនួសឯកឧត្តមរហូតមក។

### ២.២. ការអនុម័តយកវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជាមូលដ្ឋាន

កាលពីថ្ងៃពុធ ទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ គ.ជ.ភ.ខ.បានអនុម័តជាឯកច្ឆន្ទយកវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាមូលដ្ឋាន ប៉ុន្តែ ការផ្សព្វផ្សាយតាមរយៈព្រឹត្តិបត្រមិនបានជ្រួតជ្រាបដល់គ្រប់ស្រទាប់នៃសាធារណជននៅឡើយ។ ចំពោះបច្ចេកសព្ទវិញ គ.ជ.ភ.ខ.ក៏បានផ្សព្វផ្សាយតែតាមរយៈព្រឹត្តិបត្រដូចគ្នាដែរ។

គួរបញ្ជាក់ជូនសាធារណជនថា ទោះការអនុម័តយកវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជជាមូលដ្ឋានក្តី ទោះការអនុ-ម័តលើបច្ចេកសព្ទនៃមុខជំនាញនានាក្តី គឺសុទ្ធតែយកការស្វែងរកឯកភាពជូនភាសាខ្មែរជាត្រីវិស័យ, ឧទាហរណ៍ : ក្នុងចំណោមពាក្យជាច្រើនសម្រាប់បញ្ញត្តិតែមួយ ដូច *កម្មវង កម្មបទ បទកម្ម* និង *កម្ម* ជាដើម គ.ជ.ភ.ខ.បានអនុម័តរក្សាទុកតែពាក្យ *កម្ម* មួយទេ និង ក្នុងចំណោមអក្ខរាវិរុទ្ធពីរបីបែបដែលគេធ្លាប់ប្រើផ្សេងៗគ្នា ដូច *សំឡេង សំលេង* និង *សម្លេង* ជាដើម គ.ជ.ភ.ខ.ត្រូវរក្សាទុកតែអក្ខរាវិរុទ្ធ *សំឡេង* ទេ ដែលត្រឹមត្រូវតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត**។ ឧទាហរណ៍ទាំងពីរបែបនេះ ឆ្លុះបញ្ចាំងកង្វល់របស់ គ.ជ.ភ.ខ. ក្នុងការស្វែងរកឯកភាពជូនភាសាខ្មែរ។

### ២.៣. ការផ្សព្វផ្សាយតាមអ៊ីនធឺណិត

ដោយការផ្សព្វផ្សាយសេចក្តីសម្រេចរបស់ខ្លួនតាមរយៈព្រឹត្តិបត្របានជ្រួតជ្រាបត្រឹមតែរង្វង់តូច គ.ជ.ភ.ខ.បានស្នើសុំផ្សព្វផ្សាយតាមអ៊ីនធឺណិតផងដែរ គឺតាមអ៊ីនធឺណិត របស់ទីស្តីការគណៈរដ្ឋមន្ត្រី របស់រាជបណ្ឌិត្យសភាកម្ពុជា និង របស់វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនិងការទូត។ គ.ជ.ភ.ខ.បានយល់ច្បាស់ថា អ៊ីនធឺណិតអាចផ្សព្វផ្សាយបានឆ្ងាយ ប៉ុន្តែ មធ្យោ-បាយនេះផ្សព្វផ្សាយដល់តែសាធារណជនធូរធារធនធានមួយក្រុម : គ.ជ.ភ.ខ.ត្រូវរកមធ្យោបាយផ្សេងៗទៀត។

## ២.៤. ការអំពាវនាវចំពោះប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក

ឯកឧត្តម **ឃួន វិចិត្រ** តំណាងក្រសួងព័ត៌មាន ដែលតែងតែយកចិត្តទុកដាក់នឹងកិច្ចការ គ.ជ.ភ.ខ. បានផ្តល់យោបល់ប្រកបដោយសុភនិច្ឆ័យថា មានតែប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកទេ ទើបអាចបញ្ជូនសេចក្តីសម្រេចរបស់ គ.ជ.ភ.ខ. ឱ្យដល់គ្រប់ស្រទាប់នៃសាធារណជន។ អាស្រ័យហេតុនេះ គ.ជ.ភ.ខ.បានអញ្ជើញតំណាងប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ មកចូលរួមក្នុងជំនួបដ៏ជាទីសង្ឃឹមនាថ្ងៃនេះ។

គ.ជ.ភ.ខ.សូមគោរពស្វាគមន៍ដល់អស់លោកតំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានវត្តមាននៅពេលនេះ ដោយសេចក្តីសោមនស្សរីករាយជាអនេកប្បការ។ សូមលោកមេត្តាជំរាបទៅថ្នាក់ដឹកនាំរបស់លោក សូមឱ្យមានការជួយផ្សព្វផ្សាយឯកសារដែល គ.ជ.ភ.ខ.ទើបបានជូនទៅលោកអំបាញ់មិញនេះ ឱ្យបានទូលំទូលាយឱ្យយើងខ្ញុំផង : យើងខ្ញុំសូមអរគុណទុកជាមុន។

## ៣- <u>គម្រោងសម្រាប់អនាគត</u>

ការស្វែងរកឯកភាពជូនភាសាខ្មែរជាភារកិច្ចដ៏ធ្ងន់ធ្ងរនឹងដ៏លំបាក ពីព្រោះកង្វះឯកភាពបានជ្រួតជ្រាបដល់គ្រប់ស្រទាប់នៃសង្គមខ្មែរ។ កង្វះឯកភាពមិនទាក់ទងតែនឹងអក្ខរាវិរុទ្ធទេ ការប្រើពាក្យមិនដូចគ្នាសម្រាប់បញ្ញត្តិតែមួយ ឬ ការខ្ចីពាក្យមិនដូចគ្នាពីភាសាបរទេស.... ក៏ជាបញ្ហាធំធេងណាស់ដែរ។ ការអនុម័តពាក្យតាមជំនាញ ដើម្បីឱ្យគេប្រើពាក្យឱ្យត្រូវគ្នា ជាភារកិច្ចដែលត្រូវប្រើពេលយូរ រហូតដល់ចេញជាសទ្ទានុក្រមតាមជំនាញ។

ដើម្បីឱ្យការស្វែងរកឯកភាពជូនភាសាខ្មែរកាន់តែមានប្រសិទ្ធិភាព បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានស្នើសេចក្តីព្រាងច្បាប់មួយ កែប្រែគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ឱ្យទៅជាក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) ដោយបានស្នើសុំសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីលោកធ្វើជាប្រធានកិត្តិយស ហើយ ឥស្សរជនជាន់ខ្ពស់មួយចំនួន មានឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាដើម ក៏ត្រូវបានសុំឱ្យធ្វើជាទីប្រឹក្សាផងដែរ។

## <u>សរុបនិរទ្ទេសនិងសេចក្តីសន្និដ្ឋាន</u>

ទម្លាប់ជាធម្មជាតិទី២របស់មនុស្ស ដូច្នេះ អ្នកដែលធ្លាប់សរសេរឬប្រើពាក្យបែបនេះ តែងតែមានអារម្មណ៍មិនល្អ កាលណាគេឃើញអ្នកឯទៀតសរសេរឬប្រើពាក្យបែបនោះទៅវិញ។ ដោយអ្នកខ្លះសរសេរឬប្រើពាក្យបែបនេះ អ្នកខ្លះសរសេរឬប្រើពាក្យបែបនោះ យ៉ាងដូច្នេះហើយ បានជាភាសាខ្មែរយើងខ្វះឯកភាព។ ដើម្បីឱ្យភាសានេះមានឯកភាពឡើងវិញ (ដូចអរិយភាសាក្នុងលោក) គប្បីខ្មែរម្នាក់ៗខំអត់សង្កត់ចិត្ត កែទម្លាប់ណាដែលមិនស្របនឹងសេចក្តីសម្រេចរបស់ គ.ជ.ភ.ខ.។ សូមញ្ជាក់ជូនថា គ.ជ.ភ.ខ.មានតំណាងពីគ្រប់មជ្ឈដ្ឋានសំខាន់ៗ ហើយ ធ្វើការដោយផ្អែកលើបញ្ញាញាណ និង ប្រកាន់យកស្មារតីសម្រុះសម្រួលជាតិ។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់តំណាងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងជំនួបថ្ងៃនេះ និង សូមជូនពរដល់លោក សូមលោកប្រកបនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ព្រឹត្តិបត្រលេខ៣ បោះពុម្ពចំនួន ៤ ០០០ ច្បាប់
ឧបត្ថម្ភដោយ :

- លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា ចំនួន ៥០០ ច្បាប់
- លោកអគ្គបណ្ឌិត ប៊ុត សារ៉ង្ស ចំនួន ១ ០០០ ច្បាប់
- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ហ៊ាន សាហ៊ីប ចំនួន ១ ០០០ ច្បាប់
- ឯកឧត្តមបណ្ឌិត ហ្សូរ សុមេធ (បេក្ខជនបណ្ឌិតនៅរាជបណ្ឌិត្យសភាកម្ពុជា) និង លោកជំទាវ យិន ចន្ទ្រមណី ចំនួន ១ ០០០ ច្បាប់
- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត អ៊ាប បុណ្ណា ចំនួន ៥០០ ច្បាប់

បោះពុម្ពនៅរោងពុម្ព ម៉ៅ ផុន
ផ្ទះលេខ១៩១ E០ ផ្លូវលេខ១១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ